ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ប្រព័ន្ធផ្តល់ក្រេឌីតការអភិវឌ្ឍ វិជ្ជាជីវៈជាប្រចាំ

ខែសីហា ឆ្នាំ២០២១

# មាតិកា


**មាតិកា** ........ 1

**បញ្ជីអក្សរកាត់ និងពាក្យកាត់** ........ 2

**បុព្វកថា** ........ 5

**១. សេចក្តីផ្តើម** ........ 6

១.១ វិជ្ជាជីវៈគ្រូបង្រៀន ការលើកទឹកចិត្ត និងគុណភាពអប់រំ ........ 6

១.២ ទិដ្ឋភាពគោលនយោបាយ ........ 7

១.៣ ការិយាល័យគ្រប់គ្រង អវប ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស និងការគ្រប់គ្រងក្រេឌីត ........ 8

**២. គោលការណ៍ជាមូលដ្ឋាននៃប្រព័ន្ធក្រេឌីត អវប** ........ 15

២.១ ការបន្សីុប្រព័ន្ធក្រេឌីត អវប ........ 15

២.២ ប្រព័ន្ធក្រេឌីត និងគុណភាពនៃការអប់រំ៖ ការពិចារណាអំពីបន្ទុកការងារ ........ 20

**៣. បែបបទនៃប្រព័ន្ធក្រេឌីតការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ** ........ 20

៣.១ និយមន័យនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងប្រភេទនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ........ 20

៣.២ លក្ខណៈវិនិច្ឆ័យសម្រាប់ផ្តល់ក្រេឌីត អវប ........ 23

៣.៤ ការវាយតម្លៃលើសកម្មភាព អវប ........ 33

៣.៥ អ្នកផ្តល់សេវា អវប និងការទទួលស្គាល់គុណភាព ........ 35

**៤. ការប្រើប្រាស់ក្រេឌីត អវប** ........ 35

៤.១ ក្រេឌីត អវប រួមចំណែកដំឡើងគុណវុឌ្ឍិ និងកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀន ........ 35

៤.២ ក្រេឌីត អវប រួមចំណែកដល់ការឡើងឋានៈវិជ្ជាជីវៈ ស្របតាមគន្លងអាជីពគ្រូបង្រៀន ........ 39

៤.៣ ក្រេឌីត អវប រួមចំណែកដល់ការវាយតម្លៃតាមវដ្តទៀងទាត់ ........ 39

**៥. ដំណើរការផ្តល់ក្រេឌីត អវប** ........ 39

៥.១ ការផ្តល់ក្រេឌីតសម្រាប់ អវប មានរចនាសម្ព័ន្ធច្បាស់លាស់ ........ 39

៥.២ ការផ្តល់ក្រេឌីតដល់ អវប រៀនដោយខ្លួនឯង ........ 40

**ឯកសារយោង** ........ 42

**ឧបសម្ព័ន្ធទី១៖ ឧទាហរណ៍ដែលបង្ហាញពីការផ្តល់ក្រេឌីត អវប** ........ 43

**ឧបសម្ព័ន្ធទី២៖ តួនាទីរបស់ការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ** ........ 44



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## បញ្ជីអក្សរកាត់ និងពាក្យកាត់

| ពាក្យកាត់ | ភាសាអង់គ្លេស | ភាសាខ្មែរ |
|---|---|---|
| ACC | Accreditation Committee of Cambodia | គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា |
| ASEAN | Association of Southeast Asian Nations | សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ |
| AMS | ASEAN Member State | រដ្ឋជាសមាជិកអាស៊ាន |
| BA | Bachelor of Arts | បរិញ្ញាបត្រ |
| B Ed | Bachelor of Education | បរិញ្ញាបត្រអប់រំ |
| CPD | Continuous Professional Development | ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ |
| CPDMO | Continuous Professional Development Management Office | ការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ |
| DoPers | Department of Personnel | នាយកដ្ឋានបុគ្គលិក |
| DoE | District Office of Education | ការិយាល័យអប់រំ យុវជន និងកីឡា |
| DoP | Department of Planning | នាយកដ្ឋានផែនការ |
| DP | Development Partner | ដៃគូអភិវឌ្ឍន៍ |
| ECED | Early Childhood Education Department | នាយកដ្ឋានអប់រំកុមារតូច |
| EQAD | Education Quality Assurance Department | នាយកដ្ឋានធានាគុណភាពអប់រំ |
| ESP | Education Strategic Plan | ផែនការយុទ្ធសាស្ត្រវិស័យអប់រំ |
| GPE 3 | General Partnership for Education phase 3 programme | កម្មវិធីភាពជាដៃគូសកលដើម្បីការអប់រំ ដំណាក់កាលទី៣ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | | |
|---|---|---|
| GSED | General Secondary Education Department | នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ |
| HRMIS | Human Resource Management Information System | ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស |
| ICT | Information and Communications Technologies | បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ |
| INSET | In-Service Training | វិក្រឹតការគ្រូបង្រៀន |
| MA | Master of Arts | បរិញ្ញាបត្រជាន់ខ្ពស់ |
| M&E | Monitoring and Evaluation | ការតាមដាន និងវាយតម្លៃ |
| MoEYS | Ministry of Education, Youth and Sport | ក្រសួងអប់រំ យុវជន និងកីឡា |
| MOOC | Massive Open Online Course | វគ្គបណ្តុះបណ្តាលអនឡាញបើកទូលាយ |
| NGO | Non-Governmental Origination | អង្គការក្រៅរដ្ឋាភិបាល |
| NIE | National Institute of Education | វិទ្យាស្ថានជាតិអប់រំ |
| NQF | National Qualifications Framework | ក្របខណ្ឌគុណវុឌ្ឍិជាតិ |
| OECD | Organisation for Economic Co-operation and Development | អង្គការសម្រាប់កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍសេដ្ឋកិច្ច |
| PED | Primary Education Department | នាយកដ្ឋានបឋមសិក្សា |
| PoE | Provincial Office of Education | មន្ទីរអប់រំ យុវជន និងកីឡា |
| PhD | Doctor of Philosophy ( Doctorate ) | បណ្ឌិត |
| PLC | Professional Learning Community | សហគមន៍សិក្សាវិជ្ជាជីវៈ |
| PTEC | Phnom Penh Teacher Education College | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ |
| PTTC | Provincial Teacher Training Centre | សាលាគរុកោសល្យ និងវិក្រឹតការខេត្ត |

| | | |
|---|---|---|
| QA | Quality Assurance | ការធានាគុណភាព |
| RTTC | Regional Teacher Training Centre | មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ |
| SBM | School-Based Management | ការគ្រប់គ្រងតាមសាលារៀន |
| SEIP | Secondary Education Improvement Project | គម្រោងកែលម្អការអប់រំមធ្យមសិក្សា |
| STEPCam | Strengthening Teacher Education Programmes in Cambodia | កម្មវិធីពង្រឹងការអប់រំគ្រូបង្រៀននៅកម្ពុជា |
| TCP | Teacher Career Pathways | គន្លងអាជីពគ្រូបង្រៀន |
| TD | Technical Department | នាយកដ្ឋានជំនាញ |
| TEI | Teacher Education Institution | គ្រឹះស្ថានអប់រំគ្រូបង្រៀន |
| TEPS | Teacher Education Provider Standards | ស្តង់ដាគ្រឹះស្ថានអប់រំគ្រូបង្រៀន |
| TPAP | Teacher Policy Action Plan | ផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន |
| TTD | Teacher Training Department | នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ |
| TQU | Teacher Qualifications Upgrading | ការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន |
| TVET | Technical and Vocational Education and Training | ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| UNESCO | United Nations Educational, Scientific and Cultural Organisation | អង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌នៃសហប្រជាជាតិ |
| UNICEF | United Nations Children's Fund | មូលនិធិសហប្រជាជាតិដើម្បីកុមារ |
| USESDP-2 | Upper Secondary Education Sector Development Programme - 2 | កម្មវិធីអភិវឌ្ឍន៍វិស័យអប់រំមធ្យមសិក្សាទុតិយភូមិទី២ |
| VOD | Vocational Orientation Department | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ |

# បុព្វកថា

រាជរដ្ឋាភិបាលកម្ពុជាមានចក្ខុវិស័យអភិវឌ្ឍប្រទេសកម្ពុជា ឱ្យក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០ និងបានកំណត់ការអភិវឌ្ឍធនធានមនុស្សជាយុទ្ធសាស្ត្រអាទិភាពមួយក្នុងចំណោមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤។ ដើម្បីសម្រេចបាននូវគោលដៅនេះ គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការផលិតមូលធនមនុស្ស ដែលអាចជំរុញកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍប្រទេសប្រកបដោយចីរភាពឆ្ពោះទៅសម្រេចបាននូវគោលដៅឆ្នាំ២០៥០។

ការស្រាវជ្រាវបានបង្ហាញថា គ្រូបង្រៀនដែលទទួលបានការបណ្តុះបណ្តាលល្អ មានសមត្ថភាព និងមានទឹកចិត្តខ្ពស់ក្នុងការបំពេញការងារដោយបន្តអភិវឌ្ឍចំណេះដឹង និងបំណិនវិជ្ជាជីវៈរបស់ខ្លួន គឺជាកត្តាសំខាន់បំផុតនៅកម្រិតសាលារៀន ដែលមានផលជះវិជ្ជមានលើលទ្ធផលសិក្សារបស់សិស្ស។ ក្នុងន័យនេះដែរ គោលនយោបាយជាតិស្តីពីការសិក្សាពេញមួយជីវិតឆ្នាំ២០១៩ បានកំណត់ថា ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ជាកាតព្វកិច្ចចាំបាច់សម្រាប់ បុគ្គលិកអប់រំគ្រប់រូប ស្របតាមទស្សនាទាននៃការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

ដើម្បីទាក់ទាញ រក្សាទុក លើកទឹកចិត្ត និងអភិវឌ្ឍបេក្ខជនដែលមានសមត្ថភាពក្នុងវិជ្ជាជីវៈអប់រំ និងលើកកម្ពស់គុណភាពអប់រំ តម្រូវឱ្យមានប្រព័ន្ធរឹងមាំមួយដែលផ្សារភ្ជាប់ការបំពេញការងារប្រកបដោយវិជ្ជាជីវៈ ទៅនឹងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងប្រព័ន្ធផ្តល់លាភការ។ ថ្មីៗនេះ ក្រសួងអប់រំ យុវជន និងកីឡាបានបង្កើតគន្លងអាជីពគ្រូបង្រៀន ការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងគណៈកម្មការសម្រាប់ពិនិត្យ វាយតម្លៃ និងផ្តល់ការទទួលស្គាល់គុណភាពគ្រឹះស្ថាន និងអ្នកផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ហើយនឹងដាក់ឱ្យអនុវត្តប្រព័ន្ធគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស ដើម្បីគាំទ្រដល់ការអនុវត្តប្រព័ន្ធគន្លងអាជីពគ្រូបង្រៀន និងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។

នៅក្នុងឯកសារនេះ ប្រព័ន្ធផ្តល់ក្រេឌីតការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ គឺជាផ្នែកមួយដ៏សំខាន់នៃប្រព័ន្ធគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។ ខ្លឹមសារសំខាន់ៗផ្សេងទៀតនៅក្នុងឯកសារមានដូចជា៖ និយមន័យនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំក្នុងបរិបទនៃប្រព័ន្ធអប់រំកម្ពុជា គោលការណ៍គ្រឹះនៃប្រព័ន្ធក្រេឌីតការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ លក្ខណៈវិនិច្ឆ័យ និងដំណើរការសម្រាប់ការផ្តល់ក្រេឌីតការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដែលអាចជួយដល់ការដំឡើងគុណវុឌ្ឍិ និងវឌ្ឍនភាពអាជីព និងយន្តការធានាគុណភាពសម្រាប់ការរៀបចំ និងអនុវត្តសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។

ក្រសួងអប់រំ យុវជន និងកីឡាសង្ឃឹមយ៉ាងមុតមាំថា គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ ក៏ដូចជាអ្នកពាក់ព័ន្ធនឹងចូលរួមគាំទ្រព្រមទាំងប្រើប្រាស់ឯកសារនេះ ក្នុងការពង្រឹងប្រព័ន្ធអប់រំឆ្ពោះទៅសម្រេចបានគោលដៅរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រែក្លាយប្រទេសទៅជាសង្គមពុទ្ធិដែលមានការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចប្រកបដោយចីរភាព។

ថ្ងៃ ច័ន្ទ ៨រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែ សីហា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# ១. សេចក្តីផ្តើម

គ្រូបង្រៀនដែលទទួលបានការបណ្តុះបណ្តាលល្អ មានសមត្ថភាព និងមានឆន្ទៈម្ចាស់ការ ក្នុងការបន្តអភិវឌ្ឍចំណេះដឹងនិងជំនាញវិជ្ជាជីវៈ និងប្តេជ្ញាចិត្តរៀនសូត្រពេញមួយជីវិត គឺជាកត្តាសំខាន់ជាងគេបំផុតនៅកម្រិតសាលារៀន ដែលមានផលជះជាវិជ្ជមានលើលទ្ធផលសិក្សារបស់សិស្ស។ ដូច្នេះហើយរបៀបវារៈអន្តរជាតិដែលផ្តោតលើការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀនទទួលស្គាល់ថា ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ គឺជាសិទ្ធិនិងកាតព្វកិច្ចរបស់គ្រូបង្រៀន និងត្រូវបញ្ចូលទៅក្នុងកិច្ចសន្យារវាងគ្រូបង្រៀននិងនាយកសាលា។ ខណៈពេលដែលនាយកសាលាមានការប្តេជ្ញាចិត្តផ្តល់ឱកាស និងធានាថវិកាសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដើម្បីឱ្យគ្រូបង្រៀនចូលរួមក្នុងការសិក្សាវិជ្ជាជីវៈ គ្រូបង្រៀនក៏ត្រូវប្តេជ្ញាចិត្តអភិវឌ្ឍជំនាញ និងចំណេះដឹងវិជ្ជាជីវៈរបស់ខ្លួនផងដែរ។ ការទទួលបានការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំប្រកបដោយគុណភាពខ្ពស់ ជួយបង្កើនស័ក្តិសិទ្ធភាព និងធ្វើឱ្យគ្រូបង្រៀនកាន់តែមានទឹកចិត្តបង្រៀន តាមរយៈការទទួលបានឋានៈវិជ្ជាជីវៈក្នុងគន្លងអាជីពគ្រូបង្រៀន និងអត្ថប្រយោជន៍ផ្សេងៗ។ ភស្តុតាងជាច្រើនបង្ហាញថា ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានប្រសិទ្ធភាពបំផុត គឺជាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅតាមសាលារៀន ដែលផ្តល់លទ្ធភាពឱ្យគ្រូបង្រៀនអាចឆ្លុះបញ្ចាំងពីការបំពេញការងារជាប្រចាំបានពេញលេញ ដើម្បីឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន និងត្រូវផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងកំណែទម្រង់ជាប្រព័ន្ធ ក្នុងគោលបំណងលើកកម្ពស់គុណភាពអប់រំ។ គ្រូបង្រៀនគឺជាភ្នាក់ងារដែលបំពេញតួនាទីសំខាន់បំផុតក្នុងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់ខ្លួនដើម្បីក្លាយជាអ្នកជំនាញដ៏សកម្ម មានស្វ័យភាពលើការបំពេញវិជ្ជាជីវៈក្នុងថ្នាក់រៀន (UNESCO, 2015; Guerriero, 2017)។

កាលពីខែកញ្ញា ឆ្នាំ២០១៩ ក្រសួងអប់រំ យុវជន និងកីឡា បានអនុម័តក្របខណ្ឌ និងផែនការសកម្មភាពស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់គ្រូបង្រៀន នាយកសាលា ក្នុងគោលបំណងជួយឱ្យគ្រូបង្រៀន នាយកសាលាមានលទ្ធភាពបន្តអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈបានជាប្រចាំ ក្នុងនាមជាអ្នកអប់រំសតវត្សរ៍ទី២១។ នៅក្នុងបុព្វកថានៃឯកសារនេះ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** បានបញ្ជាក់ថា "ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំគឺជាអ្វីដែលអ្នកជំនាញត្រូវតែធ្វើ ដើម្បីសម្រួចចំណេះសម្បទា បំណិនសម្បទា និងចរិយាសម្បទារបស់ខ្លួន អោយស្របតាមឋានៈវិជ្ជាជីវៈថ្មីដែលពួកគេទទួលបាន តាមរយៈប្រព័ន្ធអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលមានការសម្របសម្រួលបានល្អ និងអនុវត្តទូទាំងប្រទេស ស្របតាមទស្សនាទានស្តីពីការរៀនសូត្រពេញមួយជីវិតសម្រាប់ទាំងអស់គ្នា" (MoEYS, 2019)។

ប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ រួមជាមួយនឹងគំនិតផ្តួចផ្តើមកសាងសមត្ថភាពផ្សេងទៀតដូចជា ការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន (TQU) ត្រូវបានរៀបចំឡើង ឱ្យឆ្លើយតបតាមតម្រូវការចំពោះមុខ សំដៅបង្កើនជំនាញវិជ្ជាជីវៈជាក់លាក់របស់គ្រូបង្រៀន ក៏ដូចជាសមត្ថភាពទូទៅ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍវិជ្ជាជីវៈរបស់បុគ្គលិកអប់រំ ជួយឱ្យកម្ពុជាក្លាយជាសង្គមពុទ្ធិ ជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងជាប្រទេសចំណូលខ្ពស់ត្រឹមឆ្នាំ២០៥០ (MoEYS, 2019)។

ប្រព័ន្ធសម្រាប់ផ្តល់ក្រេឌីតការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដែលបង្ហាញនៅក្នុងឯកសារ គឺជាសមាសភាគមួយដ៏សំខាន់នៃប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ។

## ១.១ វិជ្ជាជីវៈគ្រូបង្រៀន ការលើកទឹកចិត្ត និងគុណភាពអប់រំ

ប្រព័ន្ធ អវប មានចក្ខុវិស័យ និងគោលបំណងជួយឱ្យបុគ្គលិកអប់រំទទួលបានជំនាញ ចំណេះដឹង និងសមត្ថភាពវិជ្ជាជីវៈជាក់លាក់ ដោយមានការទទួលស្គាល់ពីក្រសួង អយក។ នេះគឺជាផ្នែកមួយនៃរបៀបវារៈលើកកម្ពស់វិជ្ជាជីវៈ

និងជំរុញឱ្យមានវប្បធម៌រៀនសូត្រពេញមួយជីវិត។ ជាមួយឱកាសអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ អាជីពគ្រូបង្រៀនមានភាពទាក់ទាញ និងរក្សាបេក្ខជនមានសមត្ថភាពខ្ពស់ឱ្យក្លាយជាគ្រូបង្រៀនមានជំនាញ ទឹកចិត្តបំពេញការងារ និងការប្តេជ្ញាចិត្តខ្ពស់ ដែលមានផលជះជាវិជ្ជមានដល់ការបំពេញការងារ និងលទ្ធផលសិក្សារបស់សិស្ស។ នៅអាស៊ី និងប្រទេសផ្សេងទៀត មានឯកសារជាច្រើនដែលបង្ហាញពី "វដ្តដែលនាំមកនូវភាពចម្រុងចម្រើន (virtuous cycle)" នៃវិជ្ជាជីវៈគ្រូបង្រៀនដូចជា ការបង្កើនសមត្ថភាព ការលើកទឹកចិត្តបំពេញការងារ ការផ្តល់រង្វាន់ ការដំឡើងឋានៈក្នុងសង្គម និងឋានៈវិជ្ជាជីវៈ នឹងធ្វើឱ្យប្រសើរឡើងនូវគុណភាព សេវាអប់រំ (Jensen, 2012; UNESCO, 2015; Guerriero, 2017)។ ផ្ទុយទៅវិញ នៅតាមប្រទេសដែលរដ្ឋាភិបាលមិនបានផ្តោតការយកចិត្តទុកដាក់លើការបណ្តុះបណ្តាលគ្រូបង្រៀនដែលមានគុណភាព ការអភិវឌ្ឍវិជ្ជាជីវៈ ការជួយគាំទ្រគ្រូបង្រៀន និងមិនមានប្រព័ន្ធផ្តល់លាភការច្បាស់លាស់ ធ្វើឱ្យគ្រូបង្រៀនគ្មានឆន្ទៈក្នុងការបំពេញការងារ និងមានឋានៈទាបនៅក្នុងសង្គម ជាហេតុនាំឱ្យលទ្ធផលនៃការអប់រំនៅមានកម្រិតទាប (VSO, 2007; UNESCO, 2015)។

## ១.២ ទិដ្ឋភាពគោលនយោបាយ

ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ ទទួលស្គាល់តួនាទីរបស់គ្រូបង្រៀន ក្នុងការបង្កើនគុណភាពនៃការអប់រំ ដែលជាអាទិភាពមួយ ក្នុងចំណោមអាទិភាពទាំង៧ ដែលក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញ ជាការឆ្លើយតបចំពោះយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា។ គោលនយោបាយទី១ នៃផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ មានគោលបំណងធានានូវការអប់រំប្រកបដោយគុណភាព បរិយាបន្ន សមធម៌ និងលើកកម្ពស់ឱកាសរៀនសូត្រពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ដោយបានចាត់ទុកការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់គ្រូបង្រៀន ការអភិវឌ្ឍសមត្ថភាព និងការលើកទឹកចិត្តបុគ្គលិក ជាអាទិភាពសំខាន់។

ក្រសួងអប់រំ យុវជន និងកីឡា បានអភិវឌ្ឍស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនឆ្នាំ២០១០ ដែលជាផ្នែកមួយនៃការខិតខំអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន។ ស្តង់ដានេះបានកំណត់សមាសភាពធំៗចំនួន៤៖ (១) ចំណេះដឹងវិជ្ជាជីវៈ (២) ការអនុវត្តវិជ្ជាជីវៈ (៣) ការសិក្សាវិជ្ជាជីវៈ និង(៤) ក្រមសីលធម៌វិជ្ជាជីវៈ សម្រាប់វាស់វែងចំណេះដឹង ជំនាញ និងឥរិយាបថវិជ្ជាជីវៈរបស់គ្រូបង្រៀន។ ក្របខណ្ឌអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងប្រព័ន្ធផ្តល់ក្រេឌីតការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលបានបង្ហាញនៅក្នុងឯកសារនេះ រួមចំណែកដោយផ្ទាល់ដល់ការលើកកម្ពស់សមត្ថភាពគ្រូបង្រៀន ជាការឆ្លើយតបទៅនឹងស្តង់ដាទី១ ដល់ទី៣។

ផ្អែកតាមគោលនយោបាយគ្រូបង្រៀនឆ្នាំ២០១៣ ផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន ដែលរៀបចំដោយនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ និងទទួលបានការអនុម័តកាលពីឆ្នាំ២០១៥ ដាក់ចេញនូវចក្ខុវិស័យថ្មីមួយសម្រាប់គ្រូបង្រៀននៅកម្ពុជាដូចជា ទាក់ទាញ និងរក្សាទុកគ្រូបង្រៀនដែលមានសមត្ថភាព លើកកម្ពស់គុណភាពនៃការបង្រៀននិងរៀន តាមរយៈការកែលម្អការបណ្តុះបណ្តាល និងការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន និងការលើកកម្ពស់ឋានៈគ្រូបង្រៀននៅក្នុងសង្គម។

ដូចគ្នានេះដែរ ស្តង់ដានាយកសាលាឆ្នាំ២០១៧ តម្រូវឱ្យនាយកសាលាបំពេញតាមស្តង់ដាចំនួន៦៖ (១) កម្រិតវប្បធម៌ និងបទពិសោធន៍ការងារ (២) សមត្ថភាព និងគុណសម្បត្តិរបស់នាយកសាលា (៣) បំណិនត្រិះរិះពិចារណា និងនវានុវត្តន៍ (៤) ភាពជាអ្នកដឹកនាំគ្រប់គ្រងរដ្ឋបាលសាលារៀន (៥) ភាពជាអ្នកដឹកនាំលើកម្មវិធីសិក្សា ការបង្រៀននិងរៀន និង(៦) ការភ្ជាប់សាលារៀន និងសហគមន៍។ ស្តង់ដាគ្រឹះស្ថានអប់រំគ្រូបង្រៀនឆ្នាំ២០១៦ ដាក់ចេញនូវលក្ខខណ្ឌសម្រាប់គ្រឹះស្ថានទាំងឡាយណាដែលអនុវត្តកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន និងសម្រាប់គ្រូឧទ្ទេស



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ដែលកំពុងបម្រើការងារនៅតាមគ្រឹះស្ថានទាំងនោះ។ ប្រកាសលេខ១៨៧០ កំណត់ពីក្របខណ្ឌ គោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់ដំឡើងគុណវុឌ្ឍិគ្រូបង្រៀនដល់កម្រិតបរិញ្ញាបត្រអប់រំ (ផ្តោតលើការបង្រៀន សម្រាប់គ្រូបង្រៀនកម្រិតមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ)។ គិតត្រឹមខែមិថុនា ឆ្នាំ២០២១ ស្តង់ដាវិជ្ជាជីវៈសម្រាប់អ្នកឯកទេសអប់រំ នៅមិនទាន់បានរៀបចំនៅឡើយ។ ការកំណត់ស្តង់ដាវិជ្ជាជីវៈអ្នកឯកទេសអប់រំ ក៏ជាអាទិភាពមួយផងដែរ ដើម្បីផ្តល់លទ្ធភាពកំណត់លក្ខណៈវិនិច្ឆ័យគុណភាពសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់អ្នកឯកទេសអប់រំ។

ផ្អែកតាមស្តង់ដា និងគោលនយោបាយដែលបង្ហាញខាងលើ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំគោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំសម្រាប់បុគ្គលិកអប់រំ កាលពីឆ្នាំ២០១៧ ក្នុងគោលបំណងអនុវត្តជាផ្លូវការនូវលិខិតបទដ្ឋានគតិយុត្ត យន្តការសម្រាប់ អវប ប្រព័ន្ធសម្រាប់តាមដាន អវប ការតាមដានពីតម្រូវការ អវប ការគ្រប់គ្រងនិងអនុវត្តកម្មវិធីវិក្រឹតការ ការលើកទឹកចិត្តនិងការរក្សាគ្រូបង្រៀនឱ្យនៅបន្តបំពេញការងារក្នុងប្រព័ន្ធអប់រំ និងការតាមដាន វាយតម្លៃលើប្រព័ន្ធ អវប។ គោលនយោបាយនេះនាំឱ្យមានការរៀបចំក្របខណ្ឌ អវប សម្រាប់គ្រូបង្រៀន និងនាយកសាលា ដែលជាមូលដ្ឋានសម្រាប់រៀបចំប្រព័ន្ធទទួលបានក្រេឌីត អវប។

ក្របខណ្ឌ និងផែនការសកម្មភាពស្តីពី អវប សម្រាប់គ្រូបង្រៀន និងនាយកសាលា ដែលរៀបចំឡើងនៅឆ្នាំ២០១៩ មានផែនទីបង្ហាញផ្លូវលម្អិតអំពីប្រព័ន្ធ អវប ដែលត្រូវដាក់ឱ្យប្រើប្រាស់ និងផ្សារភ្ជាប់ជាមួយនឹងគន្លងអាជីពគ្រូបង្រៀន ដើម្បីលើកគុណតម្លៃគ្រូបង្រៀន និងគុណភាពវិជ្ជាជីវៈបង្រៀន ក៏ដូចជាទាក់ទាញ និងរក្សាទុកបុគ្គលដែលមានសមត្ថភាពនិងមានទឹកចិត្តបម្រើការងារ ឱ្យចាប់យកអាជីពជាគ្រូបង្រៀន។ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំនឹងទទួលបានក្រេឌីត អវប ដែលរួមចំណែកដល់ការដំឡើងឋានៈវិជ្ជាជីវៈ និងការដំឡើងគុណវុឌ្ឍិ។

### ១.៣ ការិយាល័យគ្រប់គ្រង អវប ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស និងការគ្រប់គ្រងក្រេឌីត

ការិយាល័យគ្រប់គ្រង អវប នៃនាយកដ្ឋានបុគ្គលិករបស់ក្រសួងអប់រំ យុវជន និងកីឡា ទទួលខុសត្រូវលើការគ្រប់គ្រង និងពិនិត្យតាមដានការអនុវត្តផែនការសកម្មភាព អវប នៅថ្នាក់ជាតិ។

ប្រព័ន្ធផ្តល់ក្រេឌីត អវប ស្ថិតនៅក្រោមការគ្រប់គ្រងរដ្ឋបាល និងការចាត់ចែងរបស់ការិយាល័យគ្រប់គ្រង អវប។ ការិយាល័យគ្រប់គ្រង អវប មានបីផ្នែក៖ (១) ផ្នែកកត់ត្រា និងគ្រប់គ្រងទិន្នន័យ និងក្រេឌីត អវប (២) ផ្នែកសម្របសម្រួល កំណត់ស្តង់ដាគុណភាពអប្បបរមា ផ្តល់ការទទួលស្គាល់ ធានាគុណភាព និងរៀបចំថវិកា អវប (៣) ផ្នែកព័ត៌មាននិងផ្សព្វផ្សាយអំពី អវប។ ផ្នែកកត់ត្រា និងគ្រប់គ្រងទិន្នន័យ និងក្រេឌីត អវប ទទួលខុសត្រូវរក្សាទិន្នន័យក្រេឌីត អវប ដែលបុគ្គលិកអប់រំទទួលបាន និងទិន្នន័យស្តីពីសេវា អវប (សូមមើលឧបសម្ព័ន្ធទី២ អំពីតួនាទីនៃការិយាល័យគ្រប់គ្រង អវប) តាមរយៈ ម៉ូឌុល អវប និងគន្លងអាជីពគ្រូបង្រៀន ក្នុង HRMIS របស់ក្រសួងអប់រំ យុវជន និងកីឡា ។

រូបភាពទី១ ខាងក្រោមបង្ហាញពីទំនាក់ទំនងរវាង អវប ជាមួយនឹងប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស និងគន្លងអាជីពគ្រូបង្រៀន។

ក្រេឌីត អវប ដែលទទួលបាន តាមរយៈការបញ្ចប់ប្រកបដោយជោគជ័យនូវសកម្មភាព អវប ដែលមានការទទួលស្គាល់គុណភាព ត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធ HRMIS៖

ក) ចំពោះ អវប មានរចនាសម្ព័ន្ធច្បាស់លាស់ដែលមានការទទួលស្គាល់គុណភាព អ្នកផ្តល់សេវា អវប ត្រូវកត់ត្រាក្រេឌីត ដែលសិក្ខាកាមទាំងអស់ទទួលបានពីសកម្មភាព អវប ទៅក្នុងប្រព័ន្ធ HRMIS

ខ) ចំពោះ អវប រៀនដោយខ្លួនឯង អ្នកគ្រប់គ្រងផ្ទាល់ ឬគណៈគ្រប់គ្រងប្រចាំអង្គភាព នឹងកំណត់ពីភាព

ជោគជ័យនៃការចូលរួមក្នុងសកម្មភាព អវប រៀនដោយខ្លួនឯង ធៀបទៅនឹងផែនការអភិវឌ្ឍវិជ្ជាជីវៈប្រចាំឆ្នាំរបស់បុគ្គលិកអប់រំ។ ក្រេឌីត អវប ដែលពាក់ព័ន្ធ ត្រូវបានកត់ត្រានៅក្នុងប្រព័ន្ធ HRMIS នៅកម្រិតសាលារៀន ការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ ឬមន្ទីរ អយក រាជធានី ខេត្ត។ ក្នុងករណីដែល អវប ធ្វើឡើងនៅកម្រិតសាលារៀន ការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ ឬមន្ទីរ អយក រាជធានី ខេត្ត ត្រូវផ្តល់ការធានាគុណភាព ដោយផ្ទៀងផ្ទាត់សុពលភាពទិន្នន័យ ដែលបញ្ចូលទៅក្នុងប្រព័ន្ធ HRMIS និងធ្វើការពិនិត្យលើភស្តុតាងគាំទ្រនានា។

ក្របខណ្ឌអនុវត្តគន្លងអាជីពគ្រូបង្រៀនជាផ្នែកមួយនៃរបៀបវារៈអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន។ គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំទាំងអស់ ត្រូវឆ្លងកាត់ការវាយតម្លៃដើម្បីកំណត់ និងផ្តល់លាភការដល់អ្នកដែលធ្វើបានល្អ នៅក្នុងការងារដឹកនាំក៏ដូចជាការងារបង្រៀន ការចូលជាសមាជិកក្នុងក្រុមបង្រៀន និងការអភិវឌ្ឍវិជ្ជាជីវៈជាដើម។ ការវាយតម្លៃត្រូវរកឱ្យឃើញ និងទទួលស្គាល់នូវចំណុចខ្វះខាតដើម្បីធ្វើឱ្យប្រសើរឡើងនូវលទ្ធផលការងារ។ ការវាយតម្លៃផ្តោតលើសមត្ថភាពវិជ្ជាជីវៈ ដូចដែលបានកំណត់នៅក្នុងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ដើម្បីសម្រេចឱ្យបានគោលដៅ អវប។ អ្នកដែលទទួលបានលទ្ធផលល្អ មានឱកាសឡើងឋានៈវិជ្ជាជីវៈទៅកម្រិតខ្ពស់បន្ទាប់ក្នុងគន្លងអាជីពគ្រូបង្រៀន។ ឯកសារ ក្របខណ្ឌ និងសៀវភៅណែនាំប្រតិបត្តិគន្លងអាជីពគ្រូបង្រៀន ផ្តល់ការពន្យល់លម្អិតអំពីប្រព័ន្ធវាយតម្លៃ និងរបៀបដាក់ពិន្ទុលើលក្ខណៈវិនិច្ឆ័យនីមួយៗ។

ដូច្នេះ ក្រេឌីត អវប រួមចំណែកដល់លទ្ធផលនៃការវាយតម្លៃគន្លងអាជីពគ្រូបង្រៀន (សូមមើលរូបភាពទី១ ខាងក្រោម)។ រូបភាពទី១ បង្ហាញពី អវប មានទំនាក់ទំនងយ៉ាងជិតស្និទជាមួយនឹងគន្លងអាជីពគ្រូបង្រៀន ហើយព័ត៌មាននៃប្រព័ន្ធទាំងពីរនេះត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធ HRMIS។

*រូបភាពទី ១៖ ទំនាក់ទំនងរវាង អវប HRMIS និង TCP (ប្រភព៖ B. Khan និង S. Doctors)*






youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ប្រព័ន្ធផ្តល់ និងទទួលក្រេឌីត អវប ត្រូវគ្រប់គ្រង តាមរយៈម៉ូឌុល អវប នៃប្រព័ន្ធ HRMIS ដែលធ្វើការកត់ត្រាព័ត៌មានផ្សេងៗនៃសកម្មភាព អវប ដូចជា ខ្លឹមសារ អ្នកផ្តល់សេវា ចំនួនក្រេឌីត រយៈពេលនៃសកម្មភាព អវប ជាដើម។

ក្រេឌីតនឹងផ្តល់ជូនអ្នកដែលបានបញ្ចប់សកម្មភាព អវប ដោយជោគជ័យ ដែលផ្តល់ដោយអ្នកផ្តល់សេវា អវប មានការទទួលស្គាល់គុណភាពដូចជា គ្រឹះស្ថានអប់រំគ្រូបង្រៀន ដែលកំពុងអនុវត្តកម្មវិធីដំឡើងគុណវុឌ្ឍិ គ្រូបង្រៀននាពេលបច្ចុប្បន្ន និងគម្រោងដៃគូអភិវឌ្ឍន៍ ដែលផ្តល់សេវាវិក្រឹតការដូចជា STEPCam, SEIP និង USESDP-2 ជាដើម។

មន្ទីរ អយក រាជធានី ខេត្ត ប្រមូលទិន្នន័យក្រេឌីត អវប ពីសាលារៀនដោយផ្ទាល់ ឬតាមរយៈការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ។ ការិយាល័យគ្រប់គ្រង អវប ទទួលខុសត្រូវលើម៉ូឌុល អវប ក្នុងប្រព័ន្ធ HRMIS ដែលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិអាចចូលមើលបាន។ ការកត់ត្រាទិន្នន័យ អវប ចូលទៅក្នុងប្រព័ន្ធ HRMIS តាមប្រកចំនួនពីរ៖ ១) ពីសាលារៀន ក្រោយពីការវាយតម្លៃរួច និងការបង្ហាញភស្តុតាងនៅក្នុងកម្រងស្នាដៃវិជ្ជាជីវៈរបស់គ្រូបង្រៀននិងនាយកសាលា និង ២) ពីអ្នកផ្តល់សេវា អវប មានការទទួលស្គាល់គុណភាព ដែលត្រូវបញ្ចូលទៅក្នុងប្រព័ន្ធ HRMIS នូវបញ្ជីសកម្មភាព អវប និងលទ្ធផលឬពិន្ទុដែលអ្នកចូលរួមទទួលបាន។

រូបភាពទី២ បង្ហាញពីលំហូរ និងបែបបទ ពោលគឺគ្រូបង្រៀនចូលរួមក្នុងសកម្មភាព អវប បន្ទាប់មក មានការកត់ត្រាក្រេឌីតដែលទទួលបានទៅក្នុងប្រព័ន្ធ HRMIS និងបង្ហាញពីទំនាក់ទំនងរវាងប្រព័ន្ធ អវប និងគន្លងអាជីពគ្រូបង្រៀន។

*រូបភាពទី២៖ ប្រព័ន្ធលំហូរក្រេឌីត អវប និងទំនាក់ទំនងជាមួយនឹង TCP និង HRMIS (ប្រភព៖ B. Khan និង S. Doctors, ចម្លងចេញពីឯកសារពិពណ៌នាអំពីម៉ូឌុល អវប)*




t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

**ប្រព័ន្ធលំហូរក្រេឌីត អវប និងទំនាក់ទំនងជាមួយគន្លងអាជីពគ្រូបង្រៀន**

**១. គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ** គឺជាក្រុមគោលដៅនៃប្រព័ន្ធ អវប និងគន្លងអាជីពគ្រូបង្រៀន មានសិទ្ធិ និងកាតព្វកិច្ចក្នុងការចូលរួមសកម្មភាព អវប ដែលរៀបចំដោយមានគោលបំណងច្បាស់លាស់ និងទៀងទាត់ ព្រមទាំងមានឱកាសដាក់ពាក្យសុំឡើងឋានៈវិជ្ជាជីវៈស្របតាមគន្លងអាជីពគ្រូបង្រៀន និងតាមលក្ខណៈវិនិច្ឆ័យចាំបាច់។

**២. គណៈកម្មការ អវប** នៅតាមសាលារៀនត្រូវសម្របសម្រួលផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់គ្រូបង្រៀន និងនាយកសាលា រៀបចំវាយតម្លៃលើតម្រូវការ អវប របស់គ្រូបង្រៀនម្នាក់ៗ តម្រូវការនៅក្នុងសាលារៀន និងត្រូវផ្សព្វផ្សាយព័ត៌មានអំពីឱកាស អវប ដោយសហការជាមួយអ្នកផ្តល់សេវា អវប។

**៣. អវប មានរចនាសម្ព័ន្ធច្បាស់លាស់ អវប រៀនដោយខ្លួនឯង កម្មវិធីវិក្រឹតការ និងកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀន៖** អវប អាចរៀបចំឡើងដោយអ្នកផ្តល់សេវា មានរចនាសម្ព័ន្ធច្បាស់លាស់ និង ឬ ដែលសាមីខ្លួនជ្រើសរើសដោយខ្លួនឯង។ ឧទាហរណ៍៖ សកម្មភាព អវប ដែលរៀបចំដោយអ្នកផ្តល់សេវា ឬកម្មវិធីវិក្រឹតការ រួមមានវគ្គបណ្តុះបណ្តាល ឬសិក្ខាសាលាដែលផ្តល់ដោយគ្រឹះស្ថានអប់រំគ្រូបង្រៀន ដូចជាវគ្គបណ្តុះបណ្តាលនៅក្នុងកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀនជាដើម។ ឧទាហរណ៍៖ សកម្មភាព អវប រៀនខ្លួនឯង រួមមានការបញ្ចប់វគ្គសិក្សាអនឡាញបើកទូលាយ ការអានអត្ថបទស្រាវជ្រាវ និងការសរសេររបាយការណ៍សង្ខេបស្តីពីការយកចំណេះដឹងដែលទទួលបានទៅអនុវត្តនៅក្នុងសាលារៀន ការស្រាវជ្រាវប្រតិបត្តិ ឬការដឹកនាំកិច្ចប្រជុំចែករំលែកបទពិសោធន៍នៅក្នុងសហគមន៍សិក្សាវិជ្ជាជីវៈជាដើម។

**៤. ការទទួលក្រេឌីត អវប ៖** បន្ទាប់ពីបានបញ្ចប់សកម្មភាព អវប ដោយជោគជ័យ គ្រូបង្រៀន នាយកសាលា ឬអ្នកឯកទេសអប់រំ នឹងទទួលបានក្រេឌីត អវប។ អ្នកផ្តល់សេវាដែលមានការទទួលស្គាល់គុណភាព ត្រូវផ្ទៀងផ្ទាត់ និងបញ្ជាក់ឱ្យបានត្រឹមត្រូវចំពោះ អវប មានរចនាសម្ព័ន្ធច្បាស់លាស់ ហើយគណៈកម្មការ អវប នៅតាមសាលារៀន ជាអ្នកផ្ទៀងផ្ទាត់លើក្រេឌីតដែលបានពីសកម្មភាព អវប រៀនដោយខ្លួនឯង។ ក្រេឌីតទាំងនេះត្រូវបានបញ្ចូលទៅក្នុងកំណត់ត្រាអាជីព និងកត់ត្រាក្នុងប្រព័ន្ធ HRMIS។

**៥. ការវាយតម្លៃតាមវដ្តទៀងទាត់ និងលទ្ធផល៖** គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំទាំងអស់ត្រូវរៀបចំការវាយតម្លៃតាមវដ្តទៀងទាត់ជាមួយនឹងអ្នកគ្រប់គ្រងផ្ទាល់ដើម្បីវាស់វែងការបំពេញការងារធៀបនឹងចំណុចដៅដែលបានដាក់ចេញកាលពីឆ្នាំមុន ទទួលស្គាល់ពីលទ្ធផលដែលសម្រេចបាន កំណត់ពីបញ្ហាដែលត្រូវធ្វើការកែលម្អបន្ថែម និងដើម្បីកំណត់គោលដៅ អវប សម្រាប់ឆ្នាំបន្ទាប់។ ការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ តាមដានការវាយតម្លៃតាមវដ្តទៀងទាត់នេះ។ មន្ទីរ អយក រាជធានី ខេត្ត ពិនិត្យតាមដានការសម្របសម្រួល និងការគាំទ្ររបស់ការិយាល័យ អយក ក្រុង ស្រុក ខណ្ឌដែលផ្តល់ដល់សាលារៀនក្នុងការវាយតម្លៃតាមវដ្តទៀងទាត់ និងបញ្ចូលលទ្ធផលវាយតម្លៃទៅក្នុងប្រព័ន្ធ HRMIS។

**៦. ការត្រៀមឡើងឋានៈវិជ្ជាជីវៈតាមគន្លងអាជីពគ្រូបង្រៀន៖** អ្នកសន្សំបានក្រេឌីតពី អវប ហើយមានទំនុកចិត្តថាពិតជាបានបំពេញតាមលក្ខណៈវិនិច្ឆ័យនៃឋានៈវិជ្ជាជីវៈនីមួយៗស្របតាមគន្លងអាជីពគ្រូបង្រៀន អាចទទួលការ

វាយតម្លៃដំឡើងឋានៈក្នុងគន្លងអាជីពគ្រូបង្រៀន។ អ្នកអនុវត្ត អវប អាចបើកមើលព័ត៌មាន ឬពិន្ទុបច្ចុប្បន្នភាពផ្ទាល់ខ្លួនតាមកម្មវិធីទូរស័ព្ទចល័ត ហើយព័ត៌មានទាំងនោះនឹងបញ្ជាក់ពីលទ្ធភាពដែលអាចទទួលបានជោគជ័យក្នុងការវាយតម្លៃដំឡើងឋានៈវិជ្ជាជីវៈក្នុងគន្លងអាជីពគ្រូបង្រៀន។

**៧. ការវាយតម្លៃក្នុងគន្លងអាជីពគ្រូបង្រៀន និងការសម្រេចចិត្ត៖** អ្នកត្រៀមឡើងឋានៈវិជ្ជាជីវៈស្របតាមគន្លងអាជីពគ្រូបង្រៀន ត្រូវឆ្លងកាត់ការវាយតម្លៃ "កម្រិតខ្ពស់"។ ការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ ទទួលពាក្យសុំវាយតម្លៃរួចបញ្ជូនទៅមន្ទីរ អយក រាជធានី ខេត្តដើម្បីស្នើសុំការឯកភាព និងដំឡើងឋានៈវិជ្ជាជីវៈ ជូនទៅគណៈកម្មការ អវប។ ក្នុងអំឡុងពេលនៃការវាយតម្លៃនេះ បេក្ខជនបង្ហាញភស្តុតាងបញ្ជាក់ថាពួកគេពិតជាបំពេញទៅតាមលក្ខណៈវិនិច្ឆ័យដើម្បីឡើងឋានៈក្នុងគន្លងអាជីពគ្រូបង្រៀន។ គណៈកម្មការធ្វើការវាយតម្លៃ ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យ និងបញ្ចូលលទ្ធផលវាយតម្លៃក្នុងប្រព័ន្ធ HRMIS។ ប្រសិនបើការវាយតម្លៃនេះជោគជ័យ បេក្ខជនទទួលបានការឡើងឋានៈវិជ្ជាជីវៈទៅកម្រិតបន្ទាប់ទៀត។

**៨. ការមិនបំពេញបានតាមលក្ខណៈវិនិច្ឆ័យ គន្លងអាជីពគ្រូបង្រៀន ៖** បេក្ខជនមិនទទួលបានជោគជ័យអាចដាក់ពាក្យសារជាថ្មីនៅឆ្នាំបន្ទាប់ ដោយបេក្ខជនត្រូវខិតខំកែលម្អ ផ្នែកដែលទទួលពិន្ទុក្រោមស្តង់ដា។

**៩. សាលារៀន៖** អវប ក៏អាចរៀបចំនៅកម្រិតសាលារៀនផងដែរ មានន័យថាសកម្មភាព អវប ជាច្រើនអាចធ្វើឡើងនៅក្នុងសាលារៀន ដូច្នេះ អវប ទាំងនេះគឺពាក់ព័ន្ធផ្ទាល់ជាមួយនឹងសកម្មភាព និងលទ្ធផលនៃការបំពេញការងារនៅក្នុងថ្នាក់រៀន។ ការវាយតម្លៃគ្រូបង្រៀនតាមវដ្តទៀងទាត់ត្រូវធ្វើឡើងនៅកម្រិតសាលារៀន។

**១០. កម្រងសាលារៀន៖** កម្រងសាលារៀន គាំទ្រកម្មវិធីប្រឹក្សាគរុកោសល្យ និងសកម្មភាព អវប ដែលផ្តល់ដោយអ្នកផ្តល់សេវាដូចជា គ្រឹះស្ថានអប់រំគ្រូបង្រៀនដែលមានការទទួលស្គាល់គុណភាព ព្រមទាំងសម្របសម្រួលទំនាក់ទំនងរវាងការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ និងសាលារៀនដូចជា ការផ្សព្វផ្សាយព័ត៌មានជូនដល់សាលារៀន និងការបញ្ជូនទិន្នន័យស្តីពី អវប របស់គ្រូបង្រៀនម្នាក់ៗទៅកាន់ការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ ដែលបន្ទាប់មកត្រូវបញ្ជូនព័ត៌មាននេះបន្តទៀតទៅកាន់មន្ទីរ អយក រាជធានី ខេត្ត ដើម្បីបញ្ចូលទៅក្នុងប្រព័ន្ធ HRMIS។

**១១. ការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ ៖** មានតួនាទីសំខាន់សម្រាប់ផ្តល់ព័ត៌មានពីឱកាស និងក្រេឌីត អវប ទៅសាលារៀន ក៏ដូចជាផ្តល់ព័ត៌មានពី អវប ដែលគ្រូបង្រៀនម្នាក់ៗបានចូលរួម និងក្រេឌីតដែលទទួលបាន ដើម្បីបញ្ចូលទៅក្នុងប្រព័ន្ធ HRMIS តាមរយៈមន្ទីរ អយក រាជធានី ខេត្ត។ ការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ អាចតែងតាំងមន្ត្រីបង្គោលឱ្យទទួលខុសត្រូវលើ អវប និងគន្លងអាជីពគ្រូបង្រៀន។

**១២. មន្ទីរ អយក រាជធានី ខេត្ត៖** គ្រប់គ្រងប្រព័ន្ធ អវប និងគន្លងអាជីពគ្រូបង្រៀននៅថ្នាក់ក្រោមជាតិ និងផ្តល់ការទំនាក់ទំនងរវាងក្រសួងអប់រំ យុវជន និងកីឡា និងការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ។ មន្ទីរ អយក រាជធានី ខេត្តត្រូវសម្របសម្រួលគ្រប់សកម្មភាព អវប ជាផ្លូវការ។ មន្ត្រីបង្គោលរបស់មន្ទីរ អយក រាជធានី ខេត្ត ត្រូវរៀបចំ និងផ្សព្វផ្សាយប្រតិទិនពីឱកាស អវប នៅកម្រិតរាជធានី ខេត្ត។ មន្ទីរ អយក រាជធានី ខេត្តអាចចាត់តាំងមន្ត្រីបង្គោលឱ្យទទួលខុសត្រូវលើការងារ អវប និងគន្លងអាជីពគ្រូបង្រៀន។

**១៣. ការិយាល័យគ្រប់គ្រង អវប៖** គ្រប់គ្រងទិន្នន័យ អវប និង TCP ទាំងអស់នៅថ្នាក់ជាតិ រៀបចំគោលនយោបាយកំណត់ថវិកាគាំទ្រដល់សកម្មភាព អវប រាប់បញ្ចូលទាំងសកម្មភាព អវប នៅតាមសាលារៀន ផ្តល់ការទទួលស្គាល់គុណភាពដល់អ្នកផ្តល់សេវានិងកម្មវិធី អវប ព្រមទាំងផ្សព្វផ្សាយព័ត៌មានអំពីឱកាស អវប។ ការិយាល័យគ្រប់គ្រង អវប

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ផ្តល់ការគាំទ្រ និងសម្របសម្រួលសកម្មភាពនៅថ្នាក់ក្រោមជាតិតាមរយៈបណ្តាញរបស់ក្រសួងអប់រំ យុវជន និងកីឡារួមមាន នាយកដ្ឋានជំនាញ មន្ទីរ អយក រាជធានី ខេត្ត ការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ កម្រងសាលារៀន និងសាលារៀន។

**១៤. HRMIS (ម៉ូឌុល អវប និងគន្លងអាជីពគ្រូបង្រៀន)៖** គ្រប់គ្រងរាល់ទិន្នន័យទាំងអស់ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិជ្ជាជីវៈ និងវឌ្ឍនភាពអាជីពរបស់បុគ្គលិកអប់រំ។

**១៥. ការកត់ត្រាក្រេឌីត អវប និងកំណត់ត្រាអាជីព៖** រាល់សកម្មភាព អវប ទាំងអស់ត្រូវមានការកត់ត្រាចំនួនក្រេឌីត ប្រធានបទ ខ្លឹមសារសំខាន់ៗ និងមានការចេញផ្សាយកំណត់ត្រាអាជីពដែលបង្ហាញពីព័ត៌មាននៃការអនុវត្ត អវប រយៈពេល ៥ឆ្នាំម្តង ឬទៅតាមភាពចាំបាច់។

**១៦. ការឡើងឋានៈវិជ្ជាជីវៈក្នុងគន្លងអាជីពគ្រូបង្រៀន៖** មានការកត់ត្រាទិន្នន័យអំពីគុណវុឌ្ឍិ បទពិសោធន៍ លទ្ធផលនៃការវាយតម្លៃ និង អវប របស់បុគ្គលិកអប់រំ ដើម្បីចេញជារបាយការណ៍ដែលបង្ហាញព័ត៌មានលម្អិតស្តីពីពិន្ទុសម្រាប់ទទួលបានការឡើងឋានៈវិជ្ជាជីវៈទៅកាន់កម្រិតបន្ទាប់ក្នុងគន្លងអាជីពគ្រូបង្រៀន។

**១៧. នាយកដ្ឋានជំនាញ គ្រឹះស្ថានអប់រំគ្រូបង្រៀន គ្រឹះស្ថានឧត្តមសិក្សា និងអង្គការក្រៅរដ្ឋាភិបាល និងអ្នកផ្តល់សេវា អវប កម្មវិធីដំឡើងគុណវុឌ្ឍិ កម្មវិធីវិក្រឹតការឯកជន ៖** អ្នកផ្តល់សេវា អវប មានការទទួលស្គាល់គុណភាពពីការិយាល័យគ្រប់គ្រង អវប មានដូចជា នាយកដ្ឋានក្រោមឱវាទក្រសួង អយក គ្រឹះស្ថានអប់រំគ្រូបង្រៀន គ្រឹះស្ថានឧត្តមសិក្សា អង្គការក្រៅរដ្ឋាភិបាល អ្នកផ្តល់សេវា អវប កម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀន និងកម្មវិធីវិក្រឹតការឯកជនផ្សេងទៀតជាអ្នកផ្តល់សេវា អវប ផ្លូវការអាចធ្វើបាននៅតាមកម្រិតសាលារៀន។

**១៨. គ្រូបង្វឹក គ្រូប្រឹក្សា និងគ្រូឧទ្ទេសបង្គោលថ្នាក់ជាតិ៖** ជាបុគ្គលដែលបំពេញបានតាមលក្ខណៈវិនិច្ឆ័យជាអ្នកផ្តល់សេវាអប់រំ និងបានការទទួលស្គាល់គុណភាពពី ការិយាល័យគ្រប់គ្រង អវប អាចផ្តល់សេវា អវប នៅសាលារៀនដោយផ្ទាល់ ឬតាមរយៈគ្រឹះស្ថានដែលជាអ្នកផ្តល់សេវា អវប ផងដែរ។

**១៩. ការទទួលស្គាល់គុណភាព ការធានាគុណភាព និងការពិនិត្យតាមដានវាយតម្លៃ៖** ការិយាល័យគ្រប់គ្រង អវប សហការជាមួយនាយកដ្ឋានជំនាញពាក់ព័ន្ធពិសេសនាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ និងគណៈកម្មការទទួលស្គាល់គុណភាពអប់រំ ត្រូវធានាខុសត្រូវលើការទទួលស្គាល់គុណភាព ការធានាគុណភាព និងការតាមដានវាយតម្លៃប្រព័ន្ធ អវប ជាពិសេស លើការផ្តល់សេវា អវប ដែលផ្តល់ដោយបុគ្គល និងជាស្ថាប័នផ្តល់សេវា អវប។

**២០. ការកំណត់លក្ខណៈវិនិច្ឆ័យ ការទទួលស្គាល់គុណភាព និងក្រុមធានាគុណភាព៖** ការិយាល័យគ្រប់គ្រង អវប ធ្វើការសហការជាមួយអង្គភាពជំនាញពាក់ព័ន្ធដើម្បីកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ផ្តល់សេវា អវប ប្រកបដោយគុណភាព ។

ការិយាល័យគ្រប់គ្រង អវប នៃនាយកដ្ឋានបុគ្គលិករបស់ក្រសួងអប់រំ យុវជន និងកីឡានឹងចេញវិញ្ញាបនបត្រ អវប រៀងរាល់ ៥ឆ្នាំម្តង ឬទៅតាមការចាំបាច់ ដែលនឹងបង្ហាញពីចំនួនក្រេឌីត អវប ដើម្បីទទួលបានការឡើងឋានៈវិជ្ជាជីវៈ និងដំឡើងគុណវុឌ្ឍិ។ អ្នកផ្តល់សេវា អវប ឬក្រិតការ រាប់បញ្ចូលទាំងគម្រោងនានាផងដែរ អាចប្រើប្រាស់ឧបករណ៍តាមដាន និងវាយតម្លៃ អវប ដោយខ្លួនឯងដូចជា ការចុះវត្តមាន ការចូលរួម និងការកត់ត្រាលទ្ធផលរបាយការណ៍បណ្តុះបណ្តាលជាដើម ដែលនឹងត្រូវបំប្លែងទៅជាក្រេឌីត អវប សម្រាប់បញ្ចូលទៅក្នុងម៉ូឌុល អវប នៃប្រព័ន្ធ HRMIS ផ្អែកតាមលក្ខណៈវិនិច្ឆ័យដែលត្រូវបានកំណត់នៅក្នុងផ្នែកទី៣ ខាងក្រោម។

ការផ្តល់ក្រេឌីត អវប នឹងត្រូវចាត់ចែងដោយការិយាល័យគ្រប់គ្រង អវប ដែលផ្តល់ដោយអ្នកផ្តល់សេវា អវប និងកំណត់ពីចំនួនក្រេឌីត ស្របតាមប្រព័ន្ធផ្តល់ក្រេឌីត អវប។ កំណត់ត្រាអាជីពរបស់គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ ត្រូវបានប្រើប្រាស់សម្រាប់កត់ត្រាសកម្មភាព និងក្រេឌីត អវប ទាំងអស់ ហើយព័ត៌មានទាំងនេះក៏ត្រូវកត់ត្រាចូលទៅក្នុងម៉ូឌុល អវប នៃប្រព័ន្ធ HRMIS ផងដែរ។ ផ្នែកទី៣ ពន្យល់បន្ថែមពីដំណើរការផ្តល់ក្រេឌីត អវប និងការទទួលស្គាល់គុណភាពនៃសកម្មភាព អវប។

## ២. គោលការណ៍ជាមូលដ្ឋាននៃប្រព័ន្ធក្រេឌីត អវប

### ២.១ ការបន្សីប្រព័ន្ធក្រេឌីត អវប

ប្រព័ន្ធក្រេឌីត អវប មានសង្គតិភាពជាមួយប្រព័ន្ធដទៃជាច្រើនដូចខាងក្រោម៖

- ប្រព័ន្ធក្រេឌីត សម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀន
- ប្រព័ន្ធក្រេឌីត សម្រាប់កម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀន
- ប្រព័ន្ធក្រេឌីតឧត្តមសិក្សា ដែលផ្តល់ដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- ក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជាឆ្នាំ២០១២
- ប្រព័ន្ធវាយតម្លៃ និងផ្តល់វិញ្ញាបនបត្រផ្អែកតាមសមត្ថភាព និងគុណភាព (TVET) សម្រាប់កម្ពុជា
- ក្របខណ្ឌគុណវុឌ្ឍិអាស៊ានឆ្នាំ២០១៨
- គោលការណ៍ណែនាំរបស់អាស៊ានសម្រាប់ប្រព័ន្ធធានាគុណភាព និងទទួលស្គាល់វិញ្ញាបនបត្របញ្ជាក់ពីសមត្ថភាព
- ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនឆ្នាំ២០១០
- ស្តង់ដានាយកសាលាឆ្នាំ២០១៧
- ស្តង់ដាគ្រឹះស្ថានអប់រំគ្រូបង្រៀនឆ្នាំ២០១៦
- គន្លងអាជីពគ្រូបង្រៀន

ប្រព័ន្ធក្រេឌីតសម្រាប់ការបណ្តុះបណ្តាលគ្រូបង្រៀន (១២+២ និង ១២+៤) ព្រមទាំងកម្មវិធីឧត្តមសិក្សា (ដូចជា បរិញ្ញាបត្រ+១ ដើម្បីទទួលបានគុណវុឌ្ឍិសមមូលនឹងបរិញ្ញាបត្រអប់រំផ្នែកបង្រៀន ដូចចែងនៅក្នុងប្រកាសលេខ ១៨៧០) នៅកម្ពុជា អនុវត្តទៅតាមបញ្ញត្តិ ដែលចែងក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ស្តីពីការទទួលស្គាល់គុណភាពអប់រំនៅកម្រិតឧត្តមសិក្សា គោលការណ៍ណែនាំស្តីពីប្រព័ន្ធក្រេឌីត និងសេចក្តីសម្រេចឆ្នាំ២០០៤ ស្តីពីការផ្ទេរក្រេឌីតរបស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា។ ព្រះរាជក្រឹត្យនេះចែងថា តម្លៃមួយក្រេឌីត ស្មើនឹងការបង្រៀនមួយម៉ោងក្នុងមួយសប្តាហ៍ ក្នុងមួយឆមាស ដែលមានរយៈពេលយ៉ាងហោចណាស់ ១៥សប្តាហ៍។ សម្រាប់ការបង្រៀនមួយម៉ោង ត្រូវធ្វើស្វ័យសិក្សាយ៉ាងហោចណាស់ពីរម៉ោង



t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

ហើយបរិមាណស្វ័យសិក្សាបែបនេះកើនឡើងទៅតាមកម្រិតវគ្គសិក្សា។ ស្រដៀងគ្នានេះដែរ ប្រកាសលេខ ១៨៧០ ស្តីពីការដំឡើងគុណវុឌ្ឍិគ្រូបង្រៀនដល់កម្រិតបរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀន ចែងពីវិធីសាស្ត្រស្រដៀងគ្នានេះដែរ ដើម្បីបំប្លែងចំនួនម៉ោងរៀនធម្មតាទៅជាក្រេឌីត។ ប្រកាសលេខ ១៨៧០ ក៏បានកំណត់ពីចំនួនក្រេឌីតសម្រាប់កម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀន ដូចបង្ហាញនៅក្នុងតារាងទី៣ និងអំពីប្រភេទមុខជំនាញ ឧទាហរណ៍ ការសិក្សាអំពីការអប់រំ មុខវិជ្ជាឯកទេស ការសិក្សាពីកម្មវិធីសិក្សា។ល។ កម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀន ក៏បានបន្ស៊ីគ្នាជាមួយប្រព័ន្ធផ្តល់ក្រេឌីត អវប ផងដែរ ប៉ុន្តែប្រកាសនេះ ពុំបានលើកឡើងឱ្យបានច្បាស់ពីស្តង់ដាសមត្ថភាព ឬលក្ខណៈវិនិច្ឆ័យគុណភាពសម្រាប់កម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀន ក្នុងទម្រង់ជាការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្រអប់រំ។

ការធានាឱ្យមានភាពបន្ស៊ីគ្នារវាងការបណ្តុះបណ្តាលគ្រូបង្រៀន និង អវប គឺមានគោលបំណងដំឡើងគុណវុឌ្ឍិគ្រូបង្រៀនឱ្យដល់កម្រិតដូចគ្នា។ ប៉ុន្តែដោយសារ អវប អាចធ្វើឡើងតាមវិធីច្រើនយ៉ាង និងស្របតាមការសម្រេចដូចនៅក្នុងផែនការសកម្មភាពស្តីពី អវប ដើម្បីបង្កើតប្រព័ន្ធ អវប គេចាំបាច់ត្រូវធានា៖

ក) ការបន្ស៊ីប្រព័ន្ធក្រេឌីត អវប ឱ្យស្របតាមក្របខណ្ឌ និងគោលការណ៍ណែនាំដទៃទៀតស្តីពីការផ្តល់ក្រេឌីត

ខ) ការផ្តល់ក្រេឌីតដែលទទួលបានតាមរយៈ អវប រៀនដោយខ្លួនឯង ត្រូវស្របជាមួយនឹងការផ្តល់ក្រេឌីតសម្រាប់ អវប មានរចនាសម្ព័ន្ធច្បាស់លាស់។

ក្របខណ្ឌ និងគោលការណ៍ណែនាំដទៃទៀតស្តីពីការផ្តល់ក្រេឌីត ដែលប្រព័ន្ធក្រេឌីត អវប ត្រូវសម្របតាមរួមមាន៖ ក្របខណ្ឌគុណវុឌ្ឍជាតិកម្ពុជាឆ្នាំ២០១២ និងប្រព័ន្ធវាយតម្លៃនិងផ្តល់វិញ្ញាបនបត្របញ្ជាក់ផ្អែកតាមសមត្ថភាព (TVET) នៅកម្ពុជាឆ្នាំ២០១៧ ដែលកំណត់ដោយគណៈកម្មាធិការជាតិបណ្តុះបណ្តាលកម្ពុជា និងក្របខណ្ឌនិងគោលការណ៍ណែនាំរបស់អាស៊ានស្តីពីការផ្តល់វិញ្ញាបនបត្រ និងការធានាគុណភាពសម្រាប់ការអប់រំនៅកម្រិតនិងប្រភេទផ្សេងៗគ្នា។ ក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជាកំណត់ពីកម្រិតគុណវុឌ្ឍិ ចំនួនម៉ោងក្រេឌីតលទ្ធផលសិក្សា និងគន្លងសិក្សាសម្រាប់៖ ១) ការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ២) ការអប់រំកម្រិតឧត្តមសិក្សាដែលអនុញ្ញាតឱ្យគេអាចប្រើប្រាស់ក្រេឌីតដែលបានពីកម្មវិធីអប់រំ បណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ សម្រាប់រៀនយកសញ្ញាបត្រពីកម្មវិធីឧត្តមសិក្សា ស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា។ ម្យ៉ាងវិញទៀត ប្រព័ន្ធវាយតម្លៃ និងផ្តល់វិញ្ញាបនបត្រផ្អែកតាមសមត្ថភាពសម្រាប់កម្ពុជា (CBACS) បានបង្កើតនូវយន្តការវាយតម្លៃ និងផ្តល់វិញ្ញាបនបត្រដែលមានលក្ខណៈស្តង់ដា សម្រាប់ការអប់រំ បណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈនៅកម្ពុជា។ ទាំង CNQF ទាំង CBACS សុទ្ធតែប្រើប្រាស់រូបមន្តដូចគ្នាសម្រាប់ធ្វើការគណនាក្រេឌីតដែលបានពីការអប់រំកម្រិតឧត្តមសិក្សា និងបញ្ជាក់ពីសមត្ថភាពដោយបែងចែកជាប្រាំផ្នែក៖ ១) ចំណេះដឹង ២) ជំនាញក្នុងការគិត ៣) បំណិនចិត្តចលករ ៤) ជំនាញទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ និង ៥) ការប្រាស្រ័យទាក់ទង បច្ចេកវិទ្យាព័ត៌មាន និងជំនាញលេខនព្វន្ត (សូមមើលក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជាអំពីស្តង់ដាសមត្ថភាពសម្រាប់ផ្នែកនីមួយៗ ក្នុងចំណោមផ្នែកទាំង៥ សម្រាប់កម្រិតនីមួយៗនៃគុណវុឌ្ឍិ TVET)។

*តារាងទី១៖ កម្រិតនៃក្របខណ្ឌគុណវុឌ្ឍិការអប់រំនៅឧត្តមសិក្សា និងក្រេឌីតអប្បបរមាដែលចាំបាច់សម្រាប់កម្រិតនីមួយៗ*

| កម្រិត | ការអប់រំ បណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ | ការអប់រំកម្រិតឧត្តមសិក្សា | ក្រេឌីតអប្បបរមាដែលចាំបាច់ត្រូវមាន |
|---|---|---|---|
| ៨ | សញ្ញាបត្របណ្ឌិតផ្នែកបច្ចេកវិទ្យា/អប់រំធុរកិច្ច | បណ្ឌិត | ៥៤ |
| ៧ | សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកបច្ចេកវិទ្យា/អប់រំធុរកិច្ច | បរិញ្ញាបត្រជាន់ខ្ពស់ | ៤៥ |
| ៦ | សញ្ញាបត្របរិញ្ញាបត្រផ្នែកបច្ចេកវិទ្យា/អប់រំធុរកិច្ច | បរិញ្ញាបត្រ | ១២០ |
| ៥ | ការអប់រំកម្រិតខ្ពស់ផ្នែកបច្ចេកវិទ្យា/អប់រំធុរកិច្ច | បរិញ្ញាបត្ររង | ៦០ |
| ៤ | វិញ្ញាបនបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិតទី៣ | | ៣០ |
| ៣ | វិញ្ញាបនបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិតទី២ | | ៣០ |
| ២ | វិញ្ញាបនបត្របច្ចេកទេស និងវិជ្ជាជីវៈកម្រិតទី១ | | ៣០ |
| ១ | វិញ្ញាបនបត្រវិជ្ជាជីវៈ | | ៣០ |

ប្រព័ន្ធផ្ដល់ក្រេឌីត អវប នេះ ក៏ស្របតាមគោលការណ៍នៃការទទួលស្គាល់ការរៀនសូត្រកន្លងមក និងការទទួលស្គាល់សមត្ថភាពបច្ចុប្បន្នផងដែរ។ ប្រព័ន្ធវាយតម្លៃ និងផ្ដល់វិញ្ញាបនបត្រផ្អែកតាមសមត្ថភាពសម្រាប់កម្ពុជា ឱ្យនិយមន័យការទទួលស្គាល់ការរៀនសូត្រកន្លងមកថាជា "ដំណើរការវាយតម្លៃដែលផ្ដល់ជាជម្រើសសម្រាប់វាយតម្លៃជំនាញ ចំណេះដឹង និងការរៀនសូត្រកន្លងមក ដែលមិនទាន់បានទទួលស្គាល់ ចំពោះបុគ្គលម្នាក់ៗបានរៀនតាមរយៈក្រៅប្រព័ន្ធ និងក្រៅផ្លូវការ។ ការទទួលស្គាល់ការរៀនសូត្រកន្លងមក គឺជាដំណើរការវាយតម្លៃ ដែលមានការគាំទ្រ និងតម្រូវឱ្យមានការផ្ដល់ការគាំទ្រយ៉ាងច្រើនដល់បេក្ខជន" (CBACS ទំព័រទី១០) ខណៈពេលដែលការទទួលស្គាល់សមត្ថភាពបច្ចុប្បន្ន "សំដៅលើដំណើរការបញ្ជាក់ពីសញ្ញាបត្រ (វិញ្ញាបនបត្រ សញ្ញាបត្រ។ល។)" ដែលបេក្ខជនបានទទួលរួចទៅហើយ "ធៀបនឹងគុណវុឌ្ឍិ ឬស្តង់ដាសមត្ថភាពដែលត្រូវបានចុះបញ្ជីនាពេលបច្ចុប្បន្ន" (CBACS ទំព័រទី ១០)។

នៅក្នុងបរិបទទីផ្សារតែមួយរបស់អាស៊ាន រដ្ឋជាសមាជិកអាស៊ានទាំងអស់បានបង្កើតនូវក្របខណ្ឌគុណវុឌ្ឍិជាតិមួយ ដែលប្រើប្រាស់ជាឯកសារយោងសម្រាប់ "ផ្ដល់ការទទួលស្គាល់ដល់គុណវុឌ្ឍិ និងជំនាញធនធានមនុស្សជាច្រើនប្រភេទ ក្នុងឧស្សាហកម្ម" (Bateman, ២០១៦)។ សហគមន៍សេដ្ឋកិច្ចអាស៊ានមានក្របខណ្ឌចំនួន១០ ដែលបង្ហាញជូនជាសង្ខេបនៅក្នុងតារាងទី១០។ ក្របខណ្ឌនីមួយៗមានគុណវុឌ្ឍិជាច្រើនកម្រិតចាប់ពីកម្រិតទី១ ដល់កម្រិតទី១០ ដោយកម្រិតទី១ គឺជាកម្រិតទាបជាងគេ ពោលគឺកម្រិតបឋមសិក្សាជាដើម ហើយកម្រិតទី១០ គឺជាកម្រិតដែលខ្ពស់ជាងគេ ពោលគឺកម្រិតបណ្ឌិតជាដើម។ ប្រទេសកម្ពុជាកំពុងស្ថិតនៅដំណាក់កាលដំបូងក្នុងការអនុវត្តក្របខណ្ឌគុណវុឌ្ឍិរបស់ខ្លួន។ ស្តង់ដាសមត្ថភាពដែលចែងនៅក្នុងក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា គ្របដណ្ដប់លើជំនាញ និងសមត្ថភាពជាច្រើនដែលឆ្លុះបញ្ចាំងក្នុងក្របខណ្ឌគុណវុឌ្ឍិរបស់ប្រទេសអាស៊ានដទៃទៀតផងដែរ ដូចបង្ហាញនៅក្នុងតារាងទី៣។ គោលបំណងនៃប្រព័ន្ធផ្ដល់ក្រេឌីត អវប នេះ ស្នើឱ្យមានការបង្កើតយន្តការផ្ដល់ក្រេឌីតឱ្យស្របតាមយន្តការដែលមានចែងនៅក្នុងក្របខណ្ឌ ដែលត្រូវបានលើកយកមកពិភាក្សានៅក្នុងផ្នែកនេះ និងបង្ហាញលម្អិតនៅក្នុងផ្នែក២.២។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

*តារាងទី២៖ សង្ខេបរចនាសម្ព័ន្ធនៃក្របខណ្ឌគុណវុឌ្ឍិជាតិ (ប្រភព៖ ក្របខណ្ឌយោងគុណវុឌ្ឍិអាស៊ាន ឆ្នាំ២០១៨)*

| ប្រទេស | កម្រិត | ផ្នែក | ចំនួនក្រេឌីត |
|---|---|---|---|
| ប្រុយណេដារូសាឡឹម | ៨ | • ចំណេះដឹង និងជំនាញ (ប្រភេទចំណេះដឹង និង ជំនាញដែលពាក់ព័ន្ធ)<br>• ការអនុវត្ត៖ ការយកចំណេះដឹង និងការយល់ដឹង ទៅអនុវត្ត (បរិបទនៃការអនុវត្តចំណេះដឹង និង ជំនាញ)<br>• ជំនាញសិក្សារៀនសូត្រទូទៅ<br>• ជំនាញប្រាស្រ័យទាក់ទង ជំនាញបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ និងជំនាញលេខនព្វន្ត<br>• ស្វ័យភាព គណនេយ្យភាព និងការធ្វើការងារ ជាមួយអ្នកដទៃ (កម្រិតនៃភាពម្ចាស់ការ) | H Ed – ចំនួនម៉ោងរៀនក្នុងប្រទេស ៤០ម៉ោង=១ក្រេឌីត<br><br>TVET–ចំនួនម៉ោងរៀនក្នុងប្រទេស ១០ម៉ោង= ១ក្រេឌីត |
| កម្ពុជា | | • ចំណេះដឹង<br>• ជំនាញក្នុងការគិត<br>• បំណិនចិត្តចលករ<br>• ទំនាក់ទំនងអន្តរបុគ្គលនិងការទទួលខុសត្រូវ<br>• ជំនាញប្រាស្រ័យទាក់ទង បច្ចេកវិទ្យាព័ត៌មាននិង សារគមនាគមន៍ និងលេខនព្វន្ត | ប្រែប្រួលទៅតាមវិធីសាស្ត្រ |
| ឥណ្ឌូនេស៊ី | | បែងចែកជា ២ផ្នែក៖<br>• ផ្នែកទូទៅ៖ ចរិត បុគ្គលិកលក្ខណៈ ឥរិយាបថ ការងារ គុណធម៌ និងក្រមសីលធម៌<br>• ផ្នែកបំណិន៖<br>  ○ ជំនាញដើម្បីធ្វើការងារ និងសមត្ថភាព<br>  ○ វិទ្យាសាស្ត្រ/ចំណេះដឹង<br>  ○ វិធីសាស្ត្រ និងកម្រិតសមត្ថភាពក្នុងការ អនុវត្តវិទ្យាសាស្ត្រ/ចំណេះដឹង<br>  ○ ជំនាញគ្រប់គ្រង[1] | សម្រាប់ការអប់រំកម្រិតឧត្តមសិក្សា[2] |
| ឡាវ * | | • ចំណេះដឹង<br>• បំណិន<br>• ការអនុវត្ត<br>• បំណិនសង្គម | |

[1] អគ្គនាយកដ្ឋានឧត្តមសិក្សា (២០១២)

[2] ពុំបានបញ្ចូលទៅក្នុងច្បាប់

* ត្រូវបានស្នើឡើង

| | | | |
|---|---|---|---|
| ម៉ាឡេស៊ី | ៨ | • ចំណេះដឹង<br>• បំណិនអនុវត្ត<br>• បំណិនសង្គម និងការទទួលខុសត្រូវ គុណតម្លៃ ឥរិយាបថ និងវិជ្ជាជីវៈ<br>• បំណិនប្រាស្រ័យទាក់ទង ដឹកនាំ និងធ្វើការងារជាក្រុម<br>• បំណិនដោះស្រាយបញ្ហា និងបំណិនវិទ្យាសាស្ត្រ<br>• បំណិនគ្រប់គ្រងព័ត៌មាន និងការសិក្សាពេញមួយជីវិត<br>• បំណិនគ្រប់គ្រង និងសហគ្រិនភាព | ៤០ម៉ោង =១ក្រេឌីត |
| មីយ៉ាន់ម៉ា * | ៨ | • ចំណេះដឹង និងបំណិន<br>• ការអនុវត្ត និងសមត្ថភាព<br>• ការទទួលខុសត្រូវ | |
| ហ្វីលីពីន | ៨ | • ចំណេះដឹង បំណិន និងគុណតម្លៃ<br>• ការអនុវត្ត<br>• កម្រិតនៃភាពម្ចាស់ការ (ស្វ័យភាព និងការទទួលខុសត្រូវ) | - |
| សឹង្ហបុរី | ៦ | • កម្រិតចំណេះដឹង និងជំនាញដែលពាក់ព័ន្ធ<br>• កម្រិតនៃការអនុវត្តចំណេះដឹង និងជំនាញ<br>• កម្រិតគណនេយ្យភាព ភាពម្ចាស់ការ ការរៀបចំខ្លួន និងការរៀបចំអ្នកដទៃទៀត ដែលចាំបាច់សម្រាប់ដោះស្រាយបញ្ហា ឬបំពេញកិច្ចការនានា<br>• ដឹងពីកម្រិតវិជ្ជាជីវៈ និងភាពស៊ីជម្រៅនៃចំណេះសម្បទា និងបំណិនសម្បទាដែលចាំបាច់សម្រាប់ការងារដែលពាក់ព័ន្ធនឹងគុណវុឌ្ឍិនេះ | គុណវុឌ្ឍិជំនាញរបស់កម្លាំងពលកម្ម ១ក្រេឌីត ស្មើនឹងម៉ោងរៀន(RLH) ចំនួន ១០ម៉ោង (១ ក្រេឌីត = ១០ ម៉ោង)[3]។ |
| ថៃ | ៩ | • ចំណេះសម្បទា<br>• បំណិនសម្បទា<br>• ចរិយាសម្បទា | មាន |
| វៀតណាម * | ៨ | • ចំណេះសម្បទា<br>• បំណិនសម្បទា<br>• ស្វ័យភាព និងការទទួលខុសត្រូវ | ១ក្រេឌីត=៣០ម៉ោង |

[3] ចំនួនម៉ោងរៀនដែលផ្តល់ជាអនុសាសន៍ (RLH) ត្រូវបានឱ្យនិយមន័យថាជាចំនួនម៉ោងដែលសិក្ខាកាមធម្មតាម្នាក់ត្រូវរៀនគិតជាមធ្យមដើម្បីទទួលបានលទ្ធផលសិក្សារៀនសូត្រ ដែលត្រូវបានកំណត់ជាមួយឯកតា ដោយមិនគិតពីវិធីសាស្ត្របណ្តុះបណ្តាល និងវាយតម្លៃដែលត្រូវបានយកមកអនុវត្តនោះឡើយ។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ប្រព័ន្ធក្រេឌីត អវប ត្រូវបានរៀបចំឱ្យស្របតាមគន្លងអាជីពគ្រូបង្រៀន (TCP)។ គន្លងអាជីពគ្រូបង្រៀនចែកចេញជា ៣គន្លង៖ គន្លងបង្រៀន គន្លងគ្រប់គ្រង និងគន្លងឯកទេសអប់រំ។ គន្លងនីមួយៗមានឋានៈវិជ្ជាជីវៈ៣កម្រិត ដែលបេក្ខជនអាចទទួលនៅពេលបំពេញបានទៅតាមលក្ខណៈវិនិច្ឆ័យ។ ក្រេឌីត អវប រួមចំណែកដល់ការរីកចម្រើននៃអាជីពស្របតាមគន្លងអាជីពនេះ។

## ២.២ ប្រព័ន្ធក្រេឌីត និងគុណភាពនៃការអប់រំ៖ ការពិចារណាអំពីបន្ទុកការងារ

ប្រព័ន្ធក្រេឌីត អវប ជួយគាំទ្រការធ្វើឱ្យប្រសើរឡើងគុណភាពគ្រូបង្រៀន និងស្តង់ដានៃការអប់រំគ្រូបង្រៀន ឬគុណវុឌ្ឍិគ្រូបង្រៀន និងមិនធ្វើឱ្យប៉ះពាល់ដល់គុណភាព និងស្តង់ដាទាំងនេះឡើយ។ ដូច្នេះ គេមិនគួរលើកទឹកចិត្តគ្រូបង្រៀនឱ្យទុកចោលកាតព្វកិច្ចបង្រៀនរបស់ខ្លួន ដើម្បីចូលរួមសកម្មភាព អវប នោះឡើយ ប៉ុន្តែគ្រូបង្រៀនគួរចូលរួមនៅក្នុងសកម្មភាព អវប ដើម្បីធ្វើឱ្យការបំពេញវិជ្ជាជីវៈរបស់ខ្លួនកាន់តែប្រសើរ។

គោលនយោបាយ អវប ចែងពីសិទ្ធិ និងកាតព្វកិច្ចរបស់គ្រូបង្រៀន ដោយកំណត់ឱ្យចូលរួមនៅក្នុងសកម្មភាព អវប ចំនួន ១០០ម៉ោងក្នុងមួយឆ្នាំ ប្រហែលជា ៣ម៉ោងក្នុងមួយសប្តាហ៍។ ក្របខណ្ឌ អវប ផ្តល់ជាអនុសាសន៍ថាគ្រូបង្រៀនគួរមានថ្ងៃមិនបង្រៀនចំនួន ៥ថ្ងៃ ក្នុងមួយឆ្នាំ ដើម្បីចូលរួមសកម្មភាព អវប ស្មើនឹង ៤០ម៉ោង មានន័យថា ពួកគេចាំបាច់ត្រូវចំណាយពេលផ្ទាល់ខ្លួន ៦០ម៉ោងបន្ថែមទៀត ដើម្បីរួមចំណែកដល់ អវប ឱ្យបានចំនួនម៉ោងសរុប ១០០ម៉ោង។ នៅក្នុងការអនុវត្តជាក់ស្តែង គ្រូបង្រៀនមានសិទ្ធ និងលទ្ធភាព ចូលរួមនៅក្នុងសកម្មភាព អវប យ៉ាងហោចណាស់ ៣ម៉ោង ក្នុងមួយសប្តាហ៍ ដោយប្រើប្រាស់ម៉ោងបំពេញការងាររបស់ពួកគាត់។ ឧទាហរណ៍ គ្រូបង្រៀនបឋមសិក្សាមិនបង្រៀននៅថ្ងៃព្រហស្បតិ៍ សប្តាហ៍ទី៤ នៃខែនីមួយៗ ដែលជាថ្ងៃសម្រាប់ប្រជុំបច្ចេកទេស ប្រជុំសហគមន៍សិក្សាវិជ្ជាជីវៈ ជួយសិស្សរៀនយឺត... ហើយផ្តល់ឱកាសឱ្យគ្រូបង្រៀនបឋមសិក្សាចូលរួម អវប រយៈពេល ៣ម៉ោងនៅក្នុងអំឡុងពេលនេះ។ គ្រូបង្រៀនមធ្យមសិក្សាបឋមភូមិ បង្រៀន ១៨ម៉ោង និងគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិបង្រៀន ១៦ម៉ោង ដែលផ្តល់លទ្ធភាពឱ្យពួកគេមានពេល ៣ម៉ោងក្នុងមួយសប្តាហ៍ ដើម្បីចូលរួមនៅក្នុងសកម្មភាព អវប។ ក្នុងករណីគ្រូបង្រៀនពីរវេន នៅតាមសាលារៀនដែលជួបប្រទះនឹងការខ្វះគ្រូបង្រៀន វាអាចប៉ះពាល់ដល់ការចូលរួមសកម្មភាព អវប ឱ្យបាន ៣ម៉ោង ជារៀងរាល់សប្តាហ៍នៅក្នុងម៉ោងបំពេញការងារ។ បន្ថែមលើកាតព្វកិច្ចចូលរួម អវប ១០០ម៉ោង ក្នុងមួយឆ្នាំ គ្រូបង្រៀនដែលមានបំណងចង់ចូលរួម អវប ដើម្បីទទួលបានក្រេឌីតបន្ថែម ត្រូវបានលើកទឹកចិត្តឱ្យចំណាយពេលចុងសប្តាហ៍ និងវិស្សមកាល សម្រាប់ចូលរួមនៅក្នុងសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈ។

# ៣. បែបបទនៃប្រព័ន្ធក្រេឌីតការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

## ៣.១ និយមន័យនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងប្រភេទនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

### ៣.១.១ និយមន័យនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

ក្របខណ្ឌ និងផែនការសកម្មភាពស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ឱ្យនិយមន័យ អវប សម្រាប់ប្រទេសកម្ពុជាថា "ការបណ្តុះបណ្តាលឯកទេស ការអប់រំក្នុងប្រព័ន្ធនិងក្រៅផ្លូវការ ឬការសិក្សាវិជ្ជាជីវៈកម្រិតខ្ពស់ជាច្រើនប្រភេទ ដែលមានគោលបំណងជួយឱ្យគ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំបង្កើនចំណេះដឹង និងជំនាញប្រកបដោយប្រសិទ្ធភាព" (ទំព័រទី៨)។ យ៉ាងណាមិញ និយមន័យដែលមានលក្ខណៈទូលំទូលាយជាង

នេះ ហើយក្តោបលើគោលការណ៍សំខាន់ៗនៃ អវប ដែលពាក់ព័ន្ធនឹងការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀនចាត់ទុកថា អវប គួរ៖

- ធ្វើឡើងជាប្រចាំ
- ធ្វើស្វ័យភាព និងគ្រប់គ្រងការសិក្សាដោយខ្លួនឯង
- អនុវត្តផ្អែកតាមតម្រូវការ និងស្ថានភាពអភិវឌ្ឍន៍បច្ចុប្បន្នរបស់បុគ្គលម្នាក់ៗ
- កំណត់ពីលទ្ធផលការរៀនសូត្រ និងអភិវឌ្ឍវិជ្ជាជីវៈឱ្យបានច្បាស់លាស់ ដើម្បីបំពេញទៅតាមតម្រូវការរបស់បុគ្គល និងអង្គភាព
- វាយតម្លៃលទ្ធផលសិក្សាដោយផ្អែកលើសកម្មភាព និងភស្តុតាងជាក់លាក់
- ចាត់ទុកថាជាផ្នែកមួយដ៏សំខាន់នៃវិជ្ជាជីវៈ និងជីវិតផ្ទាល់ខ្លួន មិនមែនត្រឹមតែជាសកម្មភាពបន្ថែមដែលធ្វើក៏បាន មិនធ្វើក៏បាននោះឡើយ (Marchington និង Wilkinson, 2009: 377)។

អវប អាចត្រូវបានដាក់ឱ្យអនុវត្តក្នុងទម្រង់ផ្សេងៗគ្នាដូចជា ការបណ្តុះបណ្តាល សិក្ខាសាលា សន្និសីទ និងព្រឹត្តិការណ៍ កម្មវិធីរៀនសូត្រតាមប្រព័ន្ធអនឡាញ កិច្ចប្រជុំរបស់សហគមន៍សិក្សាវិជ្ជាជីវៈ (PLC) សកម្មភាពដែលធ្វើដោយខ្លួនឯងដូចជា ការអានអត្ថបទស្រាវជ្រាវវិជ្ជាជីវៈ។ល។ ដែលផ្តោតលើការបង្កើនចំណេះដឹងនិងសមត្ថភាពផ្ទាល់ខ្លួន និងវិជ្ជាជីវៈរបស់បុគ្គលម្នាក់ៗ ដែលផ្តល់លទ្ធភាពឱ្យពួកគេអាចបន្តបង្កើនជំនាញ និងរៀនជំនាញឡើងវិញដោយខ្លួនឯង ទៅតាមគោលដៅរបស់ស្ថាប័ន គោលដៅវិជ្ជាជីវៈ និងគោលដៅផ្ទាល់ខ្លួន។

### ៣.១.២ ប្រភេទការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

ប្រព័ន្ធក្រេឌីត អវប ត្រូវធ្វើការពិចារណាលើ អវប ចំនួន ២ប្រភេទ៖

- អវប មានរចនាសម្ព័ន្ធច្បាស់លាស់ សំដៅលើការសិក្សា វគ្គបំប៉ន វគ្គបណ្តុះបណ្តាលក្នុងប្រព័ន្ធ ឬសកម្មភាពដទៃទៀត ដែលផ្តល់ដោយអ្នកផ្តល់សេវាមានការទទួលស្គាល់គុណភាពដូចជា គ្រឹះស្ថានអប់រំគ្រូបង្រៀន ដៃគូអភិវឌ្ឍន៍ និងនាយកដ្ឋានជំនាញក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា
- អវប រៀនដោយខ្លួនឯង សំដៅលើសកម្មភាពដែលបុគ្គលិកអប់រំធ្វើឡើងដោយខ្លួនឯង ដោយពុំមានការគាំទ្រជាផ្លូវការពីអ្នកផ្តល់សេវាមានការទទួលស្គាល់គុណភាព ប៉ុន្តែស្ថិតនៅក្នុងវិសាលភាពក្របខណ្ឌ អវប ដែរ។

ការចូលរួមនៅក្នុង អវប ទាំង ២ប្រភេទនេះ អាចនាំឱ្យមានការទទួលបានក្រេឌីត អវប[4]។ ប្រព័ន្ធ អវប កំពុងត្រូវបានដាក់ឱ្យអនុវត្តនៅក្នុងប្រទេសកម្ពុជាជាជំណាក់កាល ចាប់ផ្តើមពី អវប មានរចនាសម្ព័ន្ធច្បាស់លាស់។

[4] ក្របខណ្ឌ និងផែនការសកម្មភាព អវប បានលើកឡើងពីប្រព័ន្ធក្រេឌីត អវប កូនកាត់ ដែលបានពីការសិក្សា និងពីប្រភពផ្សេងទៀតដែលមិនមែនការជាសិក្សា (១៧)។ អវប ដែលបានពីការសិក្សាសំដៅលើ អវប ដែលផ្តល់ដោយគ្រឹះស្ថានអប់រំគ្រូបង្រៀន ឬគ្រឹះស្ថានឧត្តមសិក្សា និងនាំឱ្យមានការផ្តល់ក្រេឌីតសម្រាប់វគ្គសិក្សា (ដូចជាកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀនជាដើម) ហើយ អវប ដែលមិនបានពីការសិក្សាអាចជា អវប ដែលធ្វើនៅតាមសាលារៀន តាមកម្រងសាលារៀន ឬផ្តល់ដោយគ្រឹះស្ថានអប់រំគ្រូបង្រៀន ឬដោយក្រសួងអប់រំ យុវជន និងកីឡា។ ប្រព័ន្ធក្រេឌីត អវប នៅក្នុងឯកសារនេះ ត្រូវបានរៀបចំឡើងផ្អែកទៅតាមនិយមន័យនេះ ដើម្បីផ្តល់លទ្ធភាពឱ្យគេអាចប្រើប្រាស់ អវប ដែលរៀនដោយខ្លួនឯង ដើម្បីរួមចំណែកដល់ការដំឡើងគុណវុឌ្ឍិគ្រូបង្រៀន ប៉ុន្តែមានការកំណត់នូវប៉ារ៉ាម៉ែត្រមួយចំនួនសម្រាប់ អវប ប្រភេទនេះ។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

### ៣.១.២.១ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ មានរចនាសម្ព័ន្ធច្បាស់លាស់

អវប មានរចនាសម្ព័ន្ធច្បាស់លាស់រួមមាន សកម្មភាពអនុវត្តដែលផ្តល់ដោយអ្នកផ្តល់សេវាមានការទទួលស្គាល់គុណភាព មានការជួបគ្នាផ្ទាល់ក្នុងក្របខណ្ឌពេលវេលាមួយជាក់លាក់។ សកម្មភាពដែលជួបផ្ទាល់អាចធ្វើឡើងជាទម្រង់សិក្ខាសាលា វគ្គបណ្តុះបណ្តាល វគ្គបំប៉ន សកម្មភាពស្រាវជ្រាវជាក្រុម ឬសកម្មភាពដទៃទៀត។ អ្នកសិក្សាចូលរួមសកម្មភាពជួបផ្ទាល់មួយម៉ោង ត្រូវធ្វើស្វ័យសិក្សាយ៉ាងហោចណាស់ ២ម៉ោងបន្ថែម។ គ្រូបង្រៀនត្រូវមានតួនាទីសំខាន់ក្នុងការអភិវឌ្ឍសមត្ថភាពខ្លួនឯងតាមរយៈ អវប ព្រោះ អវប គឺជាដំណើរការដ៏សកម្ម។ អវប មានរចនាសម្ព័ន្ធច្បាស់លាស់ ក៏តម្រូវឱ្យមានការធ្វើស្វ័យសិក្សាក្នុងក្របខណ្ឌពេលវេលាមួយសមស្រប និងតម្រូវឱ្យគ្រូបង្រៀន ឬនាយកសាលាបង្ហាញថាពិតជាបានចូលរួមនៅក្នុងដំណើរការ អវប ពិតប្រាកដមែន។ អ្នកចូលរួម អវប ត្រូវបញ្ជាក់ពីភស្តុតាងថាពិតជាបានយកមេរៀនដែលទទួលបាន ទៅប្រើប្រាស់នៅក្នុងការអនុវត្តវិជ្ជាជីវៈរបស់ខ្លួននៅក្នុងថ្នាក់រៀន សាលារៀន ក្នុងគោលបំណងឆ្លុះបញ្ចាំងពីទំនាក់ទំនងរវាងទ្រឹស្តី ការអនុវត្ត នីតិវិធីដែលជួយឱ្យការបង្រៀន និងការដឹកនាំកាន់តែមានភាពល្អប្រសើរ។ សម្រាប់ព័ត៌មានបន្ថែមអំពីការផ្តល់ក្រេឌីត អវប ដែលមានរចនាសម្ព័ន្ធច្បាស់លាស់ សូមមើលផ្នែក៥.១ ខាងក្រោម។

### ៣.១.២.២ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ រៀនដោយខ្លួនឯង

អវប រៀនដោយខ្លួនឯង ធ្វើឡើងផ្អែកទៅតាមប្រភពធាតុចូល និងលក្ខខណ្ឌតម្រូវដែលគ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំម្នាក់ៗស្វែងរកដោយខ្លួនឯង ដោយមិនប្រើប្រាស់សេវារបស់អ្នកផ្តល់សេវា អវប។ ប្រភពធាតុចូលនេះរួមមាន វគ្គបណ្តុះបណ្តាលអនឡាញបើកទូលាយ (MOOC) ការចូលរួមនិងការបង្ហាញស្នាដៃស្រាវជ្រាវផ្ទាល់ខ្លួននៅក្នុងសន្និសីទ ឬសកម្មភាពសិក្សាវិជ្ជាជីវៈដទៃទៀត ការចូលរួមនៅក្នុងការស្រាវជ្រាវ ការអានឯកសារស្រាវជ្រាវវិជ្ជាជីវៈក្នុងទម្រង់ជាព្រឹត្តបត្រស្រាវជ្រាវឬសៀវភៅ ការស្រាវជ្រាវ និងបោះពុម្ពផ្សាយអត្ថបទអ្វីមួយជាដើម។ល។ នៅពេលដែលប្រព័ន្ធផ្តល់ក្រេឌីត អវប រៀនដោយខ្លួនឯង ត្រូវបានដាក់ឱ្យដំណើរការ នោះការិយាល័យគ្រប់គ្រង អវប នឹងត្រូវផ្សព្វផ្សាយបញ្ជីប្រភពធាតុចូលដែលមានការទទួលស្គាល់។

ការអនុវត្ត អវប រៀនដោយខ្លួនឯង ពីប្រភពមិនទាន់មានការទទួលស្គាល់គុណភាព ក៏អាចទទួលបានក្រេឌីតផងដែរ។ គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ ចាំបាច់ត្រូវដាក់សំណើសុំការទទួលស្គាល់គុណភាពទៅការិយាល័យគ្រប់គ្រង អវប លើប្រភពដែលខ្លួនបានសិក្សា។

ចំពោះការអនុវត្ត អវប រៀនដោយខ្លួនឯងពីប្រភពណាមួយ ក្នុងរយៈពេល ១ម៉ោង អ្នកចូលរួមត្រូវធ្វើស្វ័យសិក្សាលើកិច្ចការអនុវត្តយ៉ាងហោចណាស់ ២ម៉ោងបន្ថែម។ គ្រូបង្រៀន នាយកសាលា ឬអ្នកឯកទេសអប់រំ ត្រូវបង្ហាញឱ្យឃើញថាពួកគេពិតជាបានចូលរួមយ៉ាងសកម្មក្នុងដំណើរការ អវប តាមរយៈការផ្តល់ជាភស្តុតាងបញ្ជាក់ថា ពិតជាបានយកទៅប្រើប្រាស់នៅក្នុងការអនុវត្តវិជ្ជាជីវៈនៅក្នុងថ្នាក់រៀន សាលារៀន និងត្រូវធ្វើការឆ្លុះបញ្ចាំងពីទំនាក់ទំនងរវាងទ្រឹស្តី ការអនុវត្ត និងបង្ហាញពីរបៀបការសិក្សាដែលជួយឱ្យការបំពេញការងារកាន់តែល្អប្រសើរជាងមុន។ សម្រាប់ព័ត៌មានបន្ថែមអំពីរបៀបទទួលបានក្រេឌីត អវប រៀនដោយខ្លួនឯង សូមមើលផ្នែក ៥.២ ខាងក្រោម។

ការធ្វើចំណាត់ថ្នាក់បែបនេះ បញ្ជាក់យ៉ាងច្បាស់ថា អវប មានរចនាសម្ព័ន្ធច្បាស់លាស់ និង អវប រៀនដោយខ្លួនឯងមានចំណុចត្រួតគ្នាមួយចំនួន ហើយ អវប ទាំងពីរប្រភេទនេះត្រូវការស្វ័យសិក្សាជាច្រើនម៉ោងបន្ថែមទៀត។ បើតាមការយល់ដឹងពីការអប់រំគ្រូបង្រៀននាពេលបច្ចុប្បន្ននេះ រាប់បញ្ចូលទាំង អវប ផង ផ្តោតសំខាន់

លើតួនាទីនៃការឆ្លុះបញ្ចាំងនៅគ្រប់កម្រិតទាំងអស់៖ គ្រូបង្រៀន ឬគរុសិស្ស គរុនិស្សិតត្រូវបានលើកទឹកចិត្តឱ្យធ្វើការឆ្លុះបញ្ចាំងជាប្រចាំពីការអនុវត្តវិជ្ជាជីវៈផ្អែកតាមទ្រឹស្តី ផ្សារភ្ជាប់ទៅនឹងបទពិសោធន៍នៅក្នុងថ្នាក់រៀន។ ការឆ្លុះបញ្ចាំងបែបនេះ គឺផ្អែកទៅតាមទស្សនាទានរបស់*អ្នកអនុវត្តដែលចេះធ្វើការឆ្លុះបញ្ចាំង* (*reflective practitioner*)។ គ្រូបង្រៀនដែលជាអ្នកសិក្សាពេញមួយជីវិត ត្រូវបន្តធ្វើការវាយតម្លៃ និងខិតខំឆ្លុះបញ្ចាំង ក៏ដូចជាអភិវឌ្ឍបន្ថែមលើការអនុវត្តវិជ្ជាជីវៈ។

នៅក្នុងបរិបទកម្ពុជាមានការបែងចែក អវប ខុសៗគ្នាដូចជា អវប រយៈពេលខ្លី និងរយៈពេលវែង។ ប៉ុន្តែការបែងចែកបែបនេះមានភាពមិនច្បាស់លាស់ និងបង្កការលំបាកក្នុងការចាត់ថ្នាក់ អវប។

## ៣.២ លក្ខណៈវិនិច្ឆ័យសម្រាប់ផ្តល់ក្រេឌីត អវប

ការផ្តល់ក្រេឌីត អវប ត្រូវធ្វើឡើង ផ្អែកតាម៖

- ចំនួនម៉ោង អវប មានរចនាសម្ព័ន្ធច្បាស់លាស់ ដែលបានចូលរួមប្រកបដោយជោគជ័យ
- ចំនួនម៉ោងស្វ័យសិក្សាសម្រាប់សកម្មភាព អវប ដែលបានអនុវត្តប្រកបដោយជោគជ័យ
- គុណភាពនិងខ្លឹមសារនៃកម្មវិធី និងសកម្មភាព អវប រួមនឹងសមត្ថភាពដែលមានការកើនឡើង (ការកំណត់លក្ខណៈវិនិច្ឆ័យនិងស្តង់ដា)
- ការវាយតម្លៃ (ការបង្ហាញពីលទ្ធផល និងផលជះ)

### ៣.២.១ ចំនួនម៉ោង អវប ដែលត្រូវបានអនុវត្តប្រកបដោយជោគជ័យ

ប្រព័ន្ធក្រេឌីត អវប ត្រូវបានរៀបចំឡើងឱ្យស្របតាមកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន ពោលគឺដើម្បីបញ្ចប់វគ្គសិក្សាដែលមាន ៣ក្រេឌីត គរុសិស្សត្រូវជួបផ្ទាល់រយៈពេល ៣ម៉ោង និងធ្វើស្វ័យសិក្សាដោយខ្លួនឯងរយៈពេល ៦ម៉ោង ឬការងារមន្ទីរពិសោធន៍ឬការងារចុះកម្មសិក្សាដល់ទីកន្លែងរយៈពេល ៩ម៉ោង ក្នុងមួយសប្តាហ៍ យ៉ាងហោចណាស់រយៈពេល ១៥សប្តាហ៍ និងត្រូវបង្ហាញថាខ្លួនមានសមត្ថភាពបំពេញតាមលក្ខខណ្ឌអប្បបរមានៃការវាយតម្លៃ។ ឧទាហរណ៍ បរិញ្ញាបត្រអប់រំដែលផ្តល់ដល់គរុនិស្សិតមុនពេលចេញបម្រើការងារ ជាធម្មតាមាន ៥ មុខវិជ្ជាក្នុងមួយឆមាស ស្មើនឹង ១៥ក្រេឌីត (ស្មើនឹង ៦៧៥ម៉ោង ដែលក្នុងនោះរៀនផ្ទាល់ ២២៥ម៉ោង) និងត្រូវរៀនរយៈពេល ៨ឆមាស ស្មើនឹង ១២០ក្រេឌីត ទើបទទួលបានបរិញ្ញាបត្រអប់រំ។

ប៉ុន្តែ "ចំនួនម៉ោងនៃការអនុវត្ត អវប តែមួយ" មិនត្រូវបានគេចាត់ទុកថាជាមូលដ្ឋានសមស្រប សម្រាប់ផ្តល់ក្រេឌីត អវប។ លើសពីនេះ គេក៏ត្រូវបំពេញទៅតាមលក្ខណៈវិនិច្ឆ័យគុណភាពដែលកំណត់ពីគុណភាពខ្លឹមសារ ព្រមទាំងលទ្ធផលឬផលជះដែលអាចវាស់វែងបាន។

- គោលការណ៍ជាមូលដ្ឋានសម្រាប់បែងចែកក្រេឌីត អវប គឺសកម្មភាព អវប ត្រូវមានការសិក្សា ឬសកម្មភាពជួបផ្ទាល់រយៈពេល ១៥ម៉ោង បូកនឹង ៣០ម៉ោងស្វ័យសិក្សា (ការងារអនុវត្តដោយខ្លួនឯង ការស្រាវជ្រាវ ការពិសោធ ឬការយកជាតុចូលទៅប្រើប្រាស់ក្នុងការអនុវត្តការងារ) ឬការចុះកម្មសិក្សាដល់ទីកន្លែងរយៈពេល ៤៥ម៉ោង ហើយបំពេញបានលក្ខណៈវិនិច្ឆ័យគុណភាព គុណភាព និងលទ្ធផល ឬផលជះ ដែលអាចវាស់វែងបានទើបទទួលបាន ១ ក្រេឌីត។

សម្រាប់ករណី អវប រៀនដោយខ្លួនឯង ហើយគ្មានម៉ោងជួបផ្ទាល់ជាមួយគ្រូឧទ្ទេស ចំណុចនេះត្រូវវាយតម្លៃផ្តល់ក្រេឌីតតាមរយៈធាតុចូលនៃប្រភព ដែលមានការទទួលស្គាល់គុណភាពដូចជា MOOC កាលិកបត្រវិជ្ជាជីវៈ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ឬសៀវភៅសិក្សាជាដើម។ ដូច្នេះសម្រាប់ អវប រៀនដោយខ្លួនឯង គោលការណ៍ជាមូលដ្ឋានគឺសកម្មភាព អវប ត្រូវស្មើនឹង "ធាតុចូល" រយៈពេល ១៥ម៉ោង ពីប្រភពដែលត្រូវបានទទួលស្គាល់គុណភាព បូកនឹងការងារអនុវត្ត ស្រាវជ្រាវ ឬយកធាតុចូលនេះទៅប្រើប្រាស់ដោយខ្លួនឯង ៣០ម៉ោង ទើបអាចបំពេញទៅតាមលក្ខណៈវិនិច្ឆ័យគុណភាព គុណភាព និងលទ្ធផលឬផលជះដែលអាចវាស់វែងបាន នឹងទទួលបាន ១ក្រេឌីត។

**មួយក្រេឌីត អវប នឹងត្រូវផ្តល់សម្រាប់៖**

- **ការសិក្សា ឬសកម្មភាពជួបផ្ទាល់រយៈពេល ១៥ម៉ោង+៣០ម៉ោង ស្វ័យសិក្សា (ការងារអនុវត្តដោយខ្លួនឯង ការស្រាវជ្រាវ ការពិសោធ ឬការយកធាតុចូលទៅប្រើប្រាស់ក្នុងការអនុវត្តការងារ)**
- **កម្មសិក្សាគរុកោសល្យ ឬការអនុវត្តផ្ទាល់រយៈពេល ៤៥ម៉ោង**
- **រៀនដោយខ្លួនឯងពីប្រភពមានគុណភាពសមស្រប ១៥ម៉ោង + ៣០ម៉ោង ស្វ័យសិក្សា (ការអនុវត្តដោយខ្លួនឯង ការស្រាវជ្រាវ ការពិសោធ ឬការយកធាតុចូលទៅប្រើប្រាស់ក្នុងការអនុវត្តការងារ) ដោយមានការបញ្ជាក់លើលទ្ធផលសិក្សាពីគណៈគ្រប់គ្រងបានត្រឹមត្រូវ**
- **ស្វ័យសិក្សាឯករាជ្យសុទ្ធ ការពិសោធ ឬការងារចុះកម្មសិក្សារយៈពេល ៤៥ម៉ោង ដោយមានការបញ្ជាក់លើលទ្ធផលសិក្សាពីគណៈគ្រប់គ្រងបានត្រឹមត្រូវ**

**លទ្ធផលនៃការសិក្សាខាងលើត្រូវស្របតាមស្តង់ដាគុណភាពអប្បបរមាឆ្លើយតបទៅនឹងលទ្ធផលរំពឹងទុក និងផលជះដែលនាំឱ្យមានការផ្លាស់ប្តូរវិជ្ជមានក្នុងការអនុវត្តការងារ។**

កិច្ចប្រជុំបច្ចេកទេសដែលពាក់ព័ន្ធនឹងការងារមិនចាត់ទុកថាជា អវប ឡើយហើយក៏មិនអាចប្រើប្រាស់ដើម្បីទទួលបានក្រេឌីត អវប នោះដែរ។

ឧទាហរណ៍ខាងក្រោមបង្ហាញពីសកម្មភាព អវប ដែលគ្រូបង្រៀនអាចទទួលបាន ១ក្រេឌីត អវប។

***ឧទាហរណ៍ ពីការបង្ហាញសកម្មភាព អវប មានរចនាសម្ព័ន្ធច្បាស់លាស់ ដែលទទួលបាន ១ ក្រេឌីត៖***

***ឧទាហរណ៍ទី១***

សិក្ខាសាលាចូលរួមផ្ទាល់ចំនួន ២ថ្ងៃ (១៥ម៉ោង) បន្ទាប់មកមានការដាក់កិច្ចការឱ្យធ្វើ ដែលត្រូវចំណាយពេលធ្វើស្វ័យសិក្សាចំនួន ៣០ម៉ោង និងត្រូវរៀបចំរបាយការណ៍សម្រាប់ឱ្យគេវាយតម្លៃ។

***ឧទាហរណ៍ទី២***

សិក្ខាសាលាដែលមានការចូលរួមផ្ទាល់រយៈពេល ៥ថ្ងៃ ដោយ ១ថ្ងៃ រៀន ៣ម៉ោង និងចំណាយពេល ៦ម៉ោងជារៀងរាល់ថ្ងៃធ្វើការជាក្រុម ដើម្បីរៀបចំលទ្ធផលរំពឹងទុកសមស្រប។

***ឧទាហរណ៍ទី៣***

ការចូលរួមនៅក្នុងសកម្មភាពផ្តល់ប្រឹក្សាគរុកោសល្យ៖

- ការអនុវត្តក្នុងថ្នាក់រៀនសរុបចំនួន ៨ម៉ោង ដោយមានចូលរួមពីគ្រូប្រឹក្សាគរុកោសល្យ
- ការពិភាក្សាដោយមានរចនាសម្ព័ន្ធច្បាស់លាស់សរុបចំនួន ៧ម៉ោង ដើម្បីកំណត់ចំណុច និងយុទ្ធសាស្ត្រដែលត្រូវធ្វើការកែលម្អ

- ការចូលរួមពិភាក្សាដែលមានរយៈពេល ៣០ម៉ោង ដើម្បីឆ្លើយតបចំពោះចំណុចដែលត្រូវបានកំណត់ (ស្វ័យសិក្សា និងការធ្វើផែនការចំនួន ១៥ម៉ោង ការចំណាយពេលចំនួន ១៥ម៉ោង ដើម្បីរៀបចំរបាយការណ៍បង្ហាញពីវិធីសាស្ត្រសម្រាប់ដោះស្រាយបញ្ហា យុទ្ធសាស្ត្រដើម្បីជម្នះបញ្ហា និងលទ្ធផល) ដែលត្រូវបញ្ជាក់ផ្ទៀងផ្ទាត់ក្នុងអំឡុងពេលវេលាវាយតម្លៃតាមវត្តទៀងទាត់។

***ឧទាហរណ៍អំពីសកម្មភាព អវប រៀនដោយខ្លួនឯង ដែលនាំឱ្យមានការទទួលបាន ១ក្រេឌីត៖***

***ឧទាហរណ៍ទី១***

ការចូលរួមនៅក្នុងការរៀនអនឡាញរយៈពេល ១៥ម៉ោង ក្នុងកម្មវិធី MOOC និងការងារគម្រោង រយៈពេល ៣០ម៉ោង ដែលនាំឱ្យសម្រេចបាននូវលទ្ធផលអ្វីមួយដោយត្រូវឆ្លងកាត់ការវាយតម្លៃក្នុងអំឡុងការវាយតម្លៃទៀងទាត់តាមអង្គភាពឬគ្រឹះស្ថានសិក្សា។

***ឧទាហរណ៍ទី២***

ការចូលរួមនៅក្នុងបន្ទប់ពិគ្រោះការងារបង្រៀន (teaching lab) ដែលរៀបចំដោយសហគមន៍សិក្សាវិជ្ជាជីវៈក្នុងរយៈពេល ១០សប្តាហ៍ (ចូលរួម ៣ម៉ោងក្នុងមួយសប្តាហ៍ ការត្រៀមរៀបចំសម្រាប់ចូលរួមនៅក្នុងកិច្ចប្រជុំ និងការរៀបចំរបាយការណ៍ ១៥ម៉ោង)៖ នៅសប្តាហ៍នីមួយៗគ្រូបង្រៀន ១នាក់ ឡើងបង្ហាញពីស្ថានភាពនៅក្នុងថ្នាក់រៀនដែលពួកគេចង់បានជាតុចូល និងការគាំទ្រពីមិត្តរួមការងាររបស់ពួកគេ គ្រូបង្រៀនផ្លាស់វេណគ្នាបង្រៀនដើម្បីឱ្យមិត្តរួមការងារដទៃទៀតសង្កេត។ គ្រូបង្រៀនសាមីដែលអ្នកដទៃទៀតកំពុងសិក្សាពីស្ថានភាពរបស់ខ្លួន ត្រូវដឹកនាំកិច្ចប្រជុំសុំព័ត៌មានត្រឡប់ និងសរសេររបាយការណ៍សង្ខេបពីការសិក្សាវិជ្ជាជីវៈដែលពួកគេបានទទួល។

***ឧទាហរណ៍ទី៣***

ការចូលរួមនៅក្នុងគម្រោងស្រាវជ្រាវប្រតិបត្តិ៖ ការចំណាយពេល ៥ម៉ោង ដើម្បីរៀបចំគម្រោងជាមួយនឹងគ្រូផ្តល់ប្រឹក្សាគរុកោសល្យឬប្រធានសហគមន៍សិក្សាវិជ្ជាជីវៈ រួមនឹងការស្វែងយល់ពីគោលការណ៍នៃការស្រាវជ្រាវប្រតិបត្តិ ការចំណាយពេល ៣០ម៉ោង អនុវត្តសកម្មភាពស្រាវជ្រាវប្រតិបត្តិនៅក្នុងថ្នាក់រៀន និងការធ្វើការងារជាមួយនឹងមិត្តរួមការងារ ការចំណាយពេល ១០ម៉ោង ដើម្បីសរសេររបាយការណ៍។

## ៣.៣ គុណភាព ខ្លឹមសារ កម្មវិធី សកម្មភាពរបស់ អវប និងសមត្ថភាពដែលត្រូវបានបង្កើន

ដូចបង្ហាញពីខាងដើម ក្រេឌីត អវប ត្រូវបានផ្តល់ផ្អែកតាម៖

- ចំនួនម៉ោង អវប មានរចនាសម្ព័ន្ធច្បាស់លាស់ ដែលត្រូវបានអនុវត្តប្រកបដោយជោគជ័យ
- ចំនួនម៉ោងសកម្មភាព អវប រៀនដោយខ្លួនឯង ដែលត្រូវបានអនុវត្តប្រកបដោយជោគជ័យ
- គុណភាព ខ្លឹមសារ កម្មវិធី សកម្មភាពរបស់ អវប និងសមត្ថភាពដែលត្រូវបានបង្កើន (ការកំណត់លក្ខណៈវិនិច្ឆ័យ និងស្តង់ដា)
- ការវាយតម្លៃ (ការបង្ហាញពីលទ្ធផល និងផលជះ)

ដើម្បីចូលរួមក្នុងសកម្មភាព អវប និងសន្សំក្រេឌីតបាន ត្រូវមានការអភិវឌ្ឍន៍ស្តង់ដានៃខ្លឹមសារ គុណភាព សមត្ថភាព និងលទ្ធផល ផលជះដែលអាចវាស់វែងបាន។ ការផ្តល់ក្រេឌីតសម្រាប់សកម្មភាព អវប គ្រប់ប្រភេទ



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ទាំងអស់ គឺអាស្រ័យទៅលើអ្នកចូលរួមក្នុងសកម្មភាព អវប បង្ហាញពីសមត្ថភាពសម្រេចបានតាមលក្ខណៈវិនិច្ឆ័យគុណភាព ។

### ៣.៣.១ កម្រិតលក្ខណៈវិនិច្ឆ័យ និងស្តង់ដា

សកម្មភាព អវប ត្រូវបានរៀបចំឡើងដើម្បីបំពេញទៅតាមតម្រូវការរបស់គ្រូបង្រៀន នាយកសាលា ឬអ្នកឯកទេសអប់រំ ដែលជាក្រុមគោលដៅសម្រាប់សកម្មភាពទាំងនេះ។ ការកំណត់លក្ខណៈវិនិច្ឆ័យលម្អិត ត្រូវធ្វើឡើងផ្អែកទៅតាមស្តង់ដាវិជ្ជាជីវៈដែលពាក់ព័ន្ធ និងក្រុមគោលដៅ។ បច្ចុប្បន្ន យើងមានស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនឆ្នាំ២០១០ និងស្តង់ដានាយកសាលាឆ្នាំ២០១៧ និងមិនទាន់មានស្តង់ដាវិជ្ជាជីវៈអ្នកឯកទេសអប់រំនៅឡើយ។ ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន និងស្តង់ដានាយកសាលាពុំបានបែងចែកកម្រិតឋានៈនីមួយៗដូចនៅក្នុងគន្លងអាជីពគ្រូបង្រៀន។ ក្រសួង អយក ត្រូវអភិវឌ្ឍស្តង់ដាវិជ្ជាជីវៈសម្រាប់អ្នកឯកទេសអប់រំ ចំពោះស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន និងស្តង់ដានាយកសាលា ត្រូវអភិវឌ្ឍលក្ខណៈវិនិច្ឆ័យសម្រាប់កម្រិតឋានៈនីមួយៗតាមលំនាំគន្លងអាជីពគ្រូបង្រៀន តាមលទ្ធភាពដែលអាចធ្វើទៅបាន (ឋានៈវិជ្ជាជីវៈគ្រូបង្រៀនមាននៅក្នុងគន្លងអាជីពគ្រូបង្រៀន)។ ការអភិវឌ្ឍលក្ខណៈវិនិច្ឆ័យ និងផ្តល់លទ្ធភាពឱ្យអ្នកចូលរួមសកម្មភាព អវប កំណត់លក្ខណៈវិនិច្ឆ័យគុណភាពបានសមស្របសម្រាប់សកម្មភាព អវប ដែលអ្នកមានអាជីពអប់រំត្រូវអនុវត្តតាមគន្លងអាជីពគ្រូបង្រៀន (គន្លងបង្រៀន គន្លងគ្រប់គ្រង គន្លងឯកទេសអប់រំ) នៅគ្រប់ដំណាក់កាលទាំងអស់នៃអាជីពរបស់ពួកគេ (សូមមើលចំណុច ២.១ ខាងលើ)។

ប្រព័ន្ធក្រេឌីត អវប ត្រូវអនុវត្តសម្រាប់បុគ្គលិកអប់រំនៅគ្រប់ដំណាក់កាលទាំងអស់នៃអាជីពរបស់ពួកគេ។ ដោយសារតែមិនទាន់មានស្តង់ដាវិជ្ជាជីវៈសម្រាប់គ្រប់ដំណាក់កាលទាំងអស់នៃគន្លងអាជីពនៅឡើយ និងដោយសារតែស្ថានភាពបច្ចុប្បន្នរបស់គ្រូបង្រៀននៅកម្ពុជា អាទិភាពចម្បងនៃប្រព័ន្ធ អវប គឺត្រូវផ្តល់លទ្ធភាពឱ្យគ្រូបង្រៀនឱ្យបានច្រើននាក់បំផុត អាចទទួលបានឋានៈ និងមានចំណេះដឹងជាគ្រូបង្រៀនដែលមានសមត្ថភាព ពោលគឺត្រូវមានសញ្ញាបត្របរិញ្ញាបត្រអប់រំ[5]។

### ៣.៣.២ ការកំណត់លក្ខណៈវិនិច្ឆ័យ អវប សម្រាប់ទទួលបានគុណវុឌ្ឍិកម្រិតបរិញ្ញាបត្រអប់រំ

លក្ខណៈវិនិច្ឆ័យដែលបង្ហាញខាងក្រោម ត្រូវបានរៀបចំឡើងផ្អែកតាមសមត្ថភាព និងកម្រិតបញ្ញាញាណចាំបាច់សម្រាប់គ្រូបង្រៀនម្នាក់ៗ ដែលមានសមត្ថភាពទទួលយកបាន ដូចមានក្នុងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនឆ្នាំ២០១០។ ស្តង់ដាទាំងនេះកំណត់ពីសមត្ថភាព និងសមិទ្ធកម្មក្នុងកម្រិតអប្បបរមា ដែលគ្រូបង្រៀនម្នាក់ៗត្រូវបង្ហាញឱ្យគេឃើញ ដើម្បីទទួលបានក្រេឌីត អវប។ ស្តង់ដាទាំងនេះមិនរៀបរាប់ ឬបែងចែកភាពខុសគ្នារវាងសមត្ថភាព និងសមិទ្ធកម្មលើកម្រិតចំណុចគោលកំណត់នេះឡើយ។ ស្តង់ដាទាំងនេះក៏ពុំបានលើកឡើងពីស្តង់ដាលក្ខណៈវិនិច្ឆ័យគុណភាពនៃសេវា អវប ដែលផ្តល់សម្រាប់គ្រូបង្រៀនដែលមានសញ្ញាបត្រចាប់ពីបរិញ្ញាបត្រអប់រំឡើងទៅនោះឡើយ។ សម្រាប់គ្រូបង្រៀនទាំងនេះ សកម្មភាព អវប ដែលជាលក្ខណៈវិនិច្ឆ័យគុណភាពនឹងត្រូវរៀបចំឡើងនៅក្នុងដំណាក់កាលទី២។

[5] ប្រព័ន្ធក្រេឌីត អវប នឹងត្រូវដាក់ឱ្យអនុវត្តដោយប្រើប្រាស់អភិក្រមជាដំណាក់ៗ។ ដំណាក់កាលទី១ រួមមាន ក្រេឌីត អវប មានរចនាសម្ព័ន្ធច្បាស់លាស់ និងការបង្កើតប្រព័ន្ធកំណត់ចំណុចដៅដែលមានលក្ខណៈសាមញ្ញ។ នៅដំណាក់កាលទី២ នឹងមានការផ្តល់ក្រេឌីត អវប រៀនដោយខ្លួនឯង និងបង្កើតប្រព័ន្ធកំណត់ចំណុចដៅដែលមានមហិច្ឆិតាដូចជា ប្រព័ន្ធសម្រាប់កំណត់ចំណុចដៅ និងការកំណត់ចំណុចសម្រាប់គ្រប់ដំណាក់កាលទាំងអស់នៃគន្លងទាំងបី ក្នុងគន្លងអាជីពគ្រូបង្រៀន។

### ៣.៣.២.១ ការកំណត់ចំណុចដៅអំពី អវប ដែលរួមចំណែកនាំឱ្យមានគុណវុឌ្ឍិកម្រិតបរិញ្ញាបត្រអប់រំ៖ ដំណាក់កាលទី១

នៅក្នុងដំណាក់កាលទី១ ប្រព័ន្ធក្រេឌីត អវប នឹងដាក់ឱ្យអនុវត្តនូវលក្ខណៈវិនិច្ឆ័យសាមញ្ញមួយ ផ្អែកតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនឆ្នាំ២០១០ ដែលត្រូវបានរៀបចំឡើងជុំវិញសមាសភាគចំនួន៣ គឺចំណេះដឹងវិជ្ជាជីវៈ ការអនុវត្តវិជ្ជាជីវៈ និងការសិក្សាវិជ្ជាជីវៈ។ នៅក្នុងដំណាក់កាលទី១ ដើម្បីទទួលបានការទទួលស្គាល់គុណភាពសម្រាប់សកម្មភាព អវប អ្នកផ្តល់សេវា អវប ត្រូវបង្ហាញឱ្យគេឃើញថា សកម្មភាពទាំងនេះនឹងជួយលើកកម្ពស់ចំណេះដឹង និងសមត្ថភាពវិជ្ជាជីវៈ ស្របតាមស្តង់ដាវិជ្ជាជីវៈពិតប្រាកដមែន។ ដើម្បីទទួលបានក្រេឌីត អវប គ្រូបង្រៀនត្រូវបង្ហាញថាពួកគេពិតជាបានបំពេញទៅតាមស្តង់ដាទាំងនេះ តាមរយៈការវាយតម្លៃ អវប លទ្ធផលរំពឹងទុក និងលទ្ធផលចុងក្រោយដែលសម្រេចបាន (សូមមើលប្រអប់ទី១ ខាងក្រោម)។

*ប្រអប់ទី១៖ លក្ខណៈវិនិច្ឆ័យគុណភាពសម្រាប់ អវប ដែលនាំឱ្យសាមីខ្លួនមានគុណវុឌ្ឍិកម្រិតបរិញ្ញាបត្រអប់រំ (ដំណាក់កាលទី១) ផ្អែកតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន*

**សមាសភាគទី១៖ ចំណេះដឹងវិជ្ជាជីវៈ**

សកម្មភាព អវប បង្កើនចំណេះដឹងគ្រូបង្រៀនតាមរយៈការបង្ហាញអំពី អនុសមាសភាគ ពណ៌នាស្តង់ដា និងសមត្ថភាពដូចខាងក្រោម៖

***ចំណេះដឹងអំពីសិស្ស***

**១.១ ស្គាល់សិស្ស** (ដឹងពីតម្រូវការសិក្សា សមត្ថភាព ប្រវត្តិសិក្សា និងឥរិយាបថសិក្សារបស់សិស្ស)

**១.២** ដឹងច្បាស់អំពី**ប្រភេទគ្រួសារ និងកត្តាផ្សេងៗ** (ឧ.យេនឌ័រ សាវតារសង្គមនិងសេដ្ឋកិច្ច ពិការភាព និងក្រុមជនជាតិដើមភាគតិច) ដែលមានឥទ្ធិពលដល់ការសិក្សារបស់សិស្ស និងដឹងពីរបៀបដោះស្រាយកត្តាទាំងនោះ។

***ចំណេះដឹងអំពីខ្លឹមសារមេរៀន***

**១.៣** យល់ដឹងពី**គោលនយោបាយអប់រំជាតិ** គោលដៅអប់រំជាតិ និងគោលបំណងអប់រំចំណេះទូទៅ

**១.៤** ដឹងពីទ្រឹស្តីនៃការសរសេរ**កិច្ចតែងការបង្រៀន**

**១.៥ យល់ដឹងពីខ្លឹមសារកម្មវិធីសិក្សា** ហើយមានសមត្ថភាពពន្យល់ និងបង្រៀនខ្លឹមសារមុខវិជ្ជា ដែលមានក្នុងកម្មវិធីសិក្សាបានល្អ

**១.៦** យល់ពីរបៀបបញ្ជ្រាប**ខ្លឹមសារពីមុខវិជ្ជាមួយទៅក្នុងមុខវិជ្ជាមួយទៀត** ក្នុងន័យឱ្យសិស្សទទួលបានបំណិនជាច្រើន និងមានចិត្តកាន់តែចង់រៀន។

***ដឹងពីការរៀនសូត្ររបស់សិស្ស***

**១.៧** យល់ដឹងពី**បរិស្ថានសិក្សានៅក្នុង**ថ្នាក់រៀន និងសហគមន៍

**១.៨** យល់ដឹងពី**របៀបរៀនរបស់សិស្ស**

**១.៩ យល់ដឹងពីភាពខុសប្លែកគ្នានៃសម្បទា** ល្បឿន និងរបៀបសិក្សារបស់សិស្ស។

**សមាសភាគទី២៖ ការប្រតិបត្តិវិជ្ជាជីវៈ**

សកម្មភាព អវប បង្កើនបំណិនវិជ្ជាជីវៈគ្រូបង្រៀនតាមរយៈការបង្ហាញអំពីអនុសមាសភាគ ពណ៌នាស្តង់ដា និងសមត្ថភាពដូចខាងក្រោម៖

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

*ការធ្វើផែនការ និងការពិនិត្យតាមដានវាយតម្លៃលទ្ធផលសិក្សា*

២.១ រៀបចំកិច្ចតែងការបង្រៀន កម្មវិធីបង្រៀន និងការវាយតម្លៃលទ្ធផលសិក្សាបានត្រឹមត្រូវ ហើយមានប្រសិទ្ធភាព

២.២ រៀបចំ**សម្ភារបង្រៀន និងរៀន** ដើម្បីឱ្យការសិក្សាសម្រេចបានលទ្ធផលល្អ

**២.៣ ប្រើប្រាស់វិធីសាស្ត្រសមស្របសម្បូរបែប សម្រាប់វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស**

២.៤ តាមដានការចូលរួម និងថែរក្សា**កំណត់ត្រានៃភាពរីកចម្រើនរបស់សិស្ស**

២.៥ **ផ្តល់ព័ត៌មានត្រឡប់ទៅសិស្ស មាតាបិតាឬអាណាព្យាបាលសិស្ស**អំពីការអភិវឌ្ឍចំណេះដឹង បំណិន និងឥរិយាបថរបស់សិស្ស

*ការគ្រប់គ្រងបរិស្ថានសិក្សា*

២.៦ ផ្តល់**បរិស្ថានសិក្សាដែលមានសុវត្ថិភាព** និងធ្វើឱ្យសិស្សទាំងអស់ខិតខំរៀនអស់ពីលទ្ធភាព

**២.៧ ជួយសិស្សឱ្យបង្កើនការទទួលខុសត្រូវចំពោះការសិក្សារបស់ខ្លួន**

២.៨ **ចូលរួមអភិវឌ្ឍសាលារៀន** ដើម្បីទ្រទ្រង់ការសិក្សា និងសុខុមាលភាពរបស់សិស្ស ព្រមទាំងសហសេវិក មិត្តរួមអាជីព

*វិធីបង្រៀន*

២.៩ ប្រើ**វិធីបង្រៀនផ្សេងៗ** ដើម្បីជួយសម្រួលការសិក្សារបស់សិស្ស និងសម្រេចតាមស្តង់ដាកម្មវិធីសិក្សារបស់ក្រសួង អយក

២.១០ **ផ្តល់មធ្យោបាយឱ្យស្រប ទៅតាមរបៀបសិក្សា និងតម្រូវការផ្សេងៗគ្នារបស់សិស្ស** តាមរយៈការអនុវត្តវិធីបង្រៀនសមស្រប និងសម្បូរបែប

២.១១ រៀបចំ និងផ្តល់ឱ្យសិស្សនូវឱកាសសិក្សាពី**ដំណោះស្រាយបញ្ហា ដើម្បីចូលរួមគិតឱ្យបានល្អិតល្អន់ និងដោយច្នៃប្រឌិត**

២.១២ **ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍** បើមាន ដើម្បីធ្វើឱ្យការបង្រៀន និងរៀនកាន់តែមានប្រសិទ្ធភាព

**សមាសភាគទី ៣៖ ការសិក្សាវិជ្ជាជីវៈ**

សកម្មភាព អវប លើកកម្ពស់ការសិក្សាវិជ្ជាជីវៈរបស់គ្រូបង្រៀនតាមរយៈការបង្ហាញអំពីអនុសមាសភាគ ពណ៌នាស្តង់ដា និងសមត្ថភាពដូចខាងក្រោម៖

*ស្វ័យសិក្សា*

៣.១ វាយតម្លៃការបង្រៀន ការអភិវឌ្ឍខ្លួន និងការប្រើប្រាស់**ផែនការ សម្រាប់ដឹកនាំស្វ័យសិក្សាវិជ្ជាជីវៈបានទៀងទាត់**

៣.២ អភិវឌ្ឍចំណេះដឹងបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ និងបំណិនសម្រាប់អនុវត្តក្នុងការបង្រៀន និងរៀន

៣.៣ ធ្វើឱ្យប្រសើរឡើងនូវបំណិនទំនាក់ទំនងជាមួយសិស្ស មាតាបិតា មិត្តរួមអាជីព និងសហគមន៍

*ចូលរួមក្នុងការកែលម្អការបង្រៀន*

៣.៤ អានអត្ថបទវិជ្ជាជីវៈគ្រូបង្រៀន និងស្រាវជ្រាវ ដើម្បីពង្រីកចំណេះដឹងឱ្យបានទូលំទូលាយ ក្នុងន័យធ្វើឱ្យការបង្រៀនកាន់តែប្រសើរឡើង

៣.៥ ធ្វើអន្តរកម្មជាមួយគ្រូបង្រៀនដទៃទៀត ក្នុងសកម្មភាពសិក្សាវិជ្ជាជីវៈ។

### ៣.៣.២.២ ការកំណត់ពីចំណុចដៅ អវប ដែលរួមចំណែកដល់ការបង្កើនគុណវុឌ្ឍិដល់កម្រិតបរិញ្ញាបត្រអប់រំ៖ ដំណាក់កាលទី២

នៅក្នុងដំណាក់កាលទី២ ប្រព័ន្ធក្រេឌីត អវប នឹងកំណត់ពីចំណុចដៅសកម្មភាព អវប សម្រាប់គ្រូបង្រៀន ដែលមានគោលបំណងបង្កើនគុណវុឌ្ឍិដល់កម្រិតបរិញ្ញាបត្រអប់រំ និងឈានទៅបង្កើតប្រព័ន្ធ អវប ដែលមានភាពរីកចម្រើនផ្អែកទៅតាមលទ្ធផលរំពឹងទុក ដើម្បីធ្វើឱ្យគ្រូបង្រៀនមានសមត្ថភាពដូចគ្រូបង្រៀននៅក្នុងបណ្ដាប្រទេសជឿនលឿន។ ស្តង់ដាលក្ខណៈវិនិច្ឆ័យគុណភាពត្រូវបានកំណត់សម្រាប់សមត្ថភាពចំនួន៤ ដែលមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក៖

- ចំណេះដឹង និងការយល់ដឹង (ចំណេះដឹងខ្លឹមសារជាក់លាក់ និងចំណេះដឹងដែលពាក់ព័ន្ធនឹងការអនុវត្ត)
- ការអនុវត្តគោលការណ៍សំខាន់ៗពាក់ព័ន្ធនឹងបរិបទ
- បំណិនក្នុងការឆ្លុះបញ្ចាំងលើបញ្ហាសំខាន់ៗ
- បំណិនសតវត្សរ៍ទី ២១ (បំណិនទន់)

នៅក្នុងដំណាក់កាលទី២ ដើម្បីឱ្យសកម្មភាព អវប មានការទទួលស្គាល់គុណភាព អ្នកផ្ដល់សេវា អវប ត្រូវបង្ហាញថា សកម្មភាពរបស់ខ្លួនពិតជាអាចលើកកម្ពស់ចំណេះដឹង និងសមត្ថភាពវិជ្ជាជីវៈ ស្របតាមសមត្ថភាពទាំង៤ ខាងលើ។ ដើម្បីទទួលបានក្រេឌីត អវប គ្រូបង្រៀនត្រូវបង្ហាញពីការវាយតម្លៃ អវប លទ្ធផល និងផលជះដែលឆ្លើយតបទៅនឹងសមត្ថភាពដូចខាងក្រោម (សូមមើលប្រអប់ទី២ ខាងក្រោម)។

*ប្រអប់ទី ២៖ លក្ខណៈវិនិច្ឆ័យ អវប សម្រាប់កម្រិតបរិញ្ញាបត្រអប់រំ (ដំណាក់កាលទី២)*

**១. ចំណេះដឹង និងការយល់ដឹង**

សកម្មភាព អវប ផ្ដល់ឱ្យគ្រូបង្រៀននូវសមត្ថភាពដូចខាងក្រោម ៖

១.១ ចំណេះដឹងអំពីខ្លឹមសារជាក់លាក់ (បញ្ញត្តិ រូបមន្ត គោលការណ៍...) ដែលត្រូវបានកំណត់ថា ជាចំណេះដឹងអំពីមុខវិជ្ជា និងរចនាសម្ព័ន្ធរបស់មុខវិជ្ជានោះ

១.២ ចំណេះដឹងគរុកោសល្យ ឬការអនុវត្ត (ចំណេះដឹងរបស់អ្នកអនុវត្ត ចំណេះដឹងអំពីនីតិវិធី ដឹងពីរបៀប) ដើម្បីប្រែក្លាយចំណេះដឹងអំពីខ្លឹមសារជាក់លាក់ សម្រាប់អនុវត្តនៅក្នុងបរិបទនៃការបង្រៀន

១.៣ ការចូលរួមវិភាគ និងត្រិះរិះពិចារណាក្នុងដំណើរការអប់រំ ផ្ដល់លទ្ធភាពឱ្យមានការឆ្លុះបញ្ចាំងល្អិតល្អន់អំពីគោលវិធី និងទស្សនៈយល់ឃើញខុសៗគ្នាអំពីបញ្ហាអប់រំដូចជា គោលវិធីពហុមុខវិជ្ជាជាដើម

១.៤ ការយល់ដឹងពីទស្សនាទានអប់រំថ្មីៗ និងគោលវិធីអប់រំផ្អែកតាមទ្រឹស្ដី

១.៥ ឱកាសវាយតម្លៃ និងចោទសួរយ៉ាងល្អិតល្អន់ពីដំណើរការអប់រំ និងចូលរួមនៅក្នុងការជជែកវែកញែកអំពីដំណើរការទាំងនេះ

១.៦ ឱកាសប្រើប្រាស់ការស្រាវជ្រាវថ្មីៗ និងឯកសារស្រាវជ្រាវអប់រំដែលពាក់ព័ន្ធដទៃទៀត រួមនឹងការប្រមូលទិន្នន័យពីប្រភពទិន្នន័យទី១ មួយចំនួន

១.៧ ឱកាសធ្វើការវិភាគ និងវាយតម្លៃគោលនយោបាយអប់រំ និងការអនុវត្តប្រកបដោយភាពល្អិតល្អន់ក្នុងលក្ខណៈជាប្រព័ន្ធ

១.៨ ឱកាសពង្រីកការយល់ដឹងផ្ទាល់ខ្លួន ដើម្បីអនុវត្តគោលការណ៍ និងចំណេះដឹងថ្មីៗ

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

១.៩ ខ្លឹមសារ អវប ដែលផ្តល់ជូន ត្រូវផ្តោតលើចំណុចដូចខាងក្រោម៖

ក) ដំណើរការអប់រំ និងភាពពាក់ព័ន្ធក្នុងថ្នាក់រៀន និងការអនុវត្ត

ខ) ភាពពាក់ព័ន្ធសម្រាប់គោលនយោបាយ អប់រំ និងការអនុវត្តគោលនយោបាយទាំងនេះ ក្នុងបរិបទវប្បធម៌ នយោបាយ ទស្សនវិជ្ជា ប្រវត្តិសាស្ត្រ បច្ចេកវិទ្យា និងសេដ្ឋកិច្ច

គ) ការយល់ដឹងពីប្រព័ន្ធអប់រំរបស់ខ្លួន និងប្រព័ន្ធអប់រំផ្សេងទៀត តាមរយៈការសន្មត និងគុណតម្លៃ។

**២. ការអនុវត្ត**

សកម្មភាព អវប លើកទឹកចិត្តគ្រូបង្រៀនឱ្យបង្ហាញពីសមត្ថភាពដូចខាងក្រោម៖

២.១ ធ្វើការវិភាគក្នុងលក្ខណៈជាប្រព័ន្ធស្តីពីទស្សនាទានអប់រំ ទ្រឹស្តី និងបញ្ហាគោលនយោបាយដែលពាក់ព័ន្ធនឹងការអប់រំ

២.២ ឆ្លុះបញ្ចាំងពីទំនាក់ទំនងរវាងចំណេះដឹងមុខវិជ្ជា និងការអនុវត្តនៅក្នុងគោលនយោបាយ និងបរិបទអប់រំ ដូចជាភាពមិនប្រទាក់ក្រឡាគ្នាជាដើម

២.៣ សម្របតាមគោលការណ៍ និងការយល់ដឹងថ្មីៗ

២.៤ ប្រមូលភស្តុតាងឱ្យបានច្រើនប្រភេទ រួមទាំងភស្តុតាងដែលបានពីប្រភពទិន្នន័យទី១ និងប្រភពទិន្នន័យទី២ ពាក់ព័ន្ធ ដើម្បីអភិវឌ្ឍចំណេះដឹង និងការយល់ដឹង

២.៥ ប្រើប្រាស់ភស្តុតាងទាំងនេះ ដើម្បីរៀបចំផែនការ និងជួយឱ្យមានការផ្លាស់ប្តូរនៅក្នុងការអនុវត្ត

២.៦ អនុវត្តទ្រឹស្តី និងទស្សនាទានស្តីពីការអប់រំក្នុងថ្នាក់រៀន និងក្នុងបរិបទអប់រំដទៃទៀត

២.៧ សកម្មភាព អវប គួរបង្ហាញឱ្យឃើញពីវិធីសាស្ត្រ និងគោលវិធីសម្រាប់ធ្វើការស្រាវជ្រាវ ដែលជាមូលដ្ឋានសម្រាប់ការយល់ដឹង និងការស្រាវជ្រាវអប់រំ។

**៣. ការឆ្លុះបញ្ចាំង**

សកម្មភាព អវប ផ្តល់ឱកាសដល់គ្រូបង្រៀន ៖

៣.១ ឆ្លុះបញ្ចាំងពីការរៀនសូត្រ ការយល់ដឹង ការអភិវឌ្ឍ និងការអនុវត្ត

៣.២ បញ្ចូលទៅក្នុងទស្សនាទានស្តីពីការអនុវត្ត និងទ្រឹស្តីដែលបានសិក្សា អនុវត្តសាកល្បងទស្សនាទាន និងទ្រឹស្តីទាំងនេះធៀបនឹងបទពិសោធន៍ផ្ទាល់ខ្លួន

៣.៣ ស្វែងយល់ និងវិភាគល្អិតល្អន់លើទ្រឹស្តី និងការស្រាវជ្រាវផ្អែកទៅតាមបទពិសោធន៍ផ្ទាល់ខ្លួន។

***៤. ជំនាញសតវត្សរ៍ទី២១ ឬបំណិនទន់ ៖*** ជាជំនាញមួយដែលទាក់ទងទៅនឹងការសិក្សាអប់រំ ហើយវាពាក់ព័ន្ធទៅនឹងសមត្ថភាព៣ ផ្សេងទៀត ដូចជាចំណេះដឹងនិងការយល់ដឹង ការអនុវត្ត និងការឆ្លុះបញ្ចាំង។ សកម្មភាព អវប ត្រូវផ្តល់ឱកាសឱ្យគ្រូបង្រៀនអភិវឌ្ឍជំនាញដូចខាងក្រោម៖

៤.១ **ការប្រាស្រ័យទាក់ទង និងការធ្វើបទបង្ហាញ៖** ប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាព ទាំងក្នុងទម្រង់ជាសំណេរ ទម្រង់ជាការនិយាយ ដោយរៀបចំគោលជំហរនិងអំណះអំណាង និងប្រើប្រាស់ពាក្យបច្ចេកទេសឱ្យបានសមស្រប

៤.២ **បច្ចេកវិទ្យា៖** ប្រើប្រាស់បច្ចេកវិទ្យាដែលពាក់ព័ន្ធ និងកម្មវិធីកុំព្យូទ័រសម្រាប់ការអប់រំ យ៉ាងមានប្រសិទ្ធភាព ដើម្បីគាំទ្រដល់ការងាររបស់ខ្លួន និងដើម្បីបង្កើនការសិក្សាដែលមានលក្ខណៈឆ្លុះបញ្ចាំង និងស៊ីជម្រៅ

៤.៣ **ការអនុវត្តបំណិនលេខនព្វន្ត៖** យល់ដឹង និងផ្តល់ព័ត៌មានអំពីលេខនព្វន្តប្រកបដោយប្រសិទ្ធភាព និង

សុក្រឹតភាពដូចជា ការប្រមូលនិងការប្រើប្រាស់ទិន្នន័យលេខនព្វន្តយ៉ាងសមស្រប ធ្វើការវិភាគទិន្នន័យបែបគុណវិស័យនិងបរិមាណវិស័យ និងបង្ហាញទិន្នន័យក្នុងទម្រង់សមស្រប

៤.៤ **ធ្វើការជាមួយនឹងអ្នកដទៃទៀត៖** ចូលរួមការងារក្រុមប្រកបដោយប្រសិទ្ធភាព និងការសហការគ្នាដូចជាការធ្វើផែនការ ការបែងចែកការទទួលខុសត្រូវ និងធ្វើការដឹកនាំក្នុងករណីដែលសមស្រប

៤.៥ **លើកកម្ពស់ការសិក្សា និងសមិទ្ធកម្មផ្ទាល់ខ្លួន៖** អភិវឌ្ឍជំនាញសិក្សា ស្រាវជ្រាវ និងធ្វើផែនការ ដូចជារៀបចំផែនការការងារ ធ្វើការងារទៅតាមពេលកំណត់ និងឆ្លុះបញ្ចាំងពីសមិទ្ធកម្មនិងការរៀនសូត្រផ្ទាល់ខ្លួនដើម្បីធ្វើការកែលម្អ

៤.៦ **បំណិនវិភាគ និងដោះស្រាយបញ្ហា៖** វិភាគលើព័ត៌មាន រកឱ្យឃើញ និងវាយតម្លៃដំណោះស្រាយដែលសមស្រប

៤.៧ **សម្របខ្លួនទៅតាមការផ្លាស់ប្តូរ៖** បង្ហាញពីការឆ្លើយតបទៅនឹងបរិស្ថានដែលមានការផ្លាស់ប្តូរ។

ការកំណត់លក្ខណៈវិនិច្ឆ័យ នឹងសម្រេចបានតាមរយៈការបញ្ចូលគ្នានូវបែបបទនៃទទួលស្គាល់គុណភាពវគ្គបណ្តុះបណ្តាល និងអ្នកផ្តល់សេវា (ដោយការិយាល័យគ្រប់គ្រង អវប នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ) និងត្រូវផ្ទៀងផ្ទាត់សមត្ថភាពនីមួយៗក្នុងដំណើរការវាយតម្លៃ។

### ៣.៣.៣ ការកំណត់លក្ខណៈវិនិច្ឆ័យ អវប សម្រាប់នាយកសាលា

លក្ខណៈវិនិច្ឆ័យគុណភាព អវប (*Benchmark*) ដែលបង្ហាញខាងក្រោម ត្រូវបានរៀបចំឡើង ផ្អែកតាមសមត្ថភាព និងកម្រិតបញ្ញាចាំបាច់សម្រាប់នាយកសាលា ដែលមានសមត្ថភាពទទួលយកបាន ដូចមានក្នុងស្តង់ដានាយកសាលាឆ្នាំ២០១៧។ ស្តង់ដាទាំងនេះកំណត់ពីកម្រិតអប្បបរមានៃសមត្ថភាព និងសមិទ្ធកម្ម ដែលនាយកសាលាត្រូវបង្ហាញឱ្យឃើញដើម្បីទទួលបានក្រេឌីត អវប ដែលពាក់ព័ន្ធ។ ស្តង់ដាទាំងនេះមិនរៀបរាប់ឬបែងចែកភាពខុសប្លែកគ្នារវាងកម្រិតសមត្ថភាព និងសមិទ្ធកម្មលើសពីកម្រិតកំណត់នេះឡើយ។ ស្តង់ដាទាំងនេះក៏ពុំបានលើកឡើងពីលក្ខណៈវិនិច្ឆ័យគុណភាពដែលសកម្មភាព អវប ផ្តល់ជូននាយកសាលាដែលមានសញ្ញាបត្រក្រោយឧត្តមសិក្សាឬមានគុណវុឌ្ឍិខ្ពស់ជាងនេះខាងផ្នែកដឹកនាំនិងគ្រប់គ្រងសាលារៀននោះឡើយ ហើយសម្រាប់អ្នកដែលមានគុណវុឌ្ឍិកម្រិតខ្ពស់ទាំងនេះ នឹងមានការរៀបចំសកម្មភាព អវប ឱ្យបានសមស្របក្នុងពេលឆាប់ៗនេះ។

បន្ថែមលើលក្ខណៈវិនិច្ឆ័យផ្អែកតាមស្តង់ដានាយកសាលា គេរំពឹងថានាយកសាលានឹងបង្ហាញពីសមត្ថភាពដូចគ្នានឹងគ្រូបង្រៀនផងដែរដូចជា៖

- ចំណេះដឹង និងការយល់ដឹង (ចំណេះដឹងខ្លឹមសារជាក់លាក់ និងចំណេះដឹងដែលពាក់ព័ន្ធនឹងការអនុវត្ត)
- ការអនុវត្តគោលការណ៍សំខាន់ៗពាក់ព័ន្ធនឹងបរិបទ
- បំណិនក្នុងការឆ្លុះបញ្ចាំងលើបញ្ហាសំខាន់ៗ
- បំណិនសតវត្សរ៍ទី២១ (បំណិនទន់)
    - ការប្រាស្រ័យទាក់ទង និងការធ្វើបទបង្ហាញ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- ○ បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍
- ○ ការអនុវត្តបំណិនលេខនព្វន្ត
- ○ ការធ្វើការងារជាមួយអ្នកដទៃ
- ○ ការបង្កើនការរៀនសូត្រ និងសមិទ្ធកម្មផ្ទាល់ខ្លួន
- ○ បំណិនវិភាគ និងដោះស្រាយបញ្ហា
- ○ ការសម្របខ្លួនទៅតាមការផ្លាស់ប្តូរ

នាយកសាលាត្រូវបង្ហាញពីចំណេះដឹងខ្លឹមសារ និងចំណេះដឹងអំពីការអនុវត្តស្របតាមស្តង់ដានាយកសាលាដូចខាងក្រោម ៖

- សាវតារ និងលក្ខណៈរបស់នាយកសាលា (ស្តង់ដាទី២៖ សមត្ថភាព និងគុណសម្បត្តិរបស់នាយកសាលា)៖
  - ○ ចំណេះដឹង និងការគោរពតាមក្រមសីលធម៌វិជ្ជាជីវៈ
  - ○ ភាពជាដឹកនាំ និងការគ្រប់គ្រង
- ការគ្រប់គ្រងការបង្រៀន និងរៀន(ស្តង់ដាទី៥៖ ភាពជាអ្នកដឹកនាំលើកម្មវិធីសិក្សា ការបង្រៀន និងរៀន)
  - ○ ផ្តល់ការគាំទ្រ ការណែនាំ និងការប្រឹក្សាគរុកោសល្យ
  - ○ កម្មវិធីសិក្សា ស្តង់ដាកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល
  - ○ ផែនការបង្រៀន និងកិច្ចតែងការបង្រៀន
  - ○ វិធីសាស្ត្របង្រៀន (គោលវិធីសិស្សមជ្ឈមណ្ឌល ការបង្រៀននិងរៀនតាមបែបរិះរក ការប្រើប្រាស់សំណួរ)
  - ○ គរុកោសល្យដែលឆ្លើយតបទៅនឹងតម្រូវការរបស់សិស្សម្នាក់ៗ (គាំទ្រដល់សិស្សដែលមានតម្រូវការអប់រំពិសេស និងរៀនយឺត)
  - ○ ខ្លឹមសារកម្មវិធីសិក្សា (ការអប់រំបច្ចេកទេស អំណាន និងគណិតវិទ្យាសម្រាប់កម្រិតដំបូងៗ)
  - ○ ការវាយតម្លៃការសិក្សា (ការវាយតម្លៃក្នុងដំណើរការសិក្សា និងការវាយតម្លៃចុងបញ្ចប់ ការវាយតម្លៃជាប្រចាំ ការកត់ត្រាភាពជឿនលឿន ការរៀបចំតេស្តនៅកម្រិតសាលារៀន)
  - ○ ប្រព័ន្ធវាយតម្លៃនៅកម្រិតសាលារៀននិងថ្នាក់រៀន
- បំណិនត្រិះរិះពិចារណា និងនវានុវត្តន៍ (ស្តង់ដាទី៣៖ បំណិនត្រិះរិះពិចារណា និងនវានុវត្តន៍)
  - ○ ចំណេះដឹង ចក្ខុវិស័យ និងការយល់ដឹងពីគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ
  - ○ សមត្ថភាពអនុវត្ត និងគ្រប់គ្រងផែនការសកម្មភាព
  - ○ សមត្ថភាពពិនិត្យ និងវាយតម្លៃលើផែនការសកម្មភាព
- ការគ្រប់គ្រងរដ្ឋបាល (ស្តង់ដាទី៤៖ ភាពជាអ្នកដឹកនាំគ្រប់គ្រងរដ្ឋបាលសាលារៀន)
  - ○ ការគ្រប់គ្រងសាលារៀន និងភាពជាអ្នកដឹកនាំ (តួនាទី និងភារកិច្ចរបស់នាយកសាលា)
  - ○ អភិបាលកិច្ចសាលារៀន (ភាពជាពលរដ្ឋសកល យេនឌ័រនិងការអភិវឌ្ឍសាលារៀន សុខភាព និងការអប់រំ)
  - ○ គោលនយោបាយ និងយន្តការសាលារៀន (គណៈកម្មាការគ្រប់គ្រងសាលារៀន ការធ្វើអធិការកិច្ច

នៅក្នុងសាលារៀន ស្វ័យវាយតម្លៃសាលារៀន)
  - ស្តង់ដាសាលារៀន
  - ផែនការអភិវឌ្ឍន៍សាលារៀន (ផែនការកែលម្អសាលារៀន)
  - ការគ្រប់គ្រងផ្អែកតាមលទ្ធផល
- ការគ្រប់គ្រងហិរញ្ញវត្ថុ (ស្តង់ដាទី៤៖ ភាពជាអ្នកដឹកនាំគ្រប់គ្រងរដ្ឋបាលសាលារៀន)
  - មូលនិធិដំណើរការសាលារៀន
- ការគ្រប់គ្រងបុគ្គលិក (ស្តង់ដា ៤/៥)
  - ក្របខណ្ឌគ្រប់គ្រងបុគ្គលិក
  - ប្រព័ន្ធគ្រប់គ្រងសមិទ្ធកម្ម
  - គាំទ្រដល់ អវប របស់គ្រូបង្រៀន (ការរៀបចំផែនការ អវប ការកំណត់សកម្មភាព អវប ការសិក្សាស្រាវជ្រាវមេរៀន ការស្រាវជ្រាវប្រតិបត្តិ សហគមន៍សិក្សាវិជ្ជាជីវៈ)
  - ការវាយតម្លៃ
- ការកសាងបណ្តាញ និងទំនាក់ទំនង (ស្តង់ដាទី ៦៖ ការផ្សារភ្ជាប់សាលារៀន និងសហគមន៍)
  - ទំនាក់ទំនងរវាងសាលារៀនជាមួយនឹងសហគមន៍ អាជ្ញាធរ និងវិស័យឯកជន
  - ទំនាក់ទំនងរវាងសាលារៀនជាមួយនឹងមាតាបិតាសិស្ស អ្នកអាណាព្យាបាល ដើម្បីបង្កើនការចូលរួម

## ៣.៤ ការវាយតម្លៃលើសកម្មភាព អវប

### ៣.៤.១ ការវាយតម្លៃលើសកម្មភាព អវប របស់គ្រូបង្រៀន

- ការវាយតម្លៃ ១៥% លើសកម្មភាព អវប មានរចនាសម្ព័ន្ធច្បាស់លាស់ គឺគិតទៅតាមវត្តមាន និងការគោរពពេលវេលា
- ការវាយតម្លៃលើសកម្មភាព អវប ត្រូវមានលក្ខណៈនវានុវត្តន៍ រួមមានការផ្តល់ព័ត៌មានត្រឡប់ជាបណ្តើរៗដើម្បីជួយដល់ការរៀនសូត្រ និងការអភិវឌ្ឍរបស់គ្រូបង្រៀន។ កិច្ចការនានាត្រូវបានរៀបចំឡើងដើម្បីផ្តល់ឱកាសឱ្យគ្រូបង្រៀន បង្ហាញសមត្ថភាព ចំណេះដឹង និងការយល់ដឹងទូលំទូលាយ និងត្រូវមានការប្រើប្រាស់វិធីសាស្ត្រវាយតម្លៃសមស្របឱ្យបានច្រើនយ៉ាងដូចជា៖
  - ការសរសេររបាយការណ៍
  - ការធ្វើបទបង្ហាញផ្ទាល់ ឬតាមរយៈវីដេអូ
  - ឯកសារកម្មវិធីសិក្សា ឬឯកសារគរុកោសល្យ ដែលមានសេចក្តីផ្តើមបង្ហាញពីក្របខណ្ឌទ្រឹស្តី
  - កម្រងស្នាដៃដែលបង្ហាញពីលទ្ធផល
  - របាយការណ៍ស្រាវជ្រាវ ឬរបាយការណ៍ការស្រាវជ្រាវប្រតិបត្តិ
- កិច្ចការនានា ត្រូវបង្ហាញពីសមត្ថភាពផ្សារភ្ជាប់ចំណេះដឹង ទ្រឹស្តី និងភស្តុតាងស្រាវជ្រាវ ហើយត្រូវបញ្ចូលទាំងសកម្មភាពទ្រឹស្តី និងសកម្មភាពអនុវត្ត
- សកម្មភាព អវប ត្រូវបង្ហាញពីលទ្ធផល និងផលជះ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

**ការបង្ហាញពីលទ្ធផល**

- ការវាយតម្លៃលើសកម្មភាព អវប ត្រូវយកចិត្តទុកដាក់លើការបង្ហាញរបស់គ្រូបង្រៀនអំពីសមាសភាគ៤ ដូចខាងក្រោម៖
    - ចំណេះដឹង និងការយល់ដឹង
    - ការអនុវត្តគោលការណ៍សំខាន់ៗក្នុងបរិបទពាក់ព័ន្ធ
    - បំណិនក្នុងការឆ្លុះបញ្ចាំងលើបញ្ហាសំខាន់ៗ
    - បំណិនសតវត្សរ៍ទី២១ (បំណិនទន់)

**ការបង្ហាញពីផលជះ:**

- ការវាយតម្លៃលើសកម្មភាព អវប ត្រូវផ្ដោតលើការបង្ហាញរបស់គ្រូបង្រៀន ដើម្បីបញ្ជាក់ឱ្យដឹងថាពិតជាបានយកចំណេះដឹង និងការយល់ដឹងដែលទទួលបានពីការចូលរួម អវប ទៅអនុវត្តក្នុងការងារបង្រៀនដែលនាំមកនូវការផ្លាស់ប្ដូរបែបវិជ្ជមានក្នុងសកម្មភាពវិជ្ជាជីវៈ៖
    - បង្ហាញថាពិតជាបានចូលរួមយ៉ាងសកម្មប្រកបដោយការគិតនិងវិភាគយ៉ាងល្អិតល្អន់ជាមួយនឹងចំណេះដឹង ដែលពួកគេទទួលបានពីសកម្មភាព អវប មានរចនាសម្ព័ន្ធច្បាស់លាស់ ឬរៀនដោយខ្លួនឯង
    - អនុវត្តចំណេះដឹងដើម្បីដោះស្រាយបញ្ហា ឬបញ្ហាប្រឈមដែលបានរកឃើញនៅក្នុងការប្រតិបត្តិវិជ្ជាជីវៈរបស់ខ្លួន បង្ហាញពីសមត្ថភាពក្នុងការពិចារណាពីស្ថានភាពដែលកើតមានជាក់ស្ដែងក្នុងក្របខណ្ឌទ្រឹស្ដី
    - វាយតម្លៃពីផលជះ បង្ហាញពីសមត្ថភាពវិភាគពីការផ្លាស់ប្ដូរកើតមានជាក់ស្ដែងនៅក្នុងក្របខណ្ឌទ្រឹស្ដីដែលត្រូវបានជ្រើសរើសយកមកប្រើប្រាស់។

### ៣.៤.២ ការវាយតម្លៃលើសកម្មភាព អវប សម្រាប់នាយកសាលា

លក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃសកម្មភាព អវប សម្រាប់នាយកសាលា បញ្ចូលលក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃគ្រូបង្រៀន ដូចរៀបរាប់ខាងលើដែរ៖

- ការវាយតម្លៃ ១៥% លើសកម្មភាព អវប មានរចនាសម្ព័ន្ធច្បាស់លាស់ គឺគិតទៅតាមវត្តមាន និងការគោរពពេលវេលា
- ការវាយតម្លៃលើសកម្មភាព អវប ត្រូវមានលក្ខណៈនវានុវត្តន៍ រួមមានការផ្ដល់ព័ត៌មានត្រឡប់ជាបណ្ដើរៗដើម្បីជួយដល់ការរៀនសូត្រ និងការអភិវឌ្ឍរបស់នាយកសាលា។ កិច្ចការនានាត្រូវបានរៀបចំឡើងដើម្បីផ្ដល់ឱកាសឱ្យនាយកសាលា បង្ហាញសមត្ថភាព ចំណេះដឹង និងការយល់ដឹងទូលំទូលាយ
- កិច្ចការនានា ត្រូវបង្ហាញពីសមត្ថភាពផ្សារភ្ជាប់ចំណេះដឹង ទ្រឹស្ដី និងភស្ដុតាងស្រាវជ្រាវ ហើយត្រូវបញ្ចូលទាំងសកម្មភាពទ្រឹស្ដី និងសកម្មភាពអនុវត្ត
- សកម្មភាព អវប ត្រូវបង្ហាញពីលទ្ធផល និងផលជះ។

លើសពីនេះការវាយតម្លៃសកម្មភាព អវប របស់នាយកសាលាត្រូវបង្ហាញឱ្យឃើញពីសមត្ថភាពដូចខាងក្រោម៖

- ធ្វើការវិភាគរកបញ្ហាដែលកើតមានជាក់ស្តែង និងយកបញ្ហានេះទៅធ្វើការស្រាវជ្រាវអប់រំ ឬសិក្សាពីឯកសារស្រាវជ្រាវ
- រៀបចំផែនការសកម្មភាពសម្រាប់សាលារៀនរបស់ខ្លួនដោយប្រើប្រាស់ការស្រាវជ្រាវ ឬឯកសារស្រាវជ្រាវ និងឧទាហរណ៍ដែលបង្ហាញពីឧត្តមានុវត្តន៍ពីប្រទេសផ្សេងទៀត
- អនុវត្តផែនការសកម្មភាពនៅក្នុងសាលារៀនរបស់ខ្លួន
- ពិនិត្យតាមដាន និងរាយការណ៍ពីផលប៉ះពាល់នៃផែនការសកម្មភាពរបស់ខ្លួន រួចធ្វើការវាយតម្លៃលើកម្រិតនៃការផ្លាស់ប្តូរដែលសង្កេតឃើញ

### ៣.៥ អ្នកផ្តល់សេវា អវប និងការទទួលស្គាល់គុណភាព

ការិយាល័យគ្រប់គ្រង អវប សហការជាមួយនាយកដ្ឋានពាក់ព័ន្ធ រៀបចំវាយតម្លៃទទួលស្គាល់គុណភាពអ្នកផ្តល់សេវា អវប។ ក្របខណ្ឌ និងផែនការសកម្មភាព អវប បញ្ជាក់យ៉ាងច្បាស់ថា ស្ថង់ដាគ្រឹះស្ថានអប់រំគ្រូបង្រៀននឹងត្រូវធ្វើការកែលម្អឱ្យស្របតាមគោលបំណងនេះ (ទំព័រទី១៩)។ អ្នកផ្តល់សេវា អវប ដូចជា គ្រឹះស្ថានអប់រំគ្រូបង្រៀន នាយកដ្ឋានជំនាញដែលស្ថិតក្រោមចំណុះក្រសួងអប់រំ យុវជន និងកីឡា ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល និងអាចជាបុគ្គលឬស្ថាប័នឯកជនមួយចំនួន អាចដាក់ពាក្យស្នើសុំជាអ្នកផ្តល់សេវា អវប ដែលមានការស្គាល់គុណភាព មកកាន់ការិយាល័យគ្រប់គ្រង អវប។ ប្រព័ន្ធ HRMIS មានបញ្ជីអ្នកផ្តល់សេវា អវប ដែលត្រូវបានទទួលស្គាល់គុណភាព និងលក្ខណៈសម្បត្តិរបស់អ្នកផ្តល់សេវា រួមនឹងបញ្ជីសកម្មភាព អវប។ សម្រាប់ព័ត៌មានបន្ថែមអំពីការវាយតម្លៃទទួលស្គាល់គុណភាព អ្នកផ្តល់សេវា អវប សូមមើលសៀវភៅណែនាំស្តីពី អវប ។

## ៤. ការប្រើប្រាស់ក្រេឌីត អវប

ក្រេឌីត អវប អាចរួមចំណែកដល់ការទទួលបានគុណវុឌ្ឍិឬការដំឡើងគុណវុឌ្ឍិ និងការឡើងឋានៈវិជ្ជាជីវៈនៅក្នុងគន្លងអាជីពគ្រូបង្រៀន។

ក្រេឌីត អវប ជាផ្នែកមួយនៃលទ្ធផលការវាយតម្លៃតាមវដ្តទៀងទាត់ ដែលអ្នកវាយតម្លៃអាចទាញយកពិន្ទុពីប្រព័ន្ធ HRMIS ក្នុងគោលបំណងវាយតម្លៃ។

### ៤.១ ក្រេឌីត អវប រួមចំណែកដំឡើងគុណវុឌ្ឍិ និងកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀន

ដូចបង្ហាញនៅក្នុងតារាងទី៣ ដើម្បីបញ្ចប់កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនប្រកបដោយជោគជ័យ និងទទួលបានបរិញ្ញាបត្រអប់រំ គរុនិស្សិតត្រូវមានយ៉ាងតិច ១២០ក្រេឌីត ដោយត្រូវបែងចែកក្រេឌីតទាំងនេះទៅតាមមុខវិជ្ជាសិក្សាដូចខាងក្រោម៖

1. ការសិក្សាពីការអប់រំ (ការសិក្សាគរុកោសល្យ)
2. ចំណេះដឹងមុខវិជ្ជាឯកទេស (មត្តេយ្យសិក្សា និងបឋមសិក្សា) ខ្លឹមសារមុខវិជ្ជាដែលសិក្សានៅតាមសាលារៀន (មធ្យមសិក្សាមបឋមភូមិ)
3. ការសិក្សាពីកម្មវិធីសិក្សា (វិធីសាស្ត្របង្រៀនដែលផ្សារភ្ជាប់ជាមួយនឹងមុខវិជ្ជាដែលសិក្សានៅតាមសាលារៀន)

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

4. ការលើកកម្ពស់ផ្នែកភាសាបរទេស (ការសរសេរសម្រាប់គោលបំណងសិក្សា ការអាន ការធ្វើបទបង្ហាញ) ជាភាសាបរទេស (អង់គ្លេស ឬបារាំង)
5. ការស្រាវជ្រាវអប់រំ (ទ្រឹស្តី និងការអនុវត្តការស្រាវជ្រាវសម្រាប់ការសិក្សា)
6. កម្មសិក្សាគរុកោសល្យ (ការអនុវត្តការបង្រៀន)
7. វគ្គសិក្សាដែលសំខាន់ និងចាំបាច់ (ប្រធានបទ ឬខ្លឹមសារពាក់ព័ន្ធនឹងការបង្រៀន)

កម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀនបានកំណត់ឱ្យរៀនត្រឹម ៦០ក្រេឌីត លើចំនួន ១២០ក្រេឌីត ដើម្បីទទួលបានសញ្ញាបត្របរិញ្ញាបត្រអប់រំ ចំពោះអ្នកសិក្សាដែលបានបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- គុណវុឌ្ឍិ ១២+២
- បទពិសោធន៍ធ្វើជាគ្រូបង្រៀនរបស់ក្រសួងអប់រំ យុវជន និងកីឡា រយៈពេល ៥ឆ្នាំ
- អាយុមិនច្រើនជាង ៥៥ឆ្នាំនៅពេលដាក់ពាក្យសុំ
- ការប្រឡងចូលរៀនជាប់ (ប្រកាសលេខ ១៨៧០)

ដូច្នេះ កម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀនត្រូវការការសិក្សាពេញម៉ោង ២ឆ្នាំ ឬការចូលរួមក្នុងវគ្គសិក្សានៅវិស្សមកាល រយៈពេល ២ឆ្នាំ ស្មើនឹង ៥០ម៉ោងក្នុងមួយសប្តាហ៍ រយៈពេល ៩សប្តាហ៍ (សរុបប្រមាណ ៩០០ ម៉ោង សម្រាប់ការរៀនផ្ទាល់)។

*តារាងទី៣៖ ចំនួនក្រេឌីតសម្រាប់មុខវិជ្ជាសិក្សានៅក្នុងកម្មវិធីបណ្ដុះបណ្ដាលគ្រូបង្រៀន និងកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀនដើម្បីទទួលបានបរិញ្ញាបត្រអប់រំផ្នែកការបង្រៀន និងចំនួនក្រេឌីត អវប សម្រាប់កម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀនបង្ហាញនៅក្នុងវង់ក្រចក (ប្រភព៖ ប្រកាសលេខ ១៨៧០ នាយកដ្ឋានបណ្ដុះបណ្ដាល និងវិក្រឹតការ ២០១៩)*

| | មុខវិជ្ជាសិក្សា | គ្រូមត្តេយ្យសិក្សា (ពេញសិទ្ធិ) **គំរូ គ** | គ្រូមត្តេយ្យសិក្សាមានសញ្ញាបត្រចាប់ពីកម្រិតបរិញ្ញាបត្រឡើងទៅក្នុងមុខវិជ្ជាពាក់ព័ន្ធ (TQU) **គំរូ ខ** | គ្រូមត្តេយ្យសិក្សាមានសញ្ញាបត្របរិញ្ញាបត្ររងសម្រាប់ការបង្រៀន ឬបរិញ្ញាបត្រមិនមែនជំនាញអប់រំកុមារតូច (TQU) **គំរូ ក** | គ្រូបឋមសិក្សា **គំរូ គ** | គ្រូបឋមសិក្សាមានសញ្ញាបត្របរិញ្ញាបត្រក្នុងមុខវិជ្ជាពាក់ព័ន្ធ (TQU) **គំរូ ខ** | គ្រូបឋមសិក្សាមានសញ្ញាបត្របរិញ្ញាបត្ររងសម្រាប់ការបង្រៀន ឬបរិញ្ញាបត្រមិនជំនាញអប់រំបឋមសិក្សា (TQU) **គំរូ ក** | គ្រូមធ្យមសិក្សាបឋមភូមិ **គំរូ គ** | គ្រូមធ្យមសិក្សាបឋមភូមិមានសញ្ញាបត្របរិញ្ញាបត្រត្រូវមុខវិទ្យាឯកទេស (TQU) **គំរូ ខ** | គ្រូមធ្យមសិក្សាបឋមភូមិមានសញ្ញាបត្របរិញ្ញាបត្ររងក្នុងការបង្រៀន ឬបរិញ្ញាបត្រមិនចំឯកទេសមុខវិជ្ជាដើម (TQU) **គំរូ ក** |
|---|---|---|---|---|---|---|---|---|---|---|
| ១ | ការសិក្សាពីការអប់រំ | ១២ | ៤ (២) | ៦ (៣) | ១២ | ៤ (២) | ៦ (៣) | ១៥ | ៤ (២) | ៦ (៣) |
| ២ | ចំណេះដឹងមុខវិជ្ជាឯកទេស | ២៥ | ៩ (៤) | ៦ (៣) | ២៥ | ៩ (៤) | ១៤ (៥) | ៥៥ | ៩ (៤) | ២២ (៨) |
| ៣ | ការសិក្សាពីកម្មវិធីសិក្សា | ៥៤ | ០ (០) | ២៤ (១២) | ៥៤ | ០ (០) | ២១ (៧) | ១២ | ០ (០) | ៩ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| ៤ | ការលើកកម្ពស់ផ្នែកភាសាបរទេស | ២ | ០ (០) | ២ (២) | ២ | ០ (០) | ២ (២) | ៨ | ០ (០) | ៦ (៦) |
| ៥ | ការស្រាវជ្រាវអប់រំ | ៣ | ៣ (១) | ៣ (១) | ៣ | ៣ (១) | ៣ (១) | ៣ | ៣ (១) | ៣ (១) |
| ៦ | កម្មសិក្សាគរុកោសល្យ | ២០ | ០ (០) | ០ (០) | ២០ | ០ (០) | ០ (០) | ២០ | ០ (០) | ០ (០) |
| ៧ | មុខវិជ្ជារួម (ចាំបាច់ និងសំខាន់) | ៤ | ២ (១) | ៤ (២) | ៤ | ២ (២) | ៤ (២) | ៧ | ២ (១) | ៤ (២) |
| | មុខវិជ្ជាជម្រើស | ០ | ១២ (១២) | ១៥ (១៥) | ០ | ១២ (១២) | ១០ (១០) | ០ | ១២ (១២) | ១០ (១០) |
| | សរុប | ១២០ | ៣០ (១៥) | ៦០ (៣០) | ១២០ | ៣០ (១៥) | ៦០ (៣០) | ១២០ | ៣០ (១៥) | ៦០ (៣០) |

កម្រិតអតិបរមានៃចំនួនក្រេឌីត អវប ដែលត្រូវបានលើកស្នើឡើង បានបង្ហាញនៅក្នុងវង់ក្រចក ផ្អែកទៅតាមរូបមន្ត ១០០% សម្រាប់មុខវិជ្ជាភាសាបរទេស និងបំណិនសិក្សា និងមុខវិជ្ជាជម្រើស និងចន្លោះពី ៣៣% - ៥០% សម្រាប់មុខវិជ្ជាសិក្សាដទៃទៀត។ ចំនួនក្រេឌីត អវប អតិបរមាសម្រាប់ជួយដល់ការដំឡើងគុណវុឌ្ឍិមានចំនួនសរុប ៥០%។

រូបមន្តផ្សេងទៀតនឹងត្រូវបានប្រើប្រាស់សម្រាប់វគ្គសិក្សានីមួយៗ ក្នុងចំណោមមុខវិជ្ជាសិក្សាទាំង៧ និងសម្រាប់គ្រូបង្រៀនតាមគំរូនីមួយៗ (មុខវិជ្ជាសិក្សានីមួយៗក្នុងចំណោមមុខវិជ្ជាសិក្សាទាំង៧ សម្រាប់គ្រូបង្រៀនតាមគំរូនីមួយៗ ដូចបង្ហាញក្នុងតារាងទី៣ ខាងលើ នឹងមានការប្រើប្រាស់រូបមន្តជាក់លាក់ដោយឡែក សម្រាប់ភាគរយក្រេឌីតដែលអាចទទួលបានតាមរយៈ អវប)។ ឧទាហរណ៍សម្រាប់គ្រូបង្រៀនបឋមសិក្សា ដែលមានសញ្ញាបត្របរិញ្ញាបត្ររងផ្នែកបង្រៀន ឬបរិញ្ញាបត្រអប់រំផ្នែកអប់រំបឋមសិក្សា ដែលបានចូលរួមនៅក្នុងកម្មវិធីដំឡើងគុណវុឌ្ឍិគ្រូបង្រៀន និងមានការផ្តល់ ៦ក្រេឌីតសម្រាប់ការសិក្សាពីការអប់រំ អាចទទួលបាន ១ ២ ឬ ៣ក្រេឌីត ក្នុងចំណោមក្រេឌីតទាំង៦ ពី អវប ដរាបណាមានការទទួលស្គាល់ថាសកម្មភាព អវប នេះគឺជា "ការសិក្សាពីការអប់រំ"។

គ្រូបង្រៀនដែលមានគុណវុឌ្ឍិ ៩+២ គួរទទួលបានជម្រើសលើកលែងក្រេឌីតដូចក្នុងតារាងទី៣ ខាងលើ ឬត្រូវរៀនចំនួន ១២០ ក្រេឌីត ដើម្បីទទួលបានបរិញ្ញាបត្រអប់រំ។

សូមមើលតារាងទី៣ ខាងលើសម្រាប់ព័ត៌មានលម្អិតអំពីលក្ខខណ្ឌទៅតាមមុខវិជ្ជាសិក្សាសម្រាប់គ្រូបង្រៀនតាមគំរូផ្សេងៗគ្នា។

### ៤.២ ក្រេឌីត អវប រួមចំណែកដល់ការឡើងឋានៈវិជ្ជាជីវៈ ស្របតាមគន្លងអាជីពគ្រូបង្រៀន

ប្រព័ន្ធ អវប មានទំនាក់ទំនងជាមួយនឹងគន្លងអាជីពគ្រូបង្រៀននៅច្រើនកម្រិត។ ក្រេឌីត អវប រួមចំណែកផ្ទាល់ដល់ការឡើងឋានៈវិជ្ជាជីវៈ ស្របតាមគន្លងអាជីពគ្រូបង្រៀន។ ឯកសារ ក្របខណ្ឌ និងសៀវភៅណែនាំប្រតិបត្តិគន្លងអាជីពគ្រូបង្រៀន ផ្តល់ការពន្យល់លម្អិតអំពីប្រព័ន្ធវាយតម្លៃ និងរបៀបដាក់ពិន្ទុលើលក្ខណៈវិនិច្ឆ័យនីមួយៗ។

### ៤.៣ ក្រេឌីត អវប រួមចំណែកដល់ការវាយតម្លៃតាមវដ្តទៀងទាត់

ដូចពន្យល់លម្អិតនៅក្នុងផ្នែក ១.៣ ខាងលើ ក្រេឌីត អវប រួមចំណែកដល់ការវាយតម្លៃតាមវដ្តទៀងទាត់។

## ៥. ដំណើរការផ្តល់ក្រេឌីត អវប

### ៥.១ ការផ្តល់ក្រេឌីតសម្រាប់ អវប មានរចនាសម្ព័ន្ធច្បាស់លាស់

នៅពេលមានការអនុវត្តសកម្មភាព អវប មានរចនាសម្ព័ន្ធច្បាស់លាស់ តាមរយៈអ្នកផ្តល់សេវា អវប មានការទទួលស្គាល់គុណភាពដូចជា គ្រឹះស្ថានអប់រំគ្រូបង្រៀន អ្នកផ្តល់សេវាត្រូវជូនដំណឹងដល់ការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ មន្ទីរ អយក រាជធានី ខេត្ត ឬការិយាល័យគ្រប់គ្រង អវប នូវបញ្ជីឈ្មោះគ្រូបង្រៀន ឬនាយកសាលាដែលបានអនុវត្តសកម្មភាព អវប ណាមួយ ប្រកបដោយជោគជ័យ ព្រមទាំងបញ្ជាក់ពីកាលបរិច្ឆេទ ទីកន្លែង ពិន្ទុដែលបានទទួល។ល។ ការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ មន្ទីរ អយក រាជធានី ខេត្ត ឬការិយាល័យគ្រងគ្រង អវប កត់ត្រាព័ត៌មាននេះបញ្ចូលទៅក្នុងប្រព័ន្ធ HRMIS។ ប្រព័ន្ធ



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

HRMIS មានព័ត៌មានអំពីអ្នកផ្ដល់សេវា អវប មានការទទួលស្គាល់គុណភាព និងប្រភេទសេវា។ ឈ្មោះគ្រូបង្រៀន ឬនាយកសាលាដែលបានចូលរួមនៅក្នុងសកម្មភាព អវប មានរចនាសម្ព័ន្ធច្បាស់លាស់ប្រកបដោយជោគជ័យ ត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធ HRMIS ហើយមានការផ្ទៀងផ្ទាត់ព័ត៌មាននេះនៅកម្រិតដែលពាក់ព័ន្ធ។ ក្រេឌីត អវប នឹងបង្ហាញនៅក្នុងកម្រងព័ត៌មានរបស់គ្រូបង្រៀនម្នាក់ៗ (កំណត់ត្រាអាជីព ឬសៀវភៅកត់ត្រា អវប)។

ក្រោយពេលបញ្ចប់គ្រប់ផ្នែកទាំងអស់នៃសកម្មភាព អវប រួមទាំងការវាយតម្លៃ នឹងមានការធ្វើបច្ចុប្បន្នភាពកំណត់ត្រាអាជីពរបស់គ្រូបង្រៀននិងនាយកសាលាដើម្បីបង្ហាញព័ត៌មាននេះ និងមានការឯកភាពពីការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ មន្ទីរ អយក រាជធានី ខេត្ត ឬការិយាល័យគ្រប់គ្រង អវប។ គ្រូបង្រៀននិងនាយកសាលាត្រូវរក្សាទុកកំណត់ត្រាអាជីពរបស់ខ្លួន។

## ៥.២ ការផ្ដល់ក្រេឌីតដល់ អវប រៀនដោយខ្លួនឯង

ការចូលរួម អវប រៀនដោយខ្លួនឯងនៅតាមសាលារៀន កម្រងសាលារៀន ឬសហគមន៍សិក្សាវិជ្ជាជីវៈត្រូវមានការឯកភាពគ្នារវាងគ្រូបង្រៀន ឬនាយកសាលាជាមួយនឹងអ្នកគ្រប់គ្រងផ្ទាល់របស់ពួកគេលើផែនការសិក្សារបស់បុគ្គលម្នាក់ៗ។ ផែនការនេះត្រូវបានរៀបចំឡើងដើម្បីបញ្ចូលចំនួនម៉ោងនៃធាតុចូលដែលបានទទួលពីប្រភព អវប រៀនដោយខ្លួនឯងដូចជា កម្មវិធីសិក្សាអនឡាញបើកទូលាយ (MOOC) មានការទទួលស្គាល់គុណភាព ព្រឹត្តិបត្រស្រាវជ្រាវណាមួយ ជំពូកដែលកំណត់ឱ្យអាននៅក្នុងសៀវភៅណាមួយ។ល។ និងផែនការសម្រាប់កំណត់ពីចំនួនម៉ោងស្វ័យសិក្សាឬការឆ្លុះបញ្ចាំង បន្ទាប់មកគឺត្រូវមានការរៀបចំជាលទ្ធផលរំពឹងទុកដើម្បីបង្ហាញឱ្យឃើញពីលទ្ធផលដែលបានពីសកម្មភាព អវប រៀនដោយខ្លួនឯង។ ក្នុងអំឡុងពេលវាយតម្លៃតាមវដ្ដទៀងទាត់ គ្រូបង្រៀនឬនាយកសាលាត្រូវបង្ហាញកម្រងភស្តុតាងដើម្បីបញ្ជាក់ថាពិតជាបានបញ្ចប់ផែនការ អវប របស់ខ្លួនប្រកបដោយជោគជ័យ ដូចជា ភស្តុតាងដែលបង្ហាញពីលទ្ធផល (លទ្ធផលនិងផលជះ)។ ប្រសិនបើទទួលបានលទ្ធផលវិជ្ជមានពីការវាយតម្លៃ នោះបញ្ជាក់ថា សាមីខ្លួនពិតជាទទួលបានក្រេឌីត អវប តាមចំនួនដែលបានកំណត់ ហើយព័ត៌មាននេះនឹងត្រូវរាយការណ៍ជូនការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ មន្ទីរ អយក រាជធានីខេត្ត ឬការិយាល័យគ្រប់គ្រង អវប ដែលនឹងបន្តកត់ត្រាព័ត៌មានចូលទៅក្នុងប្រព័ន្ធ HRMIS។ ប្រព័ន្ធ HRMIS មានព័ត៌មានអំពីប្រភព អវប រៀនដោយខ្លួនឯងដែលត្រូវបានទទួលស្គាល់គុណភាព។ ក្រោយពេលដែលព័ត៌មាននេះត្រូវបានផ្ទៀងផ្ទាត់នៅកម្រិតដែលពាក់ព័ន្ធរួច ក្រេឌីត អវប នឹងបង្ហាញនៅក្នុងកម្រងព័ត៌មានរបស់គ្រូបង្រៀនម្នាក់ៗ (កំណត់ត្រាអាជីពឬសៀវភៅកត់ត្រា អវប)។

ក្រោយពេលទទួលបានជោគជ័យពីការវាយតម្លៃទៀងទាត់តាមអង្គភាពឬគ្រឹះស្ថានសិក្សា នឹងមានការធ្វើបច្ចុប្បន្នភាពកំណត់ត្រាអាជីពរបស់គ្រូបង្រៀន និងនាយកសាលាដើម្បីបង្ហាញព័ត៌មាននេះ ដោយមានការឯកភាពពីការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ មន្ទីរ អយក រាជធានី ខេត្ត ឬការិយាល័យគ្រប់គ្រង អវប។ គ្រូបង្រៀន និងនាយកសាលាត្រូវរក្សាទុកកំណត់ត្រាអាជីពរបស់ខ្លួន។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ឯកសារយោង


Accreditation Committee of Cambodia. (2004). *Decisions on credit system and credit transfer implements for higher education* (No.04/04/ACC/SSR)

Bateman, A. (2016). *ASEAN guiding principles for quality assurance and recognition of competency certification systems*. ASEAN: Laos PDR.

*CPD Certification Service, UK*. (2020). Accessed 29 June 2020: website: https://cpduk.co.uk/

Guerriero, S. (ed.) (2017), *Pedagogical Knowledge and the Changing Nature of the Teaching Profession*, OECD Publishing, Paris *http://dx.doi.org/10.1787/9789264270695-*

Jensen, B. (2012). *Catching up: learning from the best school systems in East Asia*. Grattan Institute.

Marchington, M. and A. Wilkinson. (2008). *Human Resource Management at Work: People management and development*. 4th edition. London: CIPD.

MoEYS. (2010). *Teacher professional standards*. Phnom Penh: MoEYS

MoEYS. (2013) *Teacher Policy*. Phnom Penh: MoEYS.

MoEYS. (2015). *Teacher policy action plan*. Phnom Penh: MoEYS

MoEYS. (2016). *Teacher education provider standards*. Phnom Penh: MoEYS

MoEYS. (2017). *Policy on Continuous Professional Development for education staff*. Phnom Penh: MoEYS

MoEYS. (2017). *School director professional standards*. Phnom Penh: MoEYS

MoEYS. (2019). *Continuous Professional Development framework for teachers and school directors*. Phnom Penh: MoEYS

MoEYS. (2019). Prakas on Teacher Qualification Upgrade to BEd (teaching) (No. 1870 អយក.ប្រក)

MoEYS. (2019) *Education Strategic Plan 2019-2023*. Phnom Penh: MoEYS.

National Training Board. (2012). *Cambodian qualifications framework*. Phnom Penh: NTB.

National Training Board. (2017.) *Competency based assessment and certification system*. Phnom Penh: NTB.

UNESCO. (2015). *Teacher policy development guide*. Paris: UNESCO.

VSO. (2007). *Listening to teachers: The Motivation and Morale of Education Workers in Mozambique*. London: VSO.

## ឧបសម្ព័ន្ធទី១៖ ឧទាហរណ៍ដែលបង្ហាញពីការផ្តល់ក្រេឌីត អវប

ឧទាហរណ៍ខាងក្រោមបង្ហាញពីរបៀបផ្តល់ក្រេឌីត អវប ដោយអនុវត្តទៅលើសកម្មភាព អវប ដែលមានរួចហើយ និងការអនុវត្តគោលការណ៍ផ្តល់ក្រេឌីត។

**ការផ្តល់ប្រឹក្សាគរុកោសល្យដែលចូលរួមដោយគ្រូបង្រៀនថ្នាក់ដំបូង** (STEPCam, UNESCO)

ការចូលរួមនៅក្នុងវគ្គបណ្តុះបណ្តាលផ្ទាល់រយៈពេល ៥៤ម៉ោង+ការឆ្លុះបញ្ចាំង ១០៨ម៉ោងក្នុងអំឡុងពេលបង្រៀន និងការធ្វើសកម្មភាពដោយខ្លួនឯងដូចជា ការសរសេររបាយការណ៍ជាដើមត្រូវទទួលបានចំនួន **៤ក្រេឌីត អវប**។

ខ្លឹមសារ និងការវាយតម្លៃដែលត្រូវវាស់វែង ធៀបនឹងលក្ខណៈវិនិច្ឆ័យ៖

- ១៥% សម្រាប់វត្តមាន និងការមកទាន់ពេលវេលា (ផ្តល់ដោយអ្នកបណ្តុះបណ្តាល)
- ២៥% សម្រាប់ការឡើងបង្រៀនក្នុងវគ្គបណ្តុះបណ្តាល (ផ្តល់ដោយអ្នកបណ្តុះបណ្តាល ដោយប្រើប្រាស់សូចនាករចំនួន ១៤)
- ១០% សម្រាប់ការផលិតឯកសារបង្រៀន ក្នុងវគ្គបណ្តុះបណ្តាល (ផ្តល់ដោយអ្នកបណ្តុះបណ្តាល)
- ២០% សម្រាប់ការសរសេរអត្ថបទឆ្លុះបញ្ចាំងមួយទំព័រលើខ្លឹមសារដែលផ្តល់ដោយវគ្គបណ្តុះបណ្តាល(វាយតម្លៃដោយអ្នកបណ្តុះបណ្តាល)
- ៣០% សម្រាប់ការយកខ្លឹមសារដែលទទួលបានពីវគ្គបណ្តុះបណ្តាលទៅអនុវត្ត និងរបាយការណ៍ស្តីពីការអនុវត្ត (វាយតម្លៃដោយគ្រូផ្តល់ប្រឹក្សាគរុកោសល្យនៅក្នុងសាលារៀន)

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ឧបសម្ព័ន្ធទី២៖ តួនាទីរបស់ការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

### ចក្ខុវិស័យ និងបេសកកម្មរបស់ការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

### ចក្ខុវិស័យ

គ្រប់គ្រងប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅតាមសាលារៀន ដែលមានគុណភាពខ្ពស់ គាំទ្រ និងលើកកម្ពស់សមត្ថភាពរបស់បុគ្គលិកអប់រំ ដើម្បីធានាថាគ្រប់គ្រឹះស្ថានអប់រំសាធារណៈទាំងអស់នៅកម្ពុជា មានគ្រូបង្រៀន អ្នកដឹកនាំសាលារៀន និងអ្នកឯកទេសអប់រំមានសមត្ថភាពនិងប្រសិទ្ធភាពការងារខ្ពស់ ដែលជាអ្នកសិក្សាពេញមួយជីវិត ហើយឆ្លុះបញ្ចាំង និងកែលម្អការអនុវត្តការងារនិងការសិក្សារបស់សិស្សជាប្រចាំ។

### បេសកកម្ម

គាំទ្រនិងលើកទឹកចិត្តគ្រូបង្រៀន អ្នកដឹកនាំសាលារៀន និងអ្នកឯកទេសអប់រំ ឱ្យបន្តបង្កើនចំណេះដឹង បំណិន សមត្ថភាព និងប្រសិទ្ធភាពការងារ និងអភិវឌ្ឍអាជីពរបស់ពួកគេតាមរយៈការគ្រប់គ្រង និងការកំណត់បទប្បញ្ញត្តិក្នុងការផ្តល់នូវការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលមានគុណភាព រួមមានស្តង់ដាគំរូ ការទទួលស្គាល់គុណភាព និងការធានាគុណភាព។

### ជំពូក១៖ បទប្បញ្ញត្តិទូទៅ

**ប្រការ១៖** លក្ខខណ្ឌយោងទាំងនេះកំណត់ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដែលស្ថិតនៅក្រោមនាយកដ្ឋានបុគ្គលិក អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ។

### ជំពូក២៖ តួនាទីនិងមុខងារ

**ប្រការ២៖** ការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ រៀបចំ និងកំណត់បទប្បញ្ញត្តិការអភិវឌ្ឍវិជ្ជាជីវៈសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា តាមរយៈក្រុមការងារអន្តរនាយកដ្ឋាន ដើម្បីបំពេញតួនាទី និងមុខងារដូចខាងក្រោម៖

- គ្រប់គ្រងទិន្នន័យ និងក្រេឌីតការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
- កំណត់បទប្បញ្ញត្តិក្នុងការផ្តល់នូវការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលមានគុណភាព រួមមានការកំណត់ស្តង់ដាគំរូ ការទទួលស្គាល់គុណភាព និងការធានាគុណភាព
- គ្រប់គ្រងការផ្សព្វផ្សាយព័ត៌មាន និងទំនាក់ទំនងជាមួយគ្រូបង្រៀន អ្នកដឹកនាំសាលារៀន និងអ្នកឯកទេសអប់រំ
- អភិវឌ្ឍនិងគ្រប់គ្រង ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស (HRMIS) ក្នុងការគ្រប់គ្រងទិន្នន័យបុគ្គលិកអប់រំ ដូចបានកំណត់ក្នុងក្របខណ្ឌគតិយុត្ត និងផែនការសកម្មភាពស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ សម្រាប់គ្រូបង្រៀន និងនាយកសាលា

- គ្រប់គ្រងម៉ូឌុលនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំក្នុងប្រព័ន្ធ HRMIS រួមមានព័ត៌មានអំពីអ្នកផ្តល់សេវា និងសកម្មភាពអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងកត់ត្រាទិន្នន័យរបស់បុគ្គលិកអប់រំដែលបានអនុវត្តការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដើម្បីរៀបចំរបាយការណ៍ និងស្ថិតិទៅតាមតម្រូវការ
- ប្រមូល និងគ្រប់គ្រងទិន្នន័យការវាយតម្លៃពីតម្រូវការ និងផែនការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដើម្បីរៀបចំរបាយការណ៍ និងស្ថិតិទៅតាមតម្រូវការ
- គ្រប់គ្រងវឌ្ឍនភាពគន្លងអាជីពគ្រូបង្រៀន អ្នកដឹកនាំសាលារៀន និង អ្នកឯកទេសអប់រំ ដើម្បីរៀបចំរបាយការណ៍ និងស្ថិតិទៅតាមតម្រូវការ
- ទទួលខុសត្រូវក្នុងការផ្តល់វិញ្ញាបនបត្រការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដែលជាកម្រងស្នាដៃវិជ្ជាជីវៈរបស់បុគ្គលិកអប់រំ រយៈពេល ៥ឆ្នាំម្តង ឬទៅតាមតម្រូវការ
- តាំងស៊ប់ក្នុងក្របខណ្ឌជូនមន្ត្រីដែលបានបញ្ចប់ការបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានអប់រំគ្រូបង្រៀន
- កំណត់លក្ខណៈវិនិច្ឆ័យ សម្រាប់ទទួលស្គាល់គុណភាពគ្រឹះស្ថានផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងវិក្រឹតការគ្រូបង្រៀន វគ្គបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ការដំឡើងឋានៈវិជ្ជាជីវៈ ការផ្តល់រង្វាន់លើកទឹកចិត្ត ជាដើម
- ផ្សព្វផ្សាយវគ្គបណ្តុះបណ្តាលដែលផ្តល់ដោយគ្រឹះស្ថានអប់រំគ្រូបង្រៀន និងគ្រឹះស្ថានដទៃទៀតដែលផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
- ធានាគុណភាពសម្រាប់វគ្គបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងជ្រើសរើសអ្នកឯកទេសវាយតម្លៃគុណភាព
- រៀបចំរបាយការណ៍ស្តីពីលទ្ធផលការងារតាមកាលកំណត់ ជូនការិយាល័យរដ្ឋបាល
- ទទួលខុសត្រូវនូវភារកិច្ចដទៃទៀតដែលចាត់តាំងដោយប្រធាននាយកដ្ឋាន

ការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដឹកនាំដោយប្រធានការិយាល័យ ១រូប និងអនុប្រធានការិយាល័យ ៣រូប ។

## ជំពូក៣៖ តួនាទី និងភារកិច្ចរបស់ប្រធានការិយាល័យ

**ប្រការ៣៖ ប្រធានការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំមានតួនាទី និងភារកិច្ចដូចខាងក្រោម៖**

- គ្រប់គ្រង និងតាមដានត្រួតពិនិត្យផ្នែកទាំងអស់ក្នុងការិយាល័យ
- សហប្រតិការជាមួយនាយកដ្ឋានដទៃទៀតដើម្បីដឹកនាំ និងគ្រប់គ្រងឱ្យបានរឹងមាំជាយុទ្ធសាស្ត្រក្នុងការអនុវត្តប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលមានគុណភាព និងលើកកម្ពស់គុណភាពការអប់រំ និងបង្កើនការលើកទឹកចិត្ត សុជីវធម៌ និងប្រសិទ្ធភាពការងារ ដោយផ្អែកលើផែនការ និងគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- សហប្រតិការជាមួយនាយកដ្ឋានដទៃទៀត ដៃគូអភិវឌ្ឍន៍ និងអង្គភាពទទួលស្គាល់គុណភាព ដើម្បីធានាឱ្យបានយ៉ាងតឹងរឹងនូវការធានាគុណភាព និងដំណើរការទទួលស្គាល់គុណភាពសម្រាប់គ្រឹះស្ថានដែលផ្តល់សេវាការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដោយផ្អែកលើផែនការ និងគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា
- ពង្រឹងកិច្ចសហប្រតិការជាមួយនាយកដ្ឋានដទៃទៀត ដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាល ក្នុងការអនុវត្តវគ្គ និងកម្មវិធីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
- សហប្រតិការជាមួយនាយកដ្ឋានដទៃទៀត ក្នុងការត្រួតពិនិត្យការងាររដ្ឋបាល ហិរញ្ញវត្ថុ និងថវិកា ដើម្បីធានាបាននូវថវិកាគ្រប់គ្រាន់សម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់គ្រូបង្រៀន អ្នកដឹកនាំសាលារៀន និងអ្នកឯកទេសអប់រំទាំងអស់ រួមទាំងថវិកាសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅកម្រិតសាលារៀន
- សហការជាមួយនាយកដ្ឋានដទៃទៀតក្នុងការត្រួតពិនិត្យការអនុវត្ត និងការគ្រប់គ្រងគន្លងអាជីពគ្រូបង្រៀន អ្នកដឹកនាំសាលារៀន និងអ្នកឯកទេសអប់រំ ដោយធានាឱ្យបាននូវអន្តរកម្មដ៏រលូនរវាងប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងគន្លងអាជីពគ្រូបង្រៀន
- សហការជាមួយនាយកដ្ឋានដទៃទៀតក្នុងការលើកស្ទួយវប្បធម៌ប្រាស្រ័យទាក់ទងគ្នា និងចែករំលែកព័ត៌មានជាចំហ ទាក់ទងនឹងគុណភាពរបស់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ សម្រាប់គ្រូបង្រៀន អ្នកដឹកនាំសាលារៀន និងអ្នកឯកទេសអប់រំ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលផ្សេងៗ ដើម្បីធានាថា បុគ្គលពាក់ព័ន្ធទាំងឡាយអាចទទួលបានព័ត៌មានអំពីវគ្គបណ្តុះបណ្តាលការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដោយយោងទៅតាមកំណត់ត្រាធនធានមនុស្សផ្ទាល់ខ្លួនរបស់ពួកគេ
- សហការជាមួយនាយកដ្ឋានដទៃទៀត និងដៃគូអភិវឌ្ឍន៍ ក្នុងការលើកស្ទួយវប្បធម៌ និងអនុវត្តការប្រមូល និងគ្រប់គ្រងព័ត៌មានធនធានមនុស្សប្រកបដោយប្រសិទ្ធភាព ដើម្បីឈានដល់ការសម្រេចបាននូវការប្រើប្រាស់ប្រព័ន្ធព័ត៌មាន និងមូលដ្ឋានទិន្នន័យតែមួយ សម្រាប់រាល់ការបំពេញមុខងារធនធានមនុស្ស រួមទាំងការគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំផងដែរ
- សហការជាមួយនាយកដ្ឋានដទៃទៀត ដើម្បីគាំទ្រដល់ការបំពេញមុខងារប្រកបដោយប្រសិទ្ធភាពរបស់ផ្នែកទាំងបីនៃការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ រួមមាន៖

## ជំពូក៤៖ រចនាសម្ព័ន្ធការិយាល័យ

**ប្រការ៤៖** ផ្នែកនីមួយៗមានអនុប្រធានការិយាល័យម្នាក់។ អនុប្រធានការិយាល័យមានតួនាទី និងភារកិច្ចដូចតទៅ៖

- ជាជំនួយការប្រធានការិយាល័យ និងទទួលបន្ទុកមុខងារដែលប្រធានការិយាល័យប្រគល់ជូន
- ដឹកនាំសកម្មភាពតាមផ្នែក ក្រោមការទទួលខុសត្រូវរបស់ប្រធានការិយាល័យ និងផ្តល់ធាតុចូល និងអនុសាសន៍លើឯកសារផ្សេងៗមុនពេលបញ្ជូនទៅកាន់ប្រធានការិយាល័យ

- ការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំបែងចែកជា៣ផ្នែកគឺ៖ (១) គ្រប់គ្រងទិន្នន័យ និងក្រេឌីតការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (២) កំណត់បទប្បញ្ញត្តិក្នុងការផ្តល់នូវការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលមានគុណភាព រួមមានស្តង់ដាគំរូ ការទទួលស្គាល់គុណភាព និងការធានាគុណភាព (៣) គ្រប់គ្រងការផ្សព្វផ្សាយព័ត៌មាន និងទំនាក់ទំនងជាមួយគ្រូបង្រៀន អ្នកដឹកនាំសាលារៀន និងអ្នកឯកទេសអប់រំ ។




## ជំពូកទី៥៖ ការទទួលខុសត្រូវតាមផ្នែករបស់ការិយាល័យ

### ប្រការ៥៖ គ្រប់គ្រងទិន្នន័យ និងក្រេឌីតការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

- អភិវឌ្ឍ និងគ្រប់គ្រង ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស (HRMIS) ក្នុងការគ្រប់គ្រងទិន្នន័យបុគ្គលិកអប់រំដូចបានកំណត់ក្នុងក្របខណ្ឌគតិយុត្ត និងផែនការសកម្មភាពស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ សម្រាប់គ្រូបង្រៀន និងនាយកសាលា
- គ្រប់គ្រងម៉ូឌុលនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំក្នុងប្រព័ន្ធ HRMIS រួមមានព័ត៌មានអំពីអ្នកផ្តល់សេវា និងសកម្មភាពការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងកត់ត្រាទិន្នន័យរបស់បុគ្គលិកអប់រំដែលបានអនុវត្តការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដើម្បីរៀបចំរបាយការណ៍ និងស្ថិតិទៅតាមតម្រូវការ
- ប្រមូល និងគ្រប់គ្រងទិន្នន័យការវាយតម្លៃពីតម្រូវការ និងផែនការបណ្តុះបណ្តាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដើម្បីរៀបចំរបាយការណ៍ និងស្ថិតិទៅតាមតម្រូវការ
- កត់ត្រាទិន្នន័យធនធានគ្រូបង្រៀនគ្រប់កម្រិតរួមមានព័ត៌មានដូចជា៖ គុណវុឌ្ឍិ បទពិសោធន៍វិជ្ជាជីវៈ ការអនុវត្ត អវប និងក្រេឌីតដែលទទួលបាន និងលទ្ធផលការវាយតម្លៃផលសម្រេច

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ប្រចាំឆ្នាំ (ទិន្នន័យត្រូវកត់ត្រានៅកម្រិតសាលារៀន ការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ ឬមន្ទីរ អយក រាជធានី ខេត្ត ទៅតាមភាពសមស្រប)

- រក្សាទុកកំណត់ត្រាសកម្មភាព អវប ដែលត្រូវនឹងកំណត់ត្រាអាជីព របស់បុគ្គលិកអប់រំម្នាក់ៗ
- ទទួលខុសត្រូវក្នុងការផ្តល់វិញ្ញាបនបត្រការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដែលជាកម្រងស្នាដៃវិជ្ជាជីវៈ របស់បុគ្គលិកអប់រំ រយៈពេល ៥ឆ្នាំម្តង ឬទៅតាមតម្រូវការ
- នៅក្នុងក្របខ័ណ្ឌនៃគន្លងអាជីពគ្រូបង្រៀន និង អវប កំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ការពន្លឿនអាជីព និងទទួលបានរង្វាន់។ល។
- គ្រប់គ្រងព័ត៌មានទាក់ទងនឹងវឌ្ឍនភាពអាជីព ការផ្តល់ចំណាត់ថ្នាក់ឡើងវិញតាមរយៈការឡើងឋានៈវិជ្ជាជីវៈ ការលើកកម្ពស់គុណវុឌ្ឍិ ឬការពន្លឿនអាជីពតាមរយៈគន្លងអាជីពគ្រូបង្រៀន សម្រាប់គ្រូបង្រៀន អ្នកដឹកនាំសាលារៀន និងអ្នកឯកទេសអប់រំ ព្រមទាំងរៀបចំរបាយការណ៍ និងស្ថិតិទៅតាមតម្រូវការ
- តាំងស៊ប់ក្នុងក្របខណ្ឌជូនមន្ត្រីដែលបានបញ្ចប់ការបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានអប់រំគ្រូបង្រៀន
- កត់ត្រាលទ្ធផលនៃការវាយតម្លៃការអនុវត្តប្រចាំឆ្នាំរបស់គ្រូបង្រៀន អ្នកដឹកនាំសាលារៀន និងអ្នកឯកទេសអប់រំ
- រៀបចំរបាយការណ៍ស្តីពីគ្រូបង្រៀន អ្នកដឹកនាំសាលារៀន និងអ្នកឯកទេសអប់រំម្នាក់ៗ ដែលបង្ហាញពីស្ថានភាពដែលទាក់ទងទៅនឹងការពន្លឿនក្នុងគន្លងអាជីព (ចំនួនពិន្ទុនៅក្នុងប្រព័ន្ធផ្តល់ពិន្ទុនៃគន្លងអាជីពគ្រូបង្រៀន)
- សហការជាមួយផ្នែកគ្រប់គ្រងការផ្សព្វផ្សាយព័ត៌មាន និងទំនាក់ទំនងជាមួយគ្រូបង្រៀន អ្នកដឹកនាំសាលារៀន និងអ្នកឯកទេសអប់រំ ជួយគាំទ្រ មន្ទីរ អយក រាជធានី ខេត្ត និងការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ ដើម្បីឱ្យគ្រូបង្រៀន អ្នកដឹកនាំសាលារៀន និងអ្នកឯកទេសអប់រំ យល់ដឹងពីការគ្រប់គ្រង កំណត់ត្រាអាជីព សម្រាប់កត់ត្រាសកម្មភាព អវប
- សហការជាមួយផ្នែកគ្រប់គ្រងការផ្សព្វផ្សាយព័ត៌មាន និងទំនាក់ទំនងជាមួយគ្រូបង្រៀន អ្នកដឹកនាំសាលារៀន និងអ្នកឯកទេសអប់រំ ជួយគាំទ្រមន្ទីរ អយក រាជធានី ខេត្ត និងការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ ដើម្បីឱ្យគ្រូបង្រៀន អ្នកដឹកនាំសាលារៀន និងអ្នកឯកទេសអប់រំ យល់ដឹងពីផែនការសិក្សាវិជ្ជាជីវៈប្រចាំឆ្នាំ ឬផែនការ អវប និងការគ្រប់គ្រងកម្រងស្នាដៃវិជ្ជាជីវៈ
- សហការជាមួយផ្នែកគ្រប់គ្រងការផ្សព្វផ្សាយព័ត៌មាន និងទំនាក់ទំនងជាមួយគ្រូបង្រៀន អ្នកដឹកនាំសាលារៀន និងអ្នកឯកទេសអប់រំ ជួយគាំទ្រមន្ទីរ អយក រាជធានី ខេត្ត និងការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ ក្នុងកាទំនាក់ទំនង និងគាំទ្រ អវប តាមសាលារៀន និងសាលាកម្រង
- ចុះឈ្មោះក្រុមបច្ចេកទេស និងសហគមន៍សិក្សាវិជ្ជាជីវៈនៅកម្រិតសាលារៀន និងសាលាកម្រង

**ប្រការ៦៖ កំណត់បទប្បញ្ញត្តិក្នុងការផ្តល់នូវការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដែលមានគុណភាព រួមមានស្តង់ដាគំរូ ការទទួលស្គាល់គុណភាព និងការធានាគុណភាព**

- ផ្តល់ការគាំទ្រផ្នែករដ្ឋបាល ភស្តុភារ និងស្ថិតិដល់ការិយាល័យគាំទ្រនិងវាយតម្លៃគ្រូបង្រៀន នៃនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ដើម្បីធ្វើការវាយតម្លៃតម្រូវការ អវប និងវិភាគទិន្នន័យដែលប្រមូលបានដើម្បីរៀបចំផែនការបណ្តុះបណ្តាល
- ផ្តល់ការគាំទ្រផ្នែករដ្ឋបាល និងស្ថិតិ រួមទាំងព័ត៌មាន HRMIS អំពីតម្រូវការបណ្តុះបណ្តាលទៅដល់ការិយាល័យវិក្រឹតការ និងការិយាល័យគាំទ្រនិងវាយតម្លៃគ្រូបង្រៀន នៃនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ដើម្បីផ្តល់សិទ្ធិអនុញ្ញាតិឱ្យមានការអនុវត្តសកម្មភាព អវប នៅកម្រិតសាលារៀន និងសាលាកម្រង
- ផ្តល់ការសម្របសម្រួល និងការគាំទ្រផ្នែករដ្ឋបាល រួមទាំងព័ត៌មាន HRMIS អំពីអ្នកផ្តល់សេវា អវប និងវគ្គ អវប ទៅដល់ការិយាល័យគាំទ្រនិងវាយតម្លៃគ្រូបង្រៀន នៃនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការដើម្បីធានាគុណភាពសកម្មភាព និងវគ្គ អវប នានា
- ផ្តល់ការសម្របសម្រួល និងការគាំទ្រផ្នែករដ្ឋបាល រួមទាំងព័ត៌មាន HRMIS អំពីការវាយតម្លៃគ្រូបង្រៀន ទៅដល់ការិយាល័យគាំទ្រនិងវាយតម្លៃគ្រូបង្រៀន នៃនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ដើម្បីធានាគុណភាពដំណើរការវាយតម្លៃគ្រូបង្រៀន អ្នកដឹកនាំសាលារៀន និងអ្នកឯកទេសអប់រំ
- ផ្តល់ការសម្របសម្រួល និងការគាំទ្រផ្នែករដ្ឋបាល ភស្តុភារ និងស្ថិតិ រួមទាំងព័ត៌មាន HRMIS ទៅដល់ការិយាល័យវិក្រឹតការ និងការិយាល័យគាំទ្រនិងវាយតម្លៃគ្រូបង្រៀន នៃនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ដើម្បីធ្វើការត្រួតពិនិត្យប្រចាំឆ្នាំពីប្រព័ន្ធ អវប
- ផ្តល់ការសម្របសម្រួល និងការគាំទ្រផ្នែករដ្ឋបាលដល់ការិយាល័យវិក្រឹតការ ការិយាល័យផែនការនិងស្រាវជ្រាវគរុកោសល្យ និងការិយាល័យគាំទ្រនិងវាយតម្លៃគ្រូបង្រៀន នៃនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ក្រោមកិច្ចសហការជាមួយអង្គភាពទទួលស្គាល់គុណភាពដទៃទៀត ដើម្បីកំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ទទួលស្គាល់គុណភាព អ្នកផ្តល់សេវា អវប ឬវគ្គវិក្រឹតការ និងវគ្គ អវប នានា
- ផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានកំណត់ វាយតម្លៃគុណភាព៖ (១) អ្នកផ្តល់សេវា អវប រួមទាំងគ្រឹះស្ថានអប់រំគ្រូបង្រៀន ដែលបំពេញតាមលក្ខខណ្ឌស្តង់ដាគ្រឹះស្ថានអប់រំគ្រូបង្រៀន (២) នាយកដ្ឋានជំនាញ ដៃគូអភិវឌ្ឍន៍ និងអ្នកផ្តល់សេវាផ្សេងទៀតដែលបំពេញតាមលក្ខណៈវិនិច្ឆ័យដែលកំណត់ដោយក្រសួងអប់រំ យុវជន និងកីឡា
- ផ្អែកលើលក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់គុណភាព បង្កើតនិងទទួលស្គាល់ គ្រូបង្វឹក គ្រូណែនាំ និងគ្រូបង្គោលថ្នាក់ជាតិ សម្រាប់សកម្មភាពអវប។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- ផ្អែកលើលក្ខណៈវិនិច្ឆ័យនៃការទទួលស្គាល់គុណភាព គាំទ្រការិយាល័យវិក្រឹតការនៃនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ដើម្បីអនុម័តសកម្មភាព និងវគ្គអវប ដែលរៀបចំដោយអ្នកផ្តល់សេវា អវប
- ផ្អែកលើប្រព័ន្ធក្រេឌីតអវប ដែលអនុម័តដោយក្រសួងអប់រំ យុវជន និងកីឡា សម្របសម្រួល និងគាំទ្រការិយាល័យគាំទ្រនិងវាយតម្លៃគ្រូបង្រៀន នៃនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ក្នុងការកំណត់ក្រេឌីតសម្រាប់សកម្មភាព និងវគ្គ អវប នានា
- សម្របសម្រួលប្រព័ន្ធ និងដំណើរការចាំបាច់ សម្រាប់ការផ្តល់សេវា អវប និងគាំទ្រ ការិយាល័យវិក្រឹតការនៃនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ដើម្បីរៀបចំផែនការ និងសម្របសម្រួលការផ្តល់សេវា អវប នៅកម្រិតសាលារៀន
- ផ្តល់ការគាំទ្រ និងសម្របសម្រួលជាមួយនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ក្នុងការរៀបចំផែនការថវិកាប្រចាំឆ្នាំសម្រាប់សកម្មភាព អវប របស់គ្រូបង្រៀន អ្នកដឹកនាំសាលារៀន និងអ្នកឯកទេសអប់រំ

**ប្រការ៧៖ គ្រប់គ្រងការផ្សព្វផ្សាយព័ត៌មាន និងទំនាក់ទំនងជាមួយគ្រូបង្រៀន អ្នកដឹកនាំសាលារៀន និងអ្នកឯកទេសអប់រំ**

- សម្របសម្រួល និងគាំទ្រ ការិយាល័យវិក្រឹតការ និងការិយាល័យគាំទ្រនិងវាយតម្លៃគ្រូបង្រៀន នៃនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ក្នុងការផលិតប្រតិទិនប្រចាំឆ្នាំពីព្រឹត្តការណ៍ និងសកម្មភាព អវប នានា
- ចងក្រង ផ្សព្វផ្សាយ និងចែកចាយ ព័ត៌មាន អវប ដែលរួមមានដូចជា សៀវភៅណែនាំស្តីពី អវប និងសៀវភៅណែនាំគ្រូចេញថ្មី សម្រាប់គ្រូបង្រៀន អ្នកដឹកនាំសាលារៀន និងអ្នកឯកទេសអប់រំ ដោយផ្អែកលើធាតុចូលពីនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ
- ផ្សព្វផ្សាយ និងចែកចាយ ប្រតិទិនប្រចាំឆ្នាំពីសកម្មភាព អវប ដោយសហការជាមួយផ្នែកផ្សេងទៀតក្នុងការិយាល័យ តាមរយៈកម្មវិធី (APP) និងគេហទំព័រផ្ទាល់របស់ការិយាល័យ
- គាំទ្រការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ និងមន្ទីរ អយក រាជធានី ខេត្ត ក្នុងការបញ្ជ្រាបចំណេះដឹងពីការគ្រប់គ្រងកំណត់ត្រាអាជីព និងសកម្មភាព អវប ដល់គ្រូបង្រៀន អ្នកដឹកនាំសាលារៀន និងអ្នកឯកទេសអប់រំ
- គាំទ្រការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ និងមន្ទីរ អយក រាជធានី ខេត្ត ក្នុងការបញ្ជ្រាបចំណេះដឹងអំពីផែនការសិក្សាវិជ្ជាជីវៈប្រចាំឆ្នាំ ឬផែនការ អវប និងការគ្រប់គ្រងកម្រងស្នាដៃវិជ្ជាជីវៈ
- គាំទ្រការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ និងមន្ទីរ អយក រាជធានី ខេត្ត ក្នុងការទំនាក់ទំនង និងគាំទ្រគណៈកម្មការអវប តាមសាលារៀន និងសាលាកម្រង
- សហការជាមួយនាយកដ្ឋានគោលនយោបាយ និងនាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ គាំទ្រមន្ទីរ អយក រាជធានី ខេត្ត និងការិយាល័យ អយក ក្រុង ស្រុក ខណ្ឌ ដើម្បីគាំទ្រ និង

ប្រមូលព័ត៌មានស្តីពីការអភិវឌ្ឍក្រុមបច្ចេកទេស និងសហគមន៍សិក្សាវិជ្ជាជីវៈ នៅតាមសាលារៀន និងសាលាកម្រង សម្រាប់ចុះឈ្មោះជាមួយនឹងផ្នែកគ្រប់គ្រងទិន្នន័យ និងក្រេឌីតការអភិវឌ្ឍវិជ្ជាជីវៈប្រចាំ។

### ប្រការ៨៖ ការអភិវឌ្ឍសមត្ថភាពបុគ្គលិកការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ

ដោយមូលហេតុប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងការិយាល័យគ្រប់គ្រងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ មានមុខងារថ្មីខុសពីមុខងាររបស់ស្ថាប័នដទៃនៃក្រសួងអប់រំ យុវជន និងកីឡា ការិយាល័យនេះត្រូវរៀបចំផែនការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិកមួយចំនួន ដូចរៀបរាប់ខាងក្រោម៖

- ទស្សនកិច្ចសិក្សាទៅកាន់ការិយាល័យគ្រប់គ្រង និងរដ្ឋបាលសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅប្រទេសកំពុងអភិវឌ្ឍដែលបានអនុវត្តការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំបានជោគជ័យ ដើម្បីសង្កេត និងរៀនសូត្រពីប្រព័ន្ធ និងនិតិវិធីដែលបានអនុវត្តក្នុងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំនៅក្នុងប្រទេសនោះ
- វគ្គបណ្តុះបណ្តាលអំពីការវាយតម្លៃការងារ របស់គ្រូបង្រៀន អ្នកដឹកនាំសាលារៀន និងអ្នកឯកទេសអប់រំ
- វគ្គបណ្តុះបណ្តាលអំពីការសម្របសម្រួល កំណត់ស្តង់ដាគំរូ ទទួលស្គាល់គុណភាព ធានាគុណភាព និងរៀបចំថវិកាសម្រាប់ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
- វគ្គបណ្តុះបណ្តាលអំពីការតាមដានត្រួតពិនិត្យ និងការវាយតម្លៃប្រព័ន្ធការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
- វគ្គបណ្តុះបណ្តាលអំពីការវាយតម្លៃទ្រង់ទ្រាយធំ ពីតម្រូវការក្នុងការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ
- វគ្គបណ្តុះបណ្តាលអំពីយុទ្ធសាស្រ្តសម្រាប់ទំនាក់ទំនងជាមួយគ្រូបង្រៀន អ្នកដឹកនាំសាលារៀន និងអ្នកឯកទេសអប់រំ
- វគ្គបណ្តុះបណ្តាលអំពីការប្រើប្រាស់ប្រព័ន្ធព័ត៌មានគ្រប់គ្រងធនធានមនុស្ស។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews


នាយកដ្ឋានបុគ្គលិក
ការិយាល័យអភិវឌ្ឍន៍ធនធានមនុស្ស
ការិយាល័យឯកសារ និងព័ត៌មាន
ការិយាល័យគ្រប់គ្រង អវប
ការិយាល័យបុគ្គលិក
ការិយាល័យរដ្ឋបាល
ការិយាល័យបៀវត្ស
ការិយាល័យក្របខ័ណ្ឌ
ប្រព័ន្ធ HRMIS
ការិយាល័យគ្រប់គ្រង អវប
អនុវត្តយុទ្ធសាស្ត្រដែលមានចែងនៅក្នុងផែនការសកម្មភាព អវប ដោយសហការជាមួយនឹងថ្នាក់ជាតិរាជធានីខេត្ត ក្រុង ស្រុកខណ្ឌ សាលារៀន និងទីភ្នាក់ងារខាងក្រៅ (ដៃគូអភិវឌ្ឍន៍ អង្គការក្រៅរដ្ឋាភិបាល ។ល។
យល់ស្រប (ជាមួយនឹងដៃគូអភិវឌ្ឍន៍ និងនាយកដ្ឋានជំនាញដែលពាក់ព័ន្ធ) លើយន្តការផ្តល់ថវិកា និងវិភាជថវិកា រួមនឹងការរៀបចំកម្មវិធី អវប ទៅតាមស្ថានភាពជាក់ស្តែង (ការផ្តល់ថវិកា អវប នៅកម្រិតសាលារៀន ។ល។)
បង្ហាញជាគំរូ និងលើកកម្ពស់វប្បធម៌ទំនាក់ទំនង និងចែករំលែកព័ត៌មានដោយចំហអំពីការផ្តល់សេវា ការគ្រប់គ្រង និងការធ្វើផែនការ អវប
រៀបចំផែនការមេស្តីពី អវប
ផ្នែកកត់ត្រា និងគ្រប់គ្រងទិន្នន័យ និងក្រេឌីត អវប
ផ្នែកព័ត៌មាន និងផ្សព្វផ្សាយ អវប
ផ្នែកសម្របសម្រួល កំណត់ស្តង់ដា ទទួលស្គាល់គុណភាព ធានាគុណភាព និងរៀបចំថវិកា អវប
កត់ត្រាទិន្នន័យធនធានមនុស្សរបស់គ្រូ
គ្រប់គ្រងការឡើងឋានៈវិជ្ជាជីវៈស្របតាម TCP
បែងចែកប្រភេទគ្រូឡើងវិញ
រៀបចំរបាយការណ៍ទិន្នន័យស្តីពីការឡើងឋានៈវិជ្ជាជីវៈរបស់គ្រូ
ផលិតរបាយការណ៍ទិន្នន័យសម្រាប់ធ្វើការវិភាគ និងការធ្វើផែនការជ្រើសរើសពង្រាយគ្រូ ។ល។
គ្រប់គ្រងម៉ូឌុល អវប នៃប្រព័ន្ធ HRMIS
ចងក្រងឯកសារ និងគ្រប់គ្រងសកម្មភាព និងក្រេឌីត អវប (ទិន្នន័យ អវប បញ្ចូលដោយរាជធានីខេត្ត ក្រុងស្រុកខណ្ឌ ឬសាលារៀន)
ចេញវិញ្ញាបនបត្រ អវប ដែលបង្ហាញពីចំនួនក្រេឌីត អវប ដែលទទួលបាន
ចងក្រងឯកសារពីលទ្ធផលនៃការវាយតម្លៃលើសមត្ថកម្មប្រចាំឆ្នាំ
កំណត់លក្ខណៈវិនិច្ឆ័យសម្រាប់ការឡើងឋានៈវិជ្ជាជីវៈ ការផ្តល់លិខិតទទួលស្គាល់
ផ្សព្វផ្សាយ និងចែករំលែកព័ត៌មាន អវប (ផ្តល់ការណែនាំ និងសៀវភៅណែនាំ អវប)
ផ្សព្វផ្សាយទៅកាន់គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ (ការគ្រប់គ្រងសៀវភៅកត់ត្រាអាជីព ដែលមានកត់ត្រាពីសកម្មភាព អវប ផែនការសិក្សាវិជ្ជាជីវៈ និងកម្រងស្នាដៃវិជ្ជាជីវៈ)
ទំនាក់ទំនងទៅកាន់គណៈកម្មាធិការ អវប នៅតាមសាលារៀន និងតាមកម្រងង
ផ្សព្វផ្សាយ និងគ្រប់គ្រងបញ្ជី/ប្រតិទិនព្រឹត្តិការណ៍/សកម្មភាព អវប ប្រចាំឆ្នាំ តាមរយៈកម្មវិធីក្នុងទូរស័ព្ទចល័ត/គេហទំព័រ
រក្សាបញ្ជីឈ្មោះសមាគមវិជ្ជាជីវៈ ព្រឹត្តិបត្រព័ត៌មាន ទស្សនាវដ្តី ។ល។
គាំទ្រដល់ការអភិវឌ្ឍក្រុមបច្ចេកទេសវិជ្ជាជីវៈ/សហគមន៍សិក្សាវិជ្ជាជីវៈសម្រាប់គ្រូបង្រៀន នាយកសាលា និងអ្នកឯកទេសអប់រំ
សម្របសម្រួលជាមួយនិងនាយកដ្ឋានពាក់ព័ន្ធ ដើម្បីកំណត់ពីលក្ខណៈវិនិច្ឆ័យសម្រាប់ផ្តល់ការទទួលស្គាល់គុណភាពដល់ អវប និងផ្តល់ការទទួលស្គាល់គុណភាពដល់អ្នកផ្តល់សេវា អវប
លើកជាអនុសាសន៍ ដើម្បីឱ្យគ្រឹះស្ថានអប់រំគ្រូដែលបានទទួលបានការឯកភាព អាចចាប់ផ្តើមរៀបចំកម្មវិធីអនុវត្ត និងផ្តល់ការធានាគុណភាពកម្មវិធីវិក្រឹតការ
កំណត់/ការទទួលស្គាល់គុណភាពដល់ក្រុមគ្រូបង្វឹក អ្នកផ្តល់ប្រឹក្សាគរុកោសល្យ និងគ្រូឧទ្ទេសថ្នាក់ជាតិដែលមានសមត្ថភាព
សម្របសម្រួលជាមួយនិងនាយកដ្ឋានពាក់ព័ន្ធ ដើម្បី
រៀបចំផែនការផ្តល់សេវា អវប
ផ្តល់ការឯកភាពដល់សេវា អវប និងសេវាវិក្រឹតការដែលផ្តល់ដោយក្រសួងអប់រំ យុវជន និងកីឡា
ផ្តល់ចំនួនក្រេឌីតដល់សេវា អវប
ត្រួតពិនិត្យលើការវាយតម្លៃតម្រូវការ អវប (ប្រមូល និងវិភាគ)
រៀបចំសកម្មភាព អវប ដូចជាសកម្មភាព អវប នៅតាមសាលារៀន និងកម្រង
សម្របសម្រួលជាមួយនឹងក្រុមការងារផ្សព្វផ្សាយព័ត៌មាន ដើម្បីផលិតប្រតិទិនសេវា អវប ប្រចាំឆ្នាំ
សម្របសម្រួលជាមួយ និងនាយកដ្ឋានពាក់ព័ន្ធ ដើម្បី៖
ផ្តល់ការធានាគុណភាពដល់ការផ្តល់សេវា អវប/វិក្រឹតការ
ធ្វើការវាយតម្លៃកម្រិតអង្គភាព ឬគ្រឹះស្ថានសិក្សាលើប្រព័ន្ធ អវប
ពិនិត្យតាមដាន និងវាយតម្លៃប្រព័ន្ធ អវប
សម្របសម្រួលជាមួយនិងនាយកដ្ឋានពាក់ព័ន្ធ ដើម្បី៖
រៀបចំផែនការថវិកា អវប
វិភាជថវិកា អវប នៅកម្រិតសាលារៀន
ប្រព័ន្ធ HRMIS នៅកម្រិតរាជធានីខេត្ត ក្រុងស្រុកខណ្ឌ សាលារៀន និងគ្រូបង្រៀន (តាមរយៈកម្មវិធីក្នុងទូរស័ព្ទចល័ត)
មន្ទីរ អ.យ.ក រាជធានីខេត្ត ការិយាល័យ អ.យ.ក ក្រុងស្រុកខណ្ឌ គណៈកម្មាធិការគ្រប់គ្រង អវប តាមសាលារៀន និងគ្រូបង្រៀន
មន្ទីរ អ.យ.ក រាជធានីខេត្ត ការិយាល័យ អ.យ.ក ក្រុងស្រុកខណ្ឌ គណៈកម្មាធិការគ្រប់គ្រង អវប តាមសាលារៀន និងគ្រូបង្រៀន